**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការទទួលខុសត្រូវព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

រៀបចំឡើងដោយនិស្សិតឈ្មោះ៖

**យន ទេហា**

**អេង ចំរើន**

សាស្ត្រាចារ្យណែនាំ

**អ៊ឹង រដ្ឋា**

ថ្នាក់បរិញ្ញាបត្រផ្នែក **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ក្រុមខ្ញុំបាទឈ្មោះ **យន ទេវតា** និង **អេង ចំរើន** ជានិស្សិតផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី ២២ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំសិក្សា ២០១៨ ដល់២០២២។

**សូមលំឱនកាយគោរពប្រតិបត្តិ និងកតញ្ញូតាធម៌ ចំពោះ៖**

លោកឪពុក **យុត ណាត** លោកឪពុក **អៀ អែម**

អ្នកម្តាយ **អ៊ុំម សុផា** អ្នកម្តាយ **វ៉ែន គីមយៀង**

ដែលបានផ្តល់កំណើតដល់កូន និងជាមនុស្សដែលមានអ្វីប្រៀបផ្ទឹមពុំបានដែលបានខិតខំពុះពាររាល់គ្រប់ឧបសគ្គដើម្បីចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅ និងផ្តល់នូវដំបូន្មានល្អប្រពៃ ព្រមទាំងជួយជម្រុញ លើកទឹក ចិត្តកូនៗគ្រប់កាលៈទេសៈ ផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រឡាញ់ ការអនុគ្រោះព្រហ្មវិហាធម៌ អប់រំកូនឲ្យតែ ប្រព្រឹត្តអំពើល្អដើរតាមគន្លងធម៌ឲ្យក្លាយជាកូនល្អ ពលរដ្ឋល្អ នៅក្នុងសង្គម។ លើសពីនេះលោកក៏បានផ្តល់នូវការ ទំនុកបម្រុងទាំងផ្នែក ស្មារតី និងសម្ភារៈ។ ជាក់ស្តែង ការផ្តល់នូវចំណេះដឹងតាមរយៈការបញ្ជូនកូនៗទៅសាលាពី បឋមរហូតបានសិក្សាថ្នាក់ បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ដោយមានភាពរលូន និងទទួលបាននូវភាពជោគជ័យ។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានជួយសម្រួល និងរៀបចំកម្មវិធីសិក្សាសម្រាប់និស្សិតគ្រប់ជំនាន់ ក្នុងការគាំទ្រការសិក្សារបស់សិស្សនិស្សិតគ្រប់ជាន់ថ្នាក់ ក៏ដូចជារូបខ្ញុំប្រកបទៅដោយភាពរលូននិងភាពជឿទុកចិត្ត។ ជាពិសេសនោះ សិស្សនិស្សិតទទួលបាននូវចំណេះដឹងជាច្រើនតាមរយៈកម្មវិធីសិក្សារបស់សាកលវិទ្យាល័យហើយក៏ជាផ្លូវមួយសម្រាប់អភិវឌ្ឍប្រទេសជាតិនាពេលអនាគតផងដែរ។ ចំពោះលោកសាស្ត្រាចារ្យ **អ៊ុំង រដ្ឋា** ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់យ៉ាងមោះមុត និងចំណាយពេលវេលាដល់មានតម្លៃក្នុងការផ្តល់នូវចំណេះដឹងល្អៗដល់ក្រុមខ្ញុំបាទទាក់ទងទៅនឹងប្រធានបទស្តីពីប្រធានបទ **ការទទួលខុសត្រូវព្រហ្មទណ្ឌ** និងការកែតម្រូវកំហុសខុសឆ្គងទាំងឡាយណាដែលមានភាពមិនប្រក្រតី ចំពោះការសរសេរសារណារបស់ក្រុមយើងខ្ញុំតាំងពីចាប់ផ្តើមដំបូងរហូតទទួលបាននូវសមិទ្ធផលដល់មួយនេះ។

ជាចុងក្រោយ ក្រុមយើងខ្ញុំទាំងពីរនាក់ សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅនូវគុណូបការៈរបស់អ្នកទាំងពីរ និងលោកសាស្ត្រាចារ្យជាទីគោរព។ កូនសូមលើកដៃឡើងបួងសួងដល់វត្ថុសក្តិសិទ្ធិ និងប្រសិទ្ធពរជ័យដល់វត្ថុសក្តិសិទ្ធិក្នុងលោក សូមមេត្តាតាមជួយថែរក្សាដល់លោកទាំងអស់ ដែលបានរៀបរាប់ខាងលើឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រជំនាន់ទី២២ អស់រយៈពេល៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចាប់ពី ២០១៨ ដល់ ២០២២ រួចមកដោយបានយកចិត្តទុក្ខដាក់ខិតខំសិក្សារៀនសូត្រ និងការទទួលបានដំបូន្មានពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ ដែលជាផ្នែកដល់សំខាន់នៃសាកលវិទ្យាល័យយើងខ្ញុំដែលជានិស្សិតរួមជំនាន់ បានទទួលឱកាសសរសេរសារណាបញ្ចប់ការសិក្សាដែលមានប្រធានបទស្តីពី **ការទទួលខុសត្រូវព្រហ្មទណ្ឌ** ។

មូលហេតុនៃការជ្រើសរើសយកប្រធានបទ **ការទទួលខុសត្រូវព្រហ្មទណ្ឌ** គឺដោយសារការទទួលខុសត្រូវព្រហ្មទណ្ឌជាផ្នែកមួយដ៏សំខាន់នៅក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាយើង។ បន្ថែមពីលើសនេះទៀត យើងនឹងសិក្សាឲ្យកាន់តែស៊ីជម្រៅទៅលើប្រធានបទនេះ ដើម្បីចងក្រងទុកជាឯកសារដើម្បីផលប្រយោជន៍សាធារណៈជន និងសង្គមយើង។

ក្រុមយើងខ្ញុំមានសេចក្តីសោមនស្សរីករាយពន់ពេកដែលមានឱកាសក្នុង ការសិក្សា ការស្រាវជ្រាវ និងរៀបចំសរសេរសារណាបញ្ចប់ស្តីពី **ការទទួលខុសត្រូវព្រហ្មទណ្ឌ** ក្រោមការណែនាំដោយសាស្ត្រាចារ្យ **អ៊ុំខ រដ្ឋា** ដែលជាសាស្ត្រាចារ្យផ្នែកច្បាប់មួយរូបដែលមានបទពិសោធន៍ទាក់ទងនឹងវិស័យសាធារណៈ។ លើសពីនេះ លោកក៏បានចំណាយពេលវេលាដ៏មានតម្លៃ ទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការចែករំលែកបទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាគតិដល់ក្រុមយើងខ្ញុំបាទ។ សារណាមួយនេះមានទិសដៅស្រាវជ្រាវប្រមូលផ្តុំ និងចងក្រងក្នុងគោលបំណងបន្សល់ទុកជាឯកសារសម្រាប់បំពេញនូវតម្រូវការរបស់សិស្សនិស្សិតជំនាន់ក្រោយ ដើម្បីយកទៅសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីបង្កើននូវចំណេះដឹងក៏ដូចជាការយល់ដឹងពីច្បាប់ ឲ្យកាន់តែទូលំទូលាយទាក់ទងទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ។ ក្រៅពីនេះមូលហេតុដែលក្រុមយើងលើកយក ប្រធានបទនេះមកធ្វើជាសារណាបញ្ចប់ការសិក្សាដោយសារក្រុមយើងចង់ សិក្សាស្វែងយល់ឲ្យកាន់តែស៊ីជម្រៅលើ ការទទួលខុសត្រូវព្រហ្មទណ្ឌដែលជាផ្នែកសំខាន់នៃរឿងព្រហ្មទណ្ឌ។ ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរសង្ឃឹមថាសារណាបញ្ចប់ការសិក្សានេះនឹងអាចធ្វើជាឯកសារជំនួយក្នុងការសិក្សា ស្រាជ្រាវក្នុងរឿងព្រហ្មទណ្ឌដល់អ្នកសិក្សាជំនាន់ក្រោយ។ ទន្ទឹមនឹងនេះផងដែរយើងខ្ញុំទាំងពីរ សូមធ្វើការអធ្យាស្រ័យទុកជាមុខចំពោះចំណុចខ្វះខាត កំហុសខុសឆ្គងទាំងខ្លឹមសារ ឃ្លាប្រយោគព្រមទាំង អក្ខរាវិរុទ្ធ ដោយអចេតនាដោយប្រការណាមួយ។ យើងខ្ញុំទាំងពីររង់ចាំទទួល ការរិះគន់ ការកែតម្រូវដើម្បីស្ថាបនាគ្រប់បែបយ៉ាងពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត មិត្តអ្នកអាន និងអ្នកស្តាប់ដើម្បីឲ្យសារណានេះកាន់តែមានភាពល្អប្រសើរឡើង។ សូមអរគុណ!

# មាតិកា


**សេចក្តីផ្តើម** ................................................ ១

**ជំពូកទី ១**

**ការទទួលខុសត្រូវព្រហ្មទណ្ឌ**

**ផ្នែកទី ១ ៖ ធាតុផ្សំនៃបទល្មើស** ................................................ ៤

១. ធាតុផ្សំនីត្យានុកូល ................................................ ៤

១.១. គោលការណ៍នីត្យានុកូល ................................................ ៤

១.២. ការអនុវត្តន៍ច្បាប់ព្រហ្មទណ្ឌជាទូទៅ ................................................ ៥

២. ធាតុផ្សំសត្យានុម័ត ................................................ ៧

២.១. ការប៉ុនប៉ង ................................................ ៧

២.២. បទល្មើសដោយមានច្រើនគ្នា ................................................ ៨

៣. ធាតុផ្សំអត្តនោម័ត ................................................ ៩

៣.១. កំហុសចេតនា ................................................ ៩

៣.២. កំហុសអចេតនា ................................................ ១០

៣.៣. ការវាយតម្លៃអំពីកំហុស ................................................ ១០

**ផ្នែកទី ២ ៖ សញ្ញាណនៃជនល្មើស** ................................................ ១១

១. ចារី ................................................ ១១

២. សហចារី ................................................ ១២

៣. អ្នកផ្តើមគំនិត ................................................ ១២

៤. អ្នកសមគំនិត ................................................ ១៣

**ផ្នែកទី ៣ ៖ សញ្ញាណទូទៅនៃការទទួលខុសត្រូវព្រហ្មទណ្ឌ** ................................................ ១៤

១. ការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ................................................ ១៤

១.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន ................................................ ១៥

១.២. ការទទួលខុសត្រូវរបស់អនីតិជន ................................................ ១៥

២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ................................................ ១៦

២.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ................................................ ១៧

២.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលសាធារណៈ ................................................ ១៨

២.៣. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលឯកជន ................................................ ១៩

## ជំពូកទី ២
## ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬការសម្រាលទោស


**ផ្នែកទី ១ ៖ មូលហេតុអត្តនោម័ត** ........ ២០

១. មូលហេតុវិបល្លាសស្មារតី ........ ២០

២. អានុភាពនៃកម្លាំង ឬ ការបង្ខំ ........ ២១

**ផ្នែកទី ២ ៖ មូលហេតុស្តីពីអំពើយុត្តិកម្ម** ........ ២១

១. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ........ ២១

២. ការការពារស្របច្បាប់ ឬការការពារធម្មានុរូប ........ ២២

៣. សច្ចធារណ៍នៃការការពារស្របច្បាប់ ........ ២២

៤. ស្ថានភាពចាំបាច់ ........ ២៣


## ជំពូកទី ៣
## ការអនុវត្តទោសព្រហ្មទណ្ឌ


**ផ្នែកទី ១ ៖ សញ្ញាណនៃទោស** ........ ២៤

១. គោលបំណងនៃទោសព្រហ្មទណ្ឌ ........ ២៤

១.១. គោលបំណងនៃការធ្វើឱ្យរួញរា ឬគោលបំណងនៃការការពារទុកជាមុន ........ ២៤

១.២. គោលបំណងនៃការធ្វើសំណងជាប្រាក់ ........ ២៤

១.៣. គោលបំណងនៃការអប់រំកែប្រែ ........ ២៥

២. ចរិតលក្ខណៈនៃទោសព្រហ្មទណ្ឌ ........ ២៥

២.១. ចរិតលក្ខណៈនីត្យានុកូលនៃទោស ........ ២៥

២.២. ចរិតលក្ខណៈនៃការប្រកាសទោស ........ ២៥

២.៣. ចរិតលក្ខណៈសមភាពនៃទោស ........ ២៥

២.៤. ចរិតលក្ខណៈឯកត្តជននៃទោស ........ ២៥

៣. មុខងារនៃទោស ........ ២៦

៤. ទោស និងសញ្ញាណប្រហាក់ប្រហែល ........ ២៧

៤.១. ទណ្ឌកម្មដែលពុំមានលក្ខណៈព្រហ្មទណ្ឌ ........ ២៧

៤.២. វិធានការសន្តិសុខ ........ ២៧

**ផ្នែកទី ២ ៖ ប្រភេទនៃទោស** ........ ២៨

១. មូលទោស ........ ២៨

១.១. អប្បបរមា និងអតិបរមានៃមូលទោស ........ ២៩

១.២. ការកំណត់ទម្ងន់ទោស និងការសម្រាលទោស ........ ២៩

១.៣. ប្រភេទនៃបទល្មើស ........ ២៩

២. ទោសបន្ថែម ........................................................................................................................ ៣២
២.១. ការដកសិទ្ធិខ្លះជាពលរដ្ឋ ................................................................................................. ៣២
២.២. ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ................................................................................ ៣៣
២.៣. ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ និងការព្យួរលិខិតបើកបរ ....................... ៣៣
២.៤. ការហាមឃាត់ចំពោះការស្នាក់នៅ ....................................................................................... ៣៣
២.៥. ការហាមឃាត់ចំពោះការចាកចេញពីដែននៃព្រះរាជាណាចក្រកម្ពុជា......................................... ៣៤
២.៦. ការហាមឃាត់ចំពោះការចូលនិងការស្នាក់នៅលើដែននៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស ............................................................................................................................ ៣៤
២.៧. ការរឹបអូស និងការចាត់ចែងទ្រព្យសម្បត្តិរឹបអូស.................................................................... ៣៤
២.៨. ការហាមឃាត់ចំពោះការកាន់កាប់ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់ រំសេវគ្រប់ប្រភេទ ............... ៣៥
២.៩. ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ................................................................................ ៣៥
២.១០. ការបិទគ្រឹះស្ថាន.............................................................................................................. ៣៥
២.១១. ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ........................................................... ៣៥
២.១២. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស................................................................................ ៣៥
២.១៣. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ............................................. ៣៦
២.១៤. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍.............................. ៣៦
២.១៥. ពេលនៃការអនុវត្តទោសបន្ថែម ........................................................................................... ៣៦
៣. ទោសជំនួស.......................................................................................................................... ៣៦
**ផ្នែកទី ៣ ៖ ការអនុវត្តទោស** ................................................................................................ ៣៧
១. ការអនុវត្តទោសចំពោះនីតិជន ................................................................................................ ៣៧
២. ការអនុវត្តទោសចំពោះអនីតិជន ............................................................................................. ៣៧
២.១. ប្រភេទវិធានការអនុវត្តចំពោះអនីតិជន................................................................................... ៣៨
២.២. មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំ .................................................................. ៣៨
២.៣. ទោសបន្ថែមចំពោះអនីតិជន ................................................................................................ ៣៩
២.៤. ទោសជំនួសចំពោះអនីតិជន .................................................................................................. ៣៩
២.៥. ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស ............................................................................. ៣៩
២.៦. កាតព្វកិច្ចដោយឡែកនៃការព្យួរទោសសាកល្បងរបស់អនីតិជន .................................................. ៤០
៣. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី.............................................................................. ៤០
៣.១. ការឃាត់ខ្លួន ...................................................................................................................... ៤០
៣.២. ការបញ្ជូនខ្លួន...................................................................................................................... ៤១
៣.២. ការឃុំខ្លួនបណ្តោះអាសន្ន...................................................................................................... ៤១
៤. ការអនុវត្តទោសចំពោះនីតិបុគ្គល ............................................................................................. ៤៦
៤.១. មូលទោសក្នុងឋានៈជាទោសពិន័យដែលអនុវត្តចំពោះនីតិបុគ្គល ............................................... ៤៧
៤.២. ទោសបន្ថែមដែលអនុវត្តចំពោះនីតិបុគ្គល............................................................................... ៤៨
**ផ្នែកទី ៤ ៖ ការរំលត់ទោស**...................................................................................................... ៥០

១. មរណៈភាពរបស់ជនជាប់ទោស.......................................................................................៥១
២. អជ្ញាយុកាលនៃទោស........................................................................................................៥១
៣. ការលើកលែងទោស ........................................................................................................៥១
៤. ការលើកលែងទោសជាទូទៅ...............................................................................................៥២
៥. ការផ្ដល់ និង ការមាននីតិសម្បទាឡើងវិញ.........................................................................៥៣
៦. ការលុបចោលទោសបន្ថែមខ្លះ ...........................................................................................៥៤
**សេចក្ដីសន្និដ្ឋាន**....................................................................................................................៥៥
**អនុសាសន៍**............................................................................................................................៥៧
**ឯកសារយោង** ........................................................................................................................
**ឧបសម្ព័ន្ធ**...............................................................................................................................

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## មូលហេតុនៃការស្រាវជ្រាវ

នៅក្នុងសង្គមបច្ចុប្បន្ន ការរស់នៅរបស់មនុស្សគ្រប់រូប តែងតែប្រាថ្នាការរស់នៅដែលមានភាពល្អប្រសើរមានជីវភាពសមរម្យ មានសុវត្ថិភាព មានសន្តិភាព ប៉ុន្តែនៅក្នុងការរស់នៅតែងតែមាននូវ ការឈ្លោះប្រកែក មានការទាស់ពាក្យសម្តី។ លើសពីនេះទៅទៀត ការធ្វើអំពើមិនគប្បីដែលផ្ទុយ ច្បាប់ទម្លាប់ ជារឿយៗដែលជាហេតុនាំឱ្យមានអំពើល្មើស ឬដែលហៅបានម្យ៉ាងទៀតថា បទល្មើស កើតឡើង។ ការប្រព្រឹត្តអំពើល្មើស ឬបទល្មើសមានករណីដូចជា ការប្រព្រឹត្ត បទល្មើសគ្រឿងញៀន បទល្មើសប្រើអំពើហិង្សា បទល្មើស រំលោភសេពសន្ថវៈ បទល្មើសឆបោក បទល្មើសឃាតកម្ម។ ជាលទ្ធផល អ្នកដែលប្រព្រឹត្តអំពើល្មើសទាំងនេះតម្រូវឲ្យមានការទទួលទោសទៅតាមផ្លូវច្បាប់ដែលយើងហៅថា **ការទទួលខុសត្រូវព្រហ្មទណ្ឌ**។

ជាក់ស្តែង បុគ្គលគ្រប់រូបត្រូវបានចងចំណងជាមួយនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ។ នៅពេលមនុស្សនៅក្នុងសង្គមបានប្រព្រឹត្តបទល្មើស ពួកគេតម្រូវឲ្យចូលខ្លួនទទួលខុសត្រូវព្រហ្មទណ្ឌទៅតាមស្ថានភាពរបស់ពួកគេដែលស្របតាមអ្វីដែលច្បាប់បានកំណត់។ យើងអាចនិយាយបានថា ការទទួលត្រូវព្រហ្មទណ្ឌ ជាច្បាប់ដែលបានតាក់តែងឡើងនេះ គឺពិតជាផ្តល់គុណសម្បត្តិធំធេងឥតគណនាសម្រាប់ សង្គមខ្មែរក៏ដូចជាពិភពលោកទាំងមូល។ **ការទទួលខុសត្រូវ** សំដៅដល់កាតព្វកិច្ចផ្លូវច្បាប់ ក្នុងការឆ្លើយតបចំពោះការខូចខាតដែលសកម្មភាពបង្កឡើងដោយរូបវន្តបុគ្គល និងនីតិបុគ្គល។ ដោយឡែកពាក្យគតិយុត្ត **ព្រហ្មទណ្ឌ** បើយោងតាមវចនានុក្រម **សម្តេចសង្ឃរាជ ជួន ណាត** ជាឈ្មោះច្បាប់ដែលរាជការបញ្ញត្តិសម្រាប់ ពិភាក្សា កាត់ទោស ពិន័យ មនុស្ស ដែលប្រព្រឹត្តល្មើស និងបញ្ញត្តិសម្រាប់ប្រទេស។ ជាលទ្ធផល យើងអាចបកស្រាយបានថា **ការទទួលខុសត្រូវព្រហ្មទណ្ឌ** មានន័យថាជាការឆ្លើយតបចំពោះការខូចខាតដែលបណ្តាលមកពីការប្រព្រឹត្តល្មើស និងបញ្ញត្តិច្បាប់។ ពិតណាស់ នៅពេលដែលរូបវន្តបុគ្គល និងនីតិបុគ្គលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌត្រូវតែទទួលខុសត្រូវនូវអំពើរបស់ខ្លួន ទោះបីជាបទល្មើសនោះជា បទលហុ បទមជ្ឈិម ឬបទឧក្រិដ្ឋក្តី ដាច់ខាតគឺ ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌតាមបញ្ញត្តិដែលមានចែង។

ការទទួលខុសត្រូវព្រហ្មទណ្ឌជាផ្នែកច្បាប់មួយដែលបានអនុម័តឡើង ដើម្បីដោះស្រាយបញ្ហាជាច្រើននៅក្នុងសង្គមខ្មែរ។ រាល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលមានរូបរាងនៅក្នុងសង្គមតែងបង្កើតជាបញ្ហាដោយចេតនា និងអចេតនា។ ជាសមទ្ធិផលនៃ ការសិក្សា ការវិភាគ ការវែកញែក នៃបញ្ហាសង្គមរបស់អ្នកសិក្សាស្រាវជ្រាវច្បាប់ក្នុងសង្គមខ្មែរទាំងមូលបានបង្កឲ្យមានការតាក់តែងច្បាប់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះឡើង ដើម្បីដោះ ស្រាយបទល្មើសគ្រប់ប្រភេទដែលកើតមាន។

## ចំណោទបញ្ហានៃការស្រាវជ្រាវ

តើការសិក្សាស្រាវជ្រាវអំពីការទទួលខុសត្រូវព្រហ្មទណ្ឌមានផលប្រយោជន៍អ្វីខ្លះ?

តើការទទួលខុសត្រូវនោះមានលក្ខណៈយ៉ាងណា ប្រសិនបើជនល្មើសជា នីតិជន អនីតិជន នីតិបុគ្គលសាធារណៈ និង នីតិបុគ្គលឯកជន?

តើមានលក្ខខណ្ឌបែបណាដែលត្រូវទទួលបានការសម្រាលឬការមិនទទួលខុសត្រូវព្រហ្មទណ្ឌ?

តើការអនុវត្តទោសព្រហ្មទណ្ឌមានលក្ខណៈដូចម្តេចខ្លះ?

## គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវអំពីប្រធានបទ **ការទទួលខុសត្រូវព្រហ្មទណ្ឌ** គឺដើម្បីផ្តល់ភាពងាយស្រួលក្នុងការស្វែងយល់ អំពីបែបបទនៃ ការទទួលទោសទណ្ឌរបស់ជនដែលបានប្រព្រឹត្តអំពើល្មើស និងបញ្ញត្តិច្បាប់ក្នុងក្រមព្រហ្មទណ្ឌ ក្នុងនាមដែលជនល្មើសជា នីតិជន អនីតិជន ឬជានីតិបុគ្គលសាធារណៈ និងឯកជន ហើយឱ្យយល់ថា អំពើឬ ទង្វើមួយចំនួនដែលក្រមព្រហ្មទណ្ឌ បានចែងយ៉ាងច្បាស់ ត្រង់មាត្រា ៣១ ដល់មាត្រា ៣៧ ថាមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ឬទទួលបានការសម្រាល។

## ដែនកំណត់នៃការស្រាវជ្រាវ

ចំពោះដែនកំណត់នៃការស្រាវជ្រាវនៃប្រធាននេះ យើងជ្រើសរើសយកតែ ការទទួលខុសត្រូវព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះយកមកសិក្សា និងវិភាគ។ ជាងនេះទៅទៀត យើងក៏អាចលើកច្បាប់ផ្សេងទៀតរបស់ខ្មែរយើងដែលពាក់ព័ន្ធនឹង ការទទួលខុសត្រូវព្រហ្មទណ្ឌ ដើម្បីធ្វើការបញ្ចូលគ្នាឲ្យមានភាពរលូន និងភាពច្បាស់លាស់ក្នុងការបកស្រាយតាមរយៈការវិភាគទិន្នន័យច្បាប់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ។

## សារៈសំខាន់នៃការស្រាវជ្រាវ

ការរៀបចំតាក់តែងនូវរបាយការណ៍នេះឡើងក្នុងគោលបំណង ចងក្រង ប្រមូលឯកសារច្បាប់ពាក់ព័ន្ធទៅនឹង **ការទទួលខុសត្រូវព្រហ្មទណ្ឌ** ជាឯកសារច្បាប់ដោយដែលមានចែង។ លើសពីនេះទៀត យើងសិក្សា និងវិភាគទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌឲ្យបានកាន់តែស៊ីជម្រៅ ដើម្បីជាឯកសារដ៏សំខាន់មួយសម្រាប់សិស្សានុសិស្ស និស្សិត អ្នកស្រាវជ្រាវ និងប្រជាពលរដ្ឋដែលចង់ស្វែងយល់ពី ការទទួលត្រូវព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា។ បន្ថែមលើនេះទៀត ដើម្បីពង្រីកចំណេះដឹងផ្ទាល់ខ្លួន ព្រមទាំងចូលរួមចំណែកផ្តល់ជាអនុសាសន៍ខ្លះលើការអនុវត្តន៍ច្បាប់ខាងលើ គ្រប់រូបវន្តបុគ្គល ឲ្យមានប្រសិទ្ធិភាព តម្លាភាព ពាក់ព័ន្ធទៅនឹង ការទទួលខុសត្រូវព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីសង្គមជាតិទាំងមូល។

## វិធីសាស្ត្រនៃការស្រាវជ្រាវ

បើយើងក្រឡេកមកដឹងពីវិធីសាស្ត្រនៃការស្រាវជ្រាវ យើងបានចងក្រងឯកសារនេះឡើងតាមរយៈ ការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យដោយយោងទៅឯកសារដែលយើងបានជួបប្រទះទៅតាមច្បាប់កំណត់។

## រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធានាដល់ការអនុវត្តន៍នីតិវិធីលើជនល្មើសឱ្យត្រឹមត្រូវតាមច្បាប់ ហេតុនេះហើយបានត្រូវសិក្សាឱ្យលម្អិតស៊ីជម្រៅពីប្រធានបទមួយនេះ ក្រុមខ្ញុំបាទសូមធ្វើការបង្ហាញពីរចនាសម្ព័ន្ធនៃសារណានេះដែលត្រូវបានចែកជាៈ

**ជំពូកទី ១ ការទទួលខុសត្រូវព្រហ្មទណ្ឌ**

**ជំពូកទី ២ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬការសម្រាលទោស**

**ជំពូកទី ៣ ការអនុវត្តទោសព្រហ្មទណ្ឌ**

# ជំពូកទី ១

# ការទទួលត្រួចព្រហ្មទណ្ឌ

# ជំពូកទី ១
# ការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌយោងតាមមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោស ដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទើបអាចត្រូវប្រកាសបាន។ នៅក្នុងមាត្រានេះក៏បានកំណត់ទៀតថា គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង។

## ផ្នែកទី ១ ៖ ធាតុផ្សំនៃបទល្មើស

ធាតុផ្សំនៃបទល្មើសត្រូវបានចែកចេញជាបីប្រភេទគឺ **ធាតុផ្សំនីត្យានុកូល ធាតុផ្សំសន្យានុម័ត ឬធាតុផ្សំសម្ភារៈ** និង **ធាតុផ្សំអត្តនោម័ត**។ យោងតាម **គោលការណ៍ឯកត្តកម្ម** នៃការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលណាប្រព្រឹត្តបុគ្គលនោះទទួលចំពោះតែអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។[១]

### ១. ធាតុផ្សំនីត្យានុកូល

ធាតុផ្សំនីត្យានុកូល គឺជាធាតុផ្សំទាក់ទងនឹងច្បាប់។ រាល់បទល្មើសណាមួយដែលមានច្បាប់ចែងជាគោលការណ៍នីត្យានុកូលភាព។ គោលការណ៍នេះបង្កើតឲ្យមានផលវិបាកពីរដែលត្រូវស្វែងយល់ជាចាំបាច់គឺ **គោលការណ៍មិនប្រតិសកម្ម**នៃច្បាប់ព្រហ្មទណ្ឌសំដៅដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌជាទូទៅ និងការអនុវត្តច្បាប់ព្រហ្មទណ្ឌដោយតុលាការ សំដៅដល់ការបកស្រាយច្បាប់យ៉ាងតឹងរ៉ឹងនៃច្បាប់ព្រហ្មទណ្ឌដោយតុលាការ។

#### ១.១. គោលការណ៍នីត្យានុកូល

គោលការណ៍នីត្យានុកូលភាពត្រូវបានបង្កើតឡើងក្នុងគោលបំណង ដើម្បីការពារសិទ្ធិសេរីភាពរបស់បុគ្គលក្នុងការប្រព្រឹត្តអំពើផ្សេងៗ។ បើយោងតាមក្រមព្រហ្មទណ្ឌទទួលស្គាល់គោលការណ៍នីត្យានុកូលភាពដែលចែងថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះទើបត្រូវផ្តន្ទាទោសបាន។ មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលប្រព្រឹត្តបទល្មើសបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចប្រកាសបាន។[២]

យោងតាមគោលការណ៍ខាងលើ ដើម្បីអាចចាត់ទុកថាអំពើណាមួយជាបទល្មើសហើយត្រូវផ្តន្ទាទោសបានលុះត្រាតែមានបញ្ញត្តច្បាប់បានចែងថា អំពើនោះជាបទល្មើស ហើយត្រូវទទួលរងទណ្ឌកម្មដែលច្បាប់កំណត់។ ដូច្នេះរាល់ការចោទប្រកាន់ និងការដាក់ទោសទាំងអស់ត្រូវតែផ្អែកលើច្បាប់។ **គ្មានច្បាប់ចែង គ្មានបទល្មើស គ្មានទោសឡើយ**។ ការអនុវត្តគោលការណ៍នីត្យានុកូលឱ្យបានល្អតម្រូវដាច់ខាតឱ្យបទល្មើសត្រូវតែមានចែងយ៉ាង

[១] ក្រមព្រហ្មទណ្ឌ, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ២០០៩, មាត្រា ២៤

[២] ក្រមព្រហ្មទណ្ឌ, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៣

ច្បាស់លាស់នៅក្នុងច្បាប់។ ការកំណត់បទល្មើសក្នុងលក្ខណៈទូលំទូលាយពេក មិនអាចធានាបាននូវការគោរពសិទ្ធិសេរីភាពរបស់បុគ្គលឡើយ ពីព្រោះថាអាចឱ្យគេចោទប្រកាន់យ៉ាងងាយស្រួលលើជនទាំងឡាយណាដែលគេពុំពេញចិត្ត។[៣]

## ១.២. ការអនុវត្តន៍ច្បាប់ព្រហ្មទណ្ឌជាទូទៅ

ការអនុវត្តច្បាប់ព្រហ្មទណ្ឌចោទជាបញ្ហាសំខាន់ៗពីរដែលត្រូវដោះស្រាយគឺ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា និងការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ។

### ក. ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

បទដ្ឋានព្រហ្មទណ្ឌមាន**អានុភាពគតិយុត្ត**ក្នុងអំឡុងពេលដែលបទដ្ឋានទាំងនោះចូលជាធរមាន មានន័យថាចាប់ពីថ្ងៃដែលច្បាប់ចូលជាធរមានរហូតដល់ថ្ងៃដែលច្បាប់ត្រូវបាន**និរាករណ៍**ចោល។ ប្រសិនបើច្បាប់ពីរ មានកម្មវត្ថុដូចគ្នាទាំងស្រុង ឬដូចគ្នាខ្លះ ហើយចូលជាធរមាននៅក្នុងកាលបរិច្ឆេទខុសៗគ្នា អាចនឹងចោទជាបញ្ហាចំពោះស្ថានភាពគតិយុត្តមួយដែលបានកើតឡើង។ តាមគោលការណ៍នីត្យានុកូល ស្តែងឱ្យឃើញថាច្បាប់ព្រហ្មទណ្ឌមិនមានលក្ខណៈប្រតិសកម្មឡើយ មានន័យថាច្បាប់ដែលចូលជាធរមាននៅថ្ងៃណាមួយជាកំណត់ គឺជាទូទៅមិនមានអានុភាពលើស្ថានភាព ដែលបានកើតមុនពេលច្បាប់ចូលជាធរមានឡើយ។ **គោលការណ៍មិនប្រតិសកម្ម** នៃច្បាប់ព្រហ្មទណ្ឌមាត្រា ១០ កថាខណ្ឌទី២នៃក្រមព្រហ្មទណ្ឌបានចែងថា បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាងនឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃប្បញ្ញត្តិនោះ។[៤]

### ខ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ

វិវាទច្បាប់នៅក្នុងលំហ នឹងកើតមានឡើងនៅពេលដែលមានធាតុបរទេសចូលរួមនៅក្នុងវិវាទនោះ។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានយកគោលការណ៍ពីរយ៉ាងមកអនុវត្តគឺ **គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា** ក្នុងករណីដែលបទល្មើសបានប្រព្រឹត្តនៅដែនដីព្រះរាជាណាចក្រកម្ពុជា និង **គោលការណ៍សញ្ជាតិនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា** ក្នុងករណីដែលបទល្មើសបានកើតឡើងនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[៥]

#### ខ.១. នៅក្នុងករណីដែលបទល្មើសបានប្រព្រឹត្តឬចាត់ថាបានប្រព្រឹត្តនៅលើដែនដីព្រះរាជាណាចក្រកម្ពុជា

យោងតាមមាត្រា ១២ នៃក្រមព្រហ្មទណ្ឌបានចែងថា ក្នុងរឿងព្រហ្មទណ្ឌច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ពុទាំងឡាយបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជារួម

[៣] គោលការណ៍ទូទៅនៃក្រមព្រហ្មទណ្ឌ

[៤] ក្រមព្រហ្មទណ្ឌ, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១០

[៥] វុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ១១៨

បញ្ចូលទាំង លំហ អាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះដែរ គេសង្កេតឃើញថាគោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាក៏ត្រូវបាន កម្រិតខ្លះដែរ ដោយសារមូលហេតុផ្សេងៗ។[៦]

**គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា** បទល្មើសមួយត្រូវចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ក្រៅពីនេះ មាត្រា ១៥ នៃក្រមព្រហ្មទណ្ឌក៏បានប្រគល់សមត្ថកិច្ចឱ្យច្បាប់កម្ពុជា។ បន្ថែមលើនេះទៀត ចំពោះករណីបទល្មើសបានប្រព្រឹត្តនៅក្នុងនាវាបរទេសហើយ ដែលអាជ្ញាធរកម្ពុជាបានទទួល ការអនុញ្ញាតឱ្យពិនិត្យមើល ឬ ឱ្យចាប់តាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ។[៧]

**ការកម្រិតនៃការអនុវត្តគោលការណ៍ដែនដី** បើទោះបីជាក្រមព្រហ្មទណ្ឌមិនបានបញ្ជាក់ ឬចែងអំពីករណីដែលមិនអាចអនុវត្តគោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាក៏ពិតមែន ក៏**ច្បាប់អន្តរជាតិ**បានទទួលស្គាល់នូវ**អភ័យឯកសិទ្ធិ**[៨] ចំពោះឯកអគ្គរាជទូតឬរដ្ឋទូត និងភ្នាក់ងារទូតព្រមទាំងក្រុមគ្រួសារផងដែរ។[៩]

### ខ.២. ករណីដែលបទល្មើសប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ទន្ទឹមនឹងគោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា ក្រមព្រហ្មទណ្ឌក៏អនុវត្តគោលការណ៍សញ្ជាតិនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌដែរ ពោលគឺច្បាប់កម្ពុជាមានសមត្ថកិច្ចអនុវត្តក្នុងករណីដែល ជនល្មើស ឬ ជនរងគ្រោះ មានសញ្ជាតិជាខ្មែរ កាលបើបទល្មើសបានប្រព្រឹត្តិនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឬក៏ក្នុងករណីដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ប្រទេសកម្ពុជា។

**គោលការណ៍សញ្ជាតិនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា** ក្នុងករណីជនល្មើសជាជនជាតិខ្មែរ ច្បាប់កម្ពុជាត្រូវយកទៅអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋទាំងអស់ដែលប្រព្រឹត្តដោយជននោះ។ ប្រសិនបើជាបទមជ្ឈិមវិញ ច្បាប់កម្ពុជាត្រូវអនុវត្តបាន លុះត្រាតែអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសដែលបទល្មើសបានកើតឡើងផងដែរ។ ចំណែកឯករណី ជនរងគ្រោះជាពលរដ្ឋខ្មែរច្បាប់កម្ពុជាត្រូវយកទៅអនុវត្តលើគ្រប់បទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាជនល្មើសជាជនបរទេស ឬជាពលរដ្ឋខ្មែរក៏ដោយ។ ការចោទប្រកាន់អាចធ្វើទៅបានលុះត្រាតែមានបណ្តឹងរបស់ ជនរងគ្រោះ ជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត។

---

[៦] ក្រមព្រហ្មទណ្ឌ, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១២

[៧] ក្រមព្រហ្មទណ្ឌ, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៥

[៨] អភ័យឯកសិទ្ធិ គឺជាមូលហេតុនៃការមិនដាក់ទោស(និទ្ទណ្ឌភាព)

[៩] ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានៃទីក្រុងវីយែន (Convention de Vienne) ចុះ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៦១។

**ការអនុវត្តច្បាប់កម្ពុជាដោយសារការប៉ះពាល់ផលប្រយោជន៍កម្ពុជា** ក្រៅពីករណីខាងលើ ច្បាប់កម្ពុជាក៏មានសមត្ថកិច្ចអនុវត្តដែរ ប្រសិនបើបទល្មើសប៉ះពាល់ដល់ដែនអធិបតេយ្យជាតិរបស់កម្ពុជា ទោះបីជាត្រូវបានប្រព្រឹត្តនៅឯបរទេសក៏ដោយ ហើយបទល្មើសទាំងនោះមានដូចជា៖

- បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា
- បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា
- បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា
- បទល្មើសដែលប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា
- បទល្មើសប្រឆាំងនឹងទីតាំង ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។[១០]

## ២. ធាតុផ្សំសត្យានុម័ត

ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ គឺជាអង្គហេតុឬហេតុការណ៍ទាំងឡាយណាដែលបង្កឱ្យកើតមាននូវអាកប្បកិរិយាណាមួយ។ អង្គហេតុទាំងនោះមានច្រើនដូចជា អំពើវិជ្ជមាន អំពើអវិជ្ជមាន និងអំពើកើតឡើងភ្លាមៗ។ បទល្មើសកើតឡើងតែក្នុងករណីដែលមានអាកប្បកិរិយាជាសម្ភារៈ សម្តែងចេញខាងក្រៅតែប៉ុណ្ណោះ ហើយអាកប្បកិរិយានោះទៀតសោតត្រូវបានហាមឃាត់ដោយច្បាប់ ពោលគឺច្បាប់បានបញ្ញត្តទុកជាមុន។ បទល្មើសត្រូវតែស្តែងឡើងដោយអំពើជាសម្ភារៈដែលគេអាចពិនិត្យឃើញបាន។ តាមអំពើសម្ភារៈរបស់បទល្មើសគេបែងចែករវាងបទល្មើសបានសម្រេចផល និងប៉ុនប៉ង។ នៅពេលបទល្មើសបានសម្រេចផល ពោលគឺបានឈានដល់គោលដៅចប់សព្វគ្រប់ហើយ ជនល្មើសត្រូវតែផ្តន្ទាទោស។ ប៉ុន្តែ នៅពេលដែលអំពើពុំទាន់បានចប់សព្វគ្រប់ ឬគ្រាន់ជាការប៉ុនប៉ង បញ្ហាចោទនោះគឺ ការកំណត់ទណ្ឌកម្ម។[១១]

### ២.១. ការប៉ុនប៉ង

ដើម្បីឱ្យអំពើល្មើសមួយអាចផ្តន្ទាទោសបាន ច្បាប់មិនតម្រូវឱ្យរងចាំដល់លទ្ធផលបានសម្រេចនោះទេ។ ដំណាក់កាលនៃការប្រព្រឹត្តបទល្មើសមានពីរគឺ **ដំណាក់កាលខាងក្នុង** សំដៅដល់ចិត្តគំនិតប្រព្រឹត្តបទល្មើសឬការសម្រេចចិត្ត និងចំណែកឯ **ដំណាក់កាលខាងក្រៅ** សំដៅដល់ការរៀបចំ ឬការត្រៀមប្រព្រឹត្តបទល្មើសការប្រតិបត្តិ ឬការប្រព្រឹត្តបទល្មើស និងចុងក្រោយគឺលទ្ធផលជាព្យសនកម្មនៃបទល្មើស។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យ៉ាងច្បាស់លាស់ពីធាតុផ្សំនៃការប៉ុនប៉ងមានទោស និងទណ្ឌកម្មដែលត្រូវអនុវត្តលើការប៉ុនប៉ងប្រព្រឹត្តបទល្មើស។

#### ក. ធាតុផ្សំនៃការប៉ុនប៉ងមានទោស

[១០] ក្រមព្រហ្មទណ្ឌ, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ២០០៩, មាត្រា ២២

[១១] រុន ពណ្ណារីទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ១៤៨

យោងតាមមាត្រា ២៥ កថាខណ្ឌទី២នៃក្រមព្រហ្មទណ្ឌបានចាត់ទុកជាចារីផងដែរចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទ ឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកចំពោះ បទមជ្ឈិម។ មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋទាំងអស់ត្រូវទទួល ការផ្តន្ទាទោស។ ចំណែកក្នុង បទមជ្ឈិម ទទួលការផ្តន្ទាទោសកាលបើមានច្បាប់ចែងទុក។ ការប៉ុនប៉ងក្នុងលហុ ពុំទទួលការផ្តន្ទាទោសទេ។ មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌក៏បានកំណត់ផងដែរនូវលក្ខខណ្ឌពីរយ៉ាង ដើម្បីកំណត់ថាការប៉ុនប៉ងមានទោសគឺៈ

- ចារីបានចាប់ផ្តើមអនុវត្តបទល្មើសមាននំយថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស។ ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្តទេ។
- តែត្រូវបានរាំងស្ទះ ឬ អាក់ខានដោយសារ ឥទ្ធិពលនៃកាលៈទេសៈខាងក្រៅឆន្ទៈរបស់ចារី។[១២]

**ខ. ទណ្ឌកម្មលើការប៉ុនប៉ង**

មុនពេលក្រមព្រហ្មទណ្ឌចូលជាធរមាន ពុំមានបញ្ញត្តិទូទៅណាមួយដាក់ទោសលើ ការប៉ុនប៉ងប្រព្រឹត្តបទល្មើសនោះទេ ដោយច្បាប់ចែងការផ្តន្ទាទោសបទល្មើសបានសម្រេចផល និងការប៉ុនប៉ងប្រព្រឹត្តក្នុងបទល្មើសនីមួយៗផ្ទាល់តែម្តង។ យោងតាមខ្លឹមសារមាត្រា ២៥ និង ២៧ នៃក្រមព្រហ្មទណ្ឌការផ្តន្ទាទោសលើ ការប៉ុនប៉ងមិនខុសពី ការផ្តន្ទាទោសលើបទល្មើសបានសម្រេចផលឡើយ។ បើពិនិត្យឲ្យឃើញថា មានគ្រប់លក្ខខណ្ឌនៃការប៉ុនប៉ង ក៏ប៉ុន្តែសម្រាប់ បទមជ្ឈិម អាចនឹងទទួលទោសលុះត្រាតែមានច្បាប់ចែងទុកជាមុន។ ជាទូទៅ នៅក្នុងការដាក់ទោសលើ ការប៉ុនប៉ងប្រព្រឹត្តបទល្មើសដោយអំពើប៉ុនប៉ង ពុំទាន់បង្កឱ្យមានព្យសនកម្មកើតឡើងទេ ចៅក្រមមិនដាក់ទោសលើ ចារី ឱ្យធ្ងន់ធ្ងរដូចចារីនៃបទល្មើសបានសម្រេចផលឡើយ។

### ២.២. បទល្មើសដោយមានច្រើនគ្នា

បទល្មើសភាគច្រើនប្រព្រឹត្តឡើងដោយបុគ្គលតែម្នាក់តែប៉ុណ្ណោះ។ តែក្នុងសង្គមបច្ចុប្បន្ន ការប្រព្រឹត្តបទល្មើសក៏ដូចជាសកម្មភាពផ្សេងៗទៀតរមែងតែងប្រព្រឹត្តឡើងជាក្រុម ដោយមានមនុស្សជាច្រើនចូលរួមសកម្មភាព។ ក្នុងបទល្មើសដែលប្រព្រឹត្តបានសម្រេច គេឃើញមានអ្នកប្រព្រឹត្តនូវអំពើជាសម្ភារៈដោយផ្ទាល់ក្នុងឋានៈជា **ចារី សហចារី អ្នកផ្តើមគំនិត** ឬជា**អ្នកសមគំនិត**។ ប៉ុន្តែដោយសារ បទល្មើសជាក្រុមបានបង្កព្យសនកម្មយ៉ាងខ្លាំងដល់សង្គម ហេតុនេះហើយច្បាប់បញ្ញត្តការដាក់ **ទណ្ឌកម្មដោយឡែក** ទៅលើជនប្រព្រឹត្តជាក្រុមតាមវិធីសាស្ត្រពីរយ៉ាងគឺៈ

- សម្រាប់បទល្មើសខ្លះ ការប្រព្រឹត្តមានគ្នាច្រើនជាមូលហេតុនាំឱ្យស្ថានទម្ងន់ទោស។

ឧទាហរណ៍ដូចជា បទហិង្សាដោយចេតនា បទរំលោភសេពសន្ថវៈ បទលួច។

- ច្បាប់ព្រហ្មទណ្ឌ បានផ្តន្ទាទោសការរួបរួមជាក្រុម ក្នុងករណីមួយចំនួន បើទោះជាពុំទាន់មានសកម្មភាពល្មើសកើតឡើងក៏ដោយ។[១៣]

---

[១២] ក្រមព្រហ្មទណ្ឌ, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ២០០៩, មាត្រា (២៥, ២៧)

[១៣] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញៈ ២០១២), ទំព័រ ១៥៩

## ៣. ធាតុផ្សំអត្តនោម័ត

និយមន័យធាតុផ្សំអត្តនោម័ត គឺជាកិរិយាផ្នត់គំនិតខាងក្នុងរបស់ជនល្មើស ចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គម។ ឬក៏អាចនិយាយម្យ៉ាងទៀតថា **អំពើសត្យានុម័ត** ដែលឆ្លើយតបទៅនឹងបទល្មើសអាចនឹងត្រូវទទួលរងនូវការផ្តន្ទាទោសបាន លុះត្រាតែចារីបានធ្វើសកម្មភាពដោយមានឆន្ទៈ ឬដោយដឹងខ្លួនថាបានបំពានច្បាប់ព្រហ្មទណ្ឌ។ អំពើជាធាតុសត្យានុម័តតែមួយពុំគ្រប់គ្រាន់ដើម្បីបង្កើតបានជាបទល្មើសទេ។ ការកំណត់បទល្មើសតែងតែផ្អែកលើ កំហុសដែលកើតចេញពីចិត្តគំនិតរបស់ចារី។

ដូច្នេះ ដើម្បីបង្កើតឱ្យបានជាបទល្មើស ចារីត្រូវតែប្រព្រឹត្តអំពើដោយមានកំហុស។ កំហុសអាចផ្អែកលើឆន្ទៈដែលមានទិសដៅច្បាស់លាស់ដោយ សំដៅទៅរកគោលដៅខុសច្បាប់ណាមួយ ពោលគឺចារីពិតជាមានឆន្ទៈ និងដឹងពីលទ្ធផលខុសច្បាប់នៃអំពើរបស់ខ្លួនដែលគេហៅថា **កំហុសចេតនា**។ ក្នុងករណីខ្លះទៀត កំហុសសំដៅលើស្ថានភាពដែលមិនមានឆន្ទៈគ្រប់គ្រាន់ ឬការប្រុងប្រយ័ត្នគ្រប់គ្រាន់ ដើម្បីជៀសវាងនូវលទ្ធផលខុសច្បាប់ដែលគេហៅថា **កំហុសអចេតនា**។[១៤]

### ៣.១. កំហុសចេតនា

យោងតាមមាត្រា ៤ កថាខណ្ឌទី ១ នៃក្រមព្រហ្មទណ្ឌចែងថា ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ហេតុនេះ ចេតនាជាធាតុផ្សំអត្តនោម័តនៃបទល្មើស។ ចេតនាប្រព្រឹត្តបទល្មើស សំដៅដល់ឆន្ទៈឆ្ពោះទៅរកការប្រព្រឹត្តបទល្មើសដែលបានកំណត់ដោយច្បាប់។ មានចេតនានឹងប្រព្រឹត្តបទល្មើស កាលបើ **ចារីស្វែងរកលទ្ធផលខុសច្បាប់ពីអំពើរបស់ខ្លួន** និង**ចារីដឹងថាអំពើរបស់ខ្លួននឹងផ្តល់នូវលទ្ធផលខុសច្បាប់**។ ចេតនាប្រព្រឹត្តបទល្មើសត្រូវរួមផ្សំដោយ **ចេតនាសម្រេចបទល្មើស** និង**ចេតនាប្រព្រឹត្តអំពើ**។[១៥]

**ចេតនាសម្រេចបទល្មើស** សំដៅដល់ចេតនារបស់បុគ្គលម្នាក់ដែលមានសេរីភាព និងមនសិការគ្រប់គ្រាន់ក្នុងការស្វែងរកលទ្ធផលដែលច្បាប់ព្រហ្មទណ្ឌបានហាមឃាត់។ ហើយនៅតែមានបំណងប្រព្រឹត្តបទល្មើសដែលខុសច្បាប់ថែមទៀត។

**ចេតនាប្រព្រឹត្តអំពើ** ចារីត្រូវប្រព្រឹត្តអំពើដោយចេតនា បានន័យថាដោយដឹងច្បាស់ពីអំពើរបស់ខ្លួន។ ចេតនាប្រព្រឹត្តអំពើ ឬអាចហៅម្យ៉ាងទៀតថា ចេតនាទុច្ចរិតមានច្រើនប្រភេទ និងខុសប្លែកពីមូលហេតុនៃការប្រព្រឹត្តបទល្មើស។ ប្រភេទនៃចេតនាទុច្ចរិតរួមមាន ចេតនាទុច្ចរិតទូទៅ ចេតនាទុច្ចរិតពិសេស ចេតនាទុច្ចរិត ធ្ងន់ធ្ងរ ចេតនាទុច្ចរិតច្បាស់លាស់ ចេតនាទុច្ចរិតមិនច្បាស់លាស់ និងចេតនាទុច្ចរិតចំពោះចេតនាទុច្ចរិតមិនចំពោះ។

[១៤] រុន ពណ្ណារិទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ១៩៣
[១៥] ក្រមព្រហ្មទណ្ឌ, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៤

### ៣.២. កំហុសអចេតនា

កំហុសអចេតនា គឺជាកំហុសដែលកើតឡើងពីការមិនងាយគ្រប់គ្រងឆន្ទៈរបស់ខ្លួនឯងបាន មានន័យថា ចារីមានបំណងធ្វើសកម្មភាពរបស់ខ្លួន ក៏ប៉ុន្តែចារីពិតជាពុំមានឆន្ទៈ ឬពុំបានដឹងពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួនឡើយ។ សម្រាប់ករណីបទល្មើសអចេតនា ធាតុផ្សំអត្តនោម័ត គឺសំដៅដល់កំហុស អចេតនា ដែលពុំមែនជាចេតនាប្រព្រឹត្តបទល្មើសទេ តែចារីបានប្រព្រឹត្តខុសនឹងវិធានណាមួយដែលគ្រប់គ្រាន់បង្កើតបានជាបទល្មើស ។

តួយ៉ាងក្នុងមាត្រា ៤ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌបានចែងថា "ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកជាមុនបទល្មើសមួយអាចកើតចេញពី ការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយទ្បែកណាមួយ"។

### ៣.៣. ការវាយតម្លៃអំពីកំហុស

សម្រាប់ករណី បទលហុ ចារីត្រូវបានសន្មតថាមានកំហុស នៅពេលដែលធាតុផ្សំអត្តនោម័តនៃបទល្មើសមានគ្រប់គ្រាន់។ ដូច្នេះ ប្រសិនបើរកឃើញថា ចារីបានធ្វើអំពើផ្ទុយនឹងច្បាប់ដូចជា ការមិនគោរពភ្លើងសញ្ញាចរាចរណ៍ មានន័យថាចារីពិតជាបានប្រព្រឹត្តកំហុសហើយដែលហៅថា កំហុសលហុ ឬកំហុសជាសម្ភារៈ។ ហេតុនេះ អយ្យការពុំចាំបាច់ធ្វើការបង្ហាញភស្តុតាងពីកំហុសរបស់ចារីឡើយ ពីព្រោះគេសន្មតថាមានកំហុសនៅពេលដែលមានធាតុផ្សំសត្យានុម័តគ្រប់គ្រាន់រួចបាត់ទៅហើយ។

នៅក្នុងការវាយតម្លៃកំហុសរបស់ចារី ពោលគឺការវាយតម្លៃអំពីធាតុផ្សំអត្តនោម័តនៃបទល្មើស ចៅក្រមមានភារកិច្ចកំណត់អំពីស្ថានភាពស្មារតីរបស់ចារី នៅពេលប្រព្រឹត្តបទល្មើសទៅតាមរឿងក្តីនីមួយៗ ចារីអាចលើកឡើងពីការភាន់ច្រឡំរបស់ខ្លួនចំពោះបទល្មើសដោយចេតនា ឬការប្រុងប្រយ័ត្នជាធម្មតារបស់ខ្លួនចំពោះ បទល្មើសដោយអចេតនា ដើម្បីបញ្ជាក់ពីការអវត្តមាននៃធាតុផ្សំអត្តនោម័តនៃបទល្មើសដែលបានកើតឡើង។

ការភាន់ច្រឡំអាចជាការយល់ច្រឡំរបស់ជនល្មើសអំពីអត្ថន័យគតិយុត្តដែលហៅថា ការភាន់ច្រឡំពីច្បាប់ និងការយល់ច្រឡំអំពីស្ថានភាពជាក់ស្តែងនៃអំពើប្រព្រឹត្តរបស់ជនល្មើសដែលហៅថា **ការភាន់ច្រឡំពីអំពើឬអង្គហេតុ**។

ការភាន់ច្រឡំពីច្បាប់ សំដៅដល់ការភាន់ច្រឡំលើវិធានច្បាប់ណាមួយ ចារីមានការយល់ច្រឡំលើអត្ថន័យនៃវិធានច្បាប់។ ករណីនេះ អាចនិយាយឱ្យងាយថាចារីពុំបានដឹងខ្លួនថាបានប្រព្រឹត្តខុសច្បាប់ទេ ក៏ប៉ុន្តែចារីមានបំណងធ្វើអំពើនោះដោយចេតនា។ រីឯ ការភាន់ច្រឡំពីអំពើ សំដៅដល់ការយល់ច្រឡំពី ស្ថានភាព របស់បុគ្គលម្នាក់អំពីស្ថានភាពជាក់ស្តែងនៃអំពើរបស់ខ្លួន។ ការភាន់ច្រឡំនេះដែលនាំឱ្យបាត់នូវកំហុសរបស់ចារីត្រូវមានលក្ខខណ្ឌពីរ គឺការភាន់ច្រឡំលើធាតុផ្សំសំខាន់នៃបទល្មើស និងការភាន់ច្រឡំដែលមិនអាចជៀសវាងបាន ។[៦]

[៦] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ២០៨

## ផ្នែកទី ២ ៖ សញ្ញាណនៃជនល្មើស

តាមន័យទូទៅជនល្មើសមកពីពាក្យថា មនុស្សបូកនឹងពាក្យល្មើស ដែលមានន័យថាការប្រព្រឹត្តលើសរំលងច្បាប់។ តាមន័យច្បាប់ជនល្មើស គឺជាអ្នកដែដល់ ឬអ្នកសមគំនិតនៃបទល្មើសមួយ បានសេចក្តីថាគ្រប់អំពើទាំងអស់ដែលបានចែងហើយត្រូវផ្តន្ទាទោសដោយនីតិវិធីព្រហ្មទណ្ឌ និងអាចធ្វើជាកម្មវត្ថុនៃការចោទប្រកាន់ប្រព្រឹត្តបទល្មើសបាន ឬគេអាចនិយាយម្យ៉ាងទៀតថា ជនល្មើសជាជនទាំងឡាយណាដែលបានចូលរួមប្រព្រឹត្តដោយចេតនានូវឧក្រិដ្ឋកម្ម ទោសកម្មណាមួយដោយផ្ទាល់ក្តីដោយប្រយោលក្តី ជននោះត្រូវមានទោសដែលគេហៅថា **ចារី**។ អ្នកចូលរួមប្រព្រឹត្តដោយផ្ទាល់នោះ ហៅថា សហចារី។ ចំណែកការរួមប្រព្រឹត្តដោយប្រយោលគេហៅថា **អ្នកសមគំនិត** និង**អ្នកផ្តើមគំនិត**។

លក្ខខណ្ឌដែលអាចចាត់ទុកថាជាជនល្មើសបាន លុះត្រាតែជាមនុស្សកំពុងមានជីវិតរស់នៅមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ មានអាយុតាមការកំណត់របស់នីតិព្រហ្មទណ្ឌ។

សរុបមកយើងអាចឱ្យនិយមន័យនៃពាក្យ ជនល្មើស ជាជនដែលបានប្រព្រឹត្តអំពើដោយចេតនា ឬអចេតនាក្តីដោយសកម្ម ឬអកម្មក្តីដែលអំពើរបស់ជននោះបណ្តាលឱ្យមានព្យសនកម្មដល់សង្គម ហើយអំពើរបស់ជននោះត្រូវបានកំណត់ទុកជាមុននៅក្នុងច្បាប់ព្រហ្មទណ្ឌ។[១៧]

### ១. ចារី

មាត្រា ២៥ គឺមានចែងជានិយមន័យអំពីចារីដែលសំដៅទៅចំពោះបុគ្គលដែលប្រព្រឹត្តបទល្មើសដោយផ្ទាល់ក៏បានន័យថាជា អ្នកប្រព្រឹត្តទាំងអំពើជាសម្ភារៈ ឬជាអ្នកប្រព្រឹត្តអំពើទាំងអស់។ យើងហៅថាចារីដោយសារតែគាត់ជាអ្នកប្រព្រឹត្តបទល្មើសដែលទទួលរងការចោទប្រកាន់ដូចជា ជនម្នាក់ដោយគ្មានការចូលរួមពីអ្នកដទៃទេតែគាត់ម្នាក់ឯងគឺបានដកកាំបិតចាក់គេបណ្តាលឲ្យស្លាប់ អញ្ចឹងជននេះគេបានឱ្យឈ្មោះថាជា **ចារី**។ ក៏ប៉ុន្តែនៅក្នុងស្ថានភាពខ្លះ គឺថាបទល្មើសប្រព្រឹត្តដោយមានបុគ្គលច្រើនរូប បានន័យថាជនខ្លះចូលរួមក្នុងឋានៈជាសហចារី អ្នកខ្លះចូលរួមក្នុងឋានៈជាអ្នកផ្តើមគំនិត អ្នកខ្លះចូលរួមក្នុងឋានៈជា អ្នកសមគំនិត។[១៨]

ចារី ត្រូវបានគេចាត់ទុកថាជាអ្នកមានតួនាទីសំខាន់ ប្រសិនបើគ្មានអំពើល្មើសរបស់ចារីនេះទេ នោះក៏គ្មានបទល្មើសកើតឡើងដែរ។ ចារីប្រព្រឹត្តផ្ទាល់ ត្រូវបានគេបែងចែកចេញជាពីរបែបទៅតាមបទល្មើសប្រព្រឹត្តដោយ **សកម្ម ឬ អកម្ម**។ **ចារីក្នុងបទល្មើសសកម្ម** គឺចារីបានធ្វើសកម្មភាពស្តែងចេញជាកាយវិការប្រព្រឹត្ត ក្នុងបំណងចង់ឱ្យទទួលបានលទ្ធផលតាមរយៈអំពើរបស់ខ្លួន។ ឧទាហរណ៍ ដូចជាអ្នកយកកាំភ្លើងបាញ់ជនរងគ្រោះ ជនដែលចូលទៅលួចក្នុងផ្ទះណាមួយ ឬជនចូលទៅឆក់ទ្រព្យសម្បត្តិអ្នកដទៃជាដើម។ ក្នុងន័យនេះយើងមិនចាំបាច់គិតថាអំពើនេះត្រូវគ្រោង និងត្រូវសម្រេចដោយខ្លួនឯង ឬដោយគ្នាច្រើននោះទេ ល្គឹកណាជនល្មើសបានប្រព្រឹត្តដោយ

---

[១៧] សាស្ត្រាចារ្យ សេង នាង, នីតិព្រហ្មទណ្ឌទូទៅ, (តុលា, ២០០៤), ទំព័រ ៦៣

[១៨] កៅ សីហា, នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ ២០១៣), ទំព័រ២០៧

ខ្លួនឯង ច្បាប់ចាត់ទុកថាជាចារីប្រព្រឹត្តបទល្មើសហើយ។ **ចារីក្នុងបទល្មើសអកម្ម** ដែលមានជនល្មើសមានកាតព្វកិច្ចត្រូវបំពេញទោះបីជននេះពឹងឱ្យអ្នកដទៃបំពេញជំនួសខ្លួន តែជនទី២នេះមិនបានបំពេញ ក៏ជនទី១នៅតែជាចារីដែរ។

ឧទាហរណ៍៖ ឈ្មោះ ម៉ុក បានច្បាស់ថាឈ្មោះ ប៊ិត ជាឃាតករតែមិនបានប្តឹងបើកមុខឧក្រិដ្ឋជន។ ដូច្នេះ ម៉ុក គឺជាចារីប្រព្រឹត្តបទល្មើសអកម្មមិនប្តឹងបើកមុខជនឧក្រិដ្ឋ។

## ២. សហចារី

សហចារី ត្រូវចាត់ទុកថាជាសហចារីកាលណាបើមានបុគ្គលច្រើននាក់បានព្រមព្រៀងបង្កើតបទល្មើសរួមគ្នាដោយផ្ទាល់។ ក្រៅពីនេះ ត្រូវចាត់ទុកថាជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្ត បទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក។ យើងអាចនិយាយបានថា សហចារី គឺជាជនទាំងឡាយណាដែលបានចូលរួមប្រព្រឹត្តដោយផ្ទាល់ជាមួយនឹងជនណាម្នាក់ ឬច្រើននាក់ផ្សេងៗទៀត ដើម្បីធ្វើសកម្មភាពក្នុងការសម្រេចគោលបំណងអ្វីមួយ។ ដូចនេះសបញ្ជាក់ឲ្យឃើញថា សហចារី គឺចារីដែលមានច្រើនគ្នាក្នុងការប្រព្រឹត្តបទល្មើសណាមួយតែប៉ុណ្ណោះ។[១៩]

ឧទាហរណ៍៖ ឈ្មោះ ក និងឈ្មោះ ខ បានតាមដានឈ្មោះ គ ខណៈដែលជននោះកំពុងព្យាយាមលួចម៉ូតូរបស់ ក។ នៅពេលដែលលោក គ ចាប់ផ្តើមឡើងជិះម៉ូតូលោក ក និង ខ បានស្ទុះទៅវាយចាប់ទាត់ធាក់ហើយស្រែកថា "ចោរៗ"។ ឃើញបែបនេះឈ្មោះ ឃ, ង, និង ច បានរត់ចូលមកចោមរោមវាយថែមទៀត ដោយសារទ្រាំនឹងទម្ងន់វាយទាត់ធាក់របស់អ្នកទាំង៥រូបមិនបាន គ ក៏បានស្លាប់ទៅ។ ជនទាំង៥រូប ក ខ ឃ ង ច នឹងត្រូវមានទោសពីបទមនុស្សឃាតដោយចេតនាក្នុងឋានៈជាចារីដដល់ទាំងអស់ដែលគេហៅថាជា សហចារី។ ក៏ប៉ុន្តែ សហចារីពុំមែនត្រូវទទួលទោសស្មើៗគ្នានោះទេ គឺគេអនុវត្តតាមគោលការណ៍ឯកត្តកម្មនៃទោសបានន័យថា ការផ្តន្ទាទោសដោយយោងទៅតាមអំពើប្រព្រឹត្តរបស់បុគ្គលម្នាក់ៗ។[២០]

## ៣. អ្នកផ្តើមគំនិត

មាត្រា ២៨ នៃក្រមព្រហ្មទណ្ឌបានចែងថាត្រូវចាត់ទុកជា អ្នកផ្តើមគំនិត ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលដែល៖

១. ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ តាមការណែនាំ ឬ ការបញ្ជា។

២. បង្កឲ្យមានបទឧក្រិដ្ឋ ឬ បទបជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញង់ ការលួងលោម ឬ ក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន។

[១៩] ក្រមព្រហ្មទណ្ឌ, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ២០០៩, មាត្រា ២៦

[២០] សាស្ត្រាចារ្យ សេង នាង, នីតិព្រហ្មទណ្ឌទូទៅ, (តុលា, ២០០៤), ទំព័រ ៦៤

អ្នកផ្ដើមគំនិត នឹងអាចត្រូវផ្ដន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬ បទមជ្ឈិមត្រូវ បានសម្រេច ឬបានប៉ុនប៉ង ។ អ្នកផ្ដើមគំនិតនៃ បទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្ដន្ទាទោសដូចគ្នានឹងចារីដែរ។ នៅក្នុងស្ថានភាពនេះ បើយើងពិនិត្យទៅមានភាសាខ្លះបានចាត់ទុកអ្នកផ្ដើមគំនិត នេះជាចារីបញ្ញា បើនិយាយជារួមគឺ ជាអ្នកភ្ញង់ ផ្ដើមនូវគំនិតក្នុងការប្រព្រឹត្តបទល្មើស។ ពិសេសបុគ្គលម្នាក់គាត់គ្មានបំណងក្នុងការប្រព្រឹត្តបទល្មើសទេ ក៏ប៉ុន្តែឆ្លងទៅតាមរយៈអ្នកផ្ដើមគំនិតនេះ ពេលខ្លះបុគ្គលអ្នកផ្ដើមគំនិតនេះគឺជាអ្នកជម្រុញដូចជាបញ្ជាថាឲ្យបុគ្គលម្នាក់ទៅសម្លាប់អ្នកនេះ ឬក៏ណែនាំឲ្យទៅសម្លាប់អ្នកនោះ ឬក៏លួងលោមឲ្យបុគ្គលណាម្នាក់ទៅប្រព្រឹត្តបទល្មើសណាមួយ។ ដូច្នេះបុគ្គលដែលជាអ្នកភ្ញង់ផ្ដើមគំនិតប្រភេទនេះ ដើម្បីឲ្យគេប្រព្រឹត្តបទល្មើសគឺក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា ២៨ កំណត់ថាគាត់គឺជាអ្នកផ្ដើមគំនិត ។

**ឧទាហរណ៍៖** លោក **ក** បានបញ្ជាឱ្យលោក **ខ** ទៅឆបោក **គ** ដែលជាប្រជាពលរដ្ឋធម្មតា ដោយបានគំរាមកំហែង ថានឹងបញ្ឈប់ពីការងារ បើសិន **ខ** មិនធ្វើការបញ្ជា។ ក្នុងករណីនេះ លោក **ខ** ត្រូវបានគេចាត់ទុកថាជាចារី ដោយហេតុថាលោក **ខ** ជាចារី ឬជាអ្នកប្រព្រឹត្តបទល្មើសដោយផ្ទាល់។ ចំណែកឯលោក **ក** វិញ ត្រូវបានចាត់ទុកថាជាអ្នកផ្ដើមគំនិត ព្រោះថា បើគ្មានគំនិតផ្ដួចផ្ដើមពីលោក **ក** ទេ លោក **ខ** ក៏មិនទៅឆបោក **គ** ដែលជាជនរងគ្រោះដែរ។

### ៤. អ្នកសមគំនិត

បទល្មើសនីមួយៗ ជួនកាលបានកើតឡើងដោយសារការប្រព្រឹត្តដោយជនល្មើសតែម្នាក់ជួនកាលកើតឡើងដោយសារ ការរួមគ្នាប្រព្រឹត្តដែលជា សហចារី ហើយជួនកាលកើតឡើងដោយសារមានការចូលរួមពីជនល្មើសដែលជា អ្នកសមគំនិតផងដែរ។ យោងតាមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និយមន័យ នៃអ្នកសមគំនិតត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួល ដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្ដល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន ។

អ្នកសមគំនិត នឹងអាចត្រូវផ្ដន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្ដន្ទាទោសដូចគ្នានឹងចារីដែរ។ បើនិយាយជារួម គឺបានន័យថាគាត់បានចូលរួមចំណែកខ្លះនៅក្នុងបទល្មើស ប៉ុន្តែគាត់មិនមែនជាអ្នកដែលភ្ញង់ផ្ដើមគំនិតមុន ដំបូងគេនោះទេ ហើយក៏គាត់មិនបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់ផងដែរ។ នេះច្បាប់ឱ្យឈ្មោះថាជា អ្នកសមគំនិតដូចមានចែងក្នុងមាត្រា២៩។ ទោះបីជាអ្នកសមគំនិតមិនបានចូលរួមប្រព្រឹត្តដោយផ្ទាល់ក៏ដោយ ប៉ុន្តែអ្នកជុំគំនិតត្រូវទទួលទោសដូចចារីដែដល់ដែរ។ ដោយផ្អែកតាមគោលការណ៍នៃការផ្ទេរកំហុស និងទោសរបស់ជនដៃដល់មកលើអ្នកសមគំនិត។

**ឧទាហរណ៍៖** នៅក្នុងបទប្លន់(មាត្រា៣៥៧)មួយមានបុគ្គលពីរនាក់ មានឈ្មោះ **ក** និង**ខ** បានធ្វើសកម្មភាពប្លន់យកលុយ នៅឯផ្ទះរបស់លោក **គ**។ ដោយ **ក** បានប្រាប់ លោក **ខ**

ថានៅវេលាម៉ោង១២ថ្ងៃត្រង់រហូតដល់ម៉ោង ៥ល្ងាច លោក គ មិននៅផ្ទះ។ ហើយលោក ខ ក៏បានធ្វើសកម្មភាពប្លន់។

ក្នុងករណីនេះ ឈ្មោះ **ក** នឹងត្រូវបានចាត់ទុកជាអ្នកសមគំនិត ព្រោះថាសកម្មភាពបែបនេះ ជាអំពើដែលជួយផ្ដល់ព័ត៌មាន ឱ្យការប្រព្រឹត្តបទល្មើសបានសម្រេចប៉ុណ្ណោះ។ យ៉ាងណាមិញឈ្មោះ **ខ** គឺនៅតែជា ចារីដោយហេតុថាខ្លួនបានធ្វើសកម្មភាពប្លន់ផ្ទះ របស់លោក **គ** ដោយផ្ទាល់។

## ផ្នែកទី ៣ ៖ សញ្ញាណទូទៅនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

យោងតាមគោលការណ៍ឯកត្តកម្ម នៃការទទួលខុសត្រូវព្រហ្មទណ្ឌ បុគ្គលគ្រប់ៗរូបត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនដែលបានប្រព្រឹត្តប៉ុណ្ណោះ។ គោលការណ៍នេះត្រូវយកមកអនុវត្តន៍ នៅពេលដែលមានអំពើល្មើសកើតឡើង ហើយបុគ្គលដែលបានប្រព្រឹត្តត្រូវតែចូលខ្លួនមកទទួលខុសត្រូវព្រហ្មទណ្ឌតាមស្ថានភាពនៃបទល្មើសដែលខ្លួនប្រព្រឹត្ត។[២១] ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាកាតព្វកិច្ចដើម្បីឆ្លើយតបទៅនឹងអំពើប្រព្រឹត្តបទល្មើសទាំងឡាយ ដោយទទួលរងទណ្ឌកម្មព្រហ្មទណ្ឌ នៅក្នុងលក្ខខណ្ឌមួយចំនួន និងតាមរូបភាពនានាដែលចែងក្នុងក្នុងច្បាប់។[២២]

សរុបសេចក្ដីមក ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺមានន័យថារាល់អំពើល្មើសដែលបានប្រព្រឹត្តដោយបុគ្គលណាម្នាក់ បុគ្គលនោះត្រូវតែជាអ្នកដែលនឹងទទួលខុសត្រូវព្រហ្មទណ្ឌដោយផ្ទាល់។

### ១. ការទទួលខុសត្រូវរបស់រូបវន្តបុគ្គល

ការទទួលខុសត្រូវរបស់រូបវ័ន្តបុគ្គល គឺជាការទទួលខុសត្រូវទោសតាមរូបភាពណាមួយ ដោយសារអំពើខុសច្បាប់របស់មនុស្សម្នាក់ បណ្ដាលឱ្យប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ សុខភាព អាយុជីវិត និងទ្រព្យសម្បត្តិរបស់អ្នកដទៃដែលច្បាប់បានការពារ។

ការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាកាតព្វកិច្ចដើម្បីឆ្លើយតបនឹងអំពើប្រព្រឹត្តបទល្មើសទាំងឡាយដោយទទួលរងទណ្ឌកម្ម ដោយមានលក្ខខណ្ឌមួយចំនួន និងតាមរូបភាពនានាដែលមានចែងក្នុងក្រមព្រហ្ម ទណ្ឌ។ រូបវន្តបុគ្គល សំដៅដល់បុគ្គលដែលមានរូបពិត មានជីវិតពិត ដែលផ្ទុយនឹងនីតិបុគ្គល។ ពីព្រោះថារូបវន្តបុគ្គលដែលប្រព្រឹត្តអំពើណាមួយ គឺត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់គាត់។ ការប្រព្រឹត្ត បទល្មើសដោយរូបវន្តបុគ្គលទាំងអស់មិនមែនសុទ្ធតែត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌដូចគ្នានោះទេខាង ព្រហ្មទណ្ឌតែម្ដងរូបវន្តបុគ្គលខ្លះត្រូវទទួលខុសត្រូវទាំងស្រុង ខ្លះទទួលខុសត្រូវមួយផ្នែកហើយខ្លះទៀត មិនទទួលខុសត្រូវ។ ការកម្រិតអំពីការទទួលខុសត្រូវនេះគឺ ដោយផ្អែកទៅលើអាយុដើម្បីកំណត់អំពីសមត្ថភាព នៃការយល់ដឹងរបស់ជនប្រព្រឹត្តដែលត្រូវបានកំណត់ដោយច្បាប់ថា តើជនប្រព្រឹត្តមានអាយុប៉ុន្មាន? ដែល ច្បាប់ចាត់ទុកថាជានីតិជន

[២១] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ២៤

[២២] សាស្ត្រាចារ្យ ហ៊ាងឡេង, នីតិព្រហ្មទណ្ឌទូទៅ, ទំព័រទី ៦៣

ដែលត្រូវទទួលខុសត្រូវពេញលេញ ហើយអាយុប៉ុន្មានដែលច្បាប់ចាត់ទុកជា អនីតិជន ត្រូវទទួលខុសត្រូវមួយផ្នែក ឬមិនតម្រូវឱ្យទទួលខុសត្រូវនោះ។ ប៉ុន្តែនៅក្នុងនេះ យើងត្រូវជ្រាបថា រូបវន្តបុគ្គល គឺត្រូវចែកចេញជា ២ប្រភេទ គឺ រូបវន្តបុគ្គលជានីតិជន និង រូបវន្តបុគ្គលជាអនីតិជន។ ហើយ រូបវន្តបុគ្គលជាអនីតិជនច្បាប់បានធ្វើការចែកជា២ ទៀត គឺ អនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ទៅដល់ក្រោម ១៨ឆ្នាំ និងអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ។

### ១.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន

នីតិជន ជាជនពេញវ័យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត។ នីតជនត្រូវបានកំណត់ចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ។ មានន័យថាបើជនណាដែលមានអាយុចាប់ពី ១៨ឆ្នាំ ឡើងទៅបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ជននោះនឹងត្រូវទទួលទោសមួយពេញលេញទៅតាមការ ដាក់ទណ្ឌកម្មដែលច្បាប់ព្រហ្មទណ្ឌបានកំណត់។ នីតិជន សំដៅដល់ជនដែលមានអាយុចាប់ពី១៨ ឆ្នាំឡើងទៅ គឺថាបុគ្គលនេះត្រូវទទួលខុសត្រូវ ព្រហ្មទណ្ឌយ៉ាងពេញលេញតែម្តង ពីព្រោះថានៅក្នុងក្រមព្រហ្មទណ្ឌ គឺបាន ចែងនៅក្នុងមាត្រា ៣៨ អំពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ "នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី១៨ (ដប់ប្រាំបីរ) ឆ្នាំ ឡើងទៅ។ ដូចនេះមានន័យថា ជនដែលមានអាយុចាប់ពី ១៨ ឆ្នាំហើយបានប្រព្រឹត្តបទល្មើសណាមួយគឺ ត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនយ៉ាងពេញលេញ។

### ១.២. ការទទួលខុសត្រូវរបស់អនីតិជន

#### ក. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ របស់អនីតិជន

តាមច្បាប់ជាទូទៅអនីតិជន មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ កាលណាបើអនីតិជនប្រព្រឹត្ត បទល្មើសអ្វីមួយ គឺជាកម្មវត្ថុនៃវិធានការអប់រំ វិធានការពារ និងវិធានការឧបត្ថម្ភ។ នីតិភាពនៃការទទួលខុសត្រូវ ព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពីអាយុ១៨ឆ្នាំឡើងទៅ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើ អនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃអនីតិជននោះ តម្រូវលើកលែង តែករណីមានចែងពិសេសក្នុងនៅក្នុងច្បាប់ផ្សេងទៀត។[២៣]

#### ខ. ការកំណត់អាយុរបស់អនីតិជន

អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវកំណត់យកអាយុ នៅពេលដែលអនីតិជន នោះប្រព្រឹត្តបទល្មើស។ ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារ ផ្សេងទៀតដែលអាចបញ្ជាក់អំពីកំណើត។ ក្នុងករណី ពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់ លាស់ទាក់ទងទៅនឹង យថាភូតនឹងឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជន អាចផ្តល់តាមគ្រប់ មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចទុកចិត្តបាន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុ តាង

[២៣] ច្បាប់ស្តីពីយុត្តិធម៌នីតិជន, ព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩, ចុះថ្ងៃទី ១៤ កក្កដា ២០១៦, មាត្រា ៧

ដើម្បីកំណត់អាយុរបស់អនីតិជនឱ្យបានឆាប់រហ័សបំផុតដែលអាចធ្វើបាន។ ករណីដែលមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់អនីតិជននោះ។

### គ. អនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ

អនីតិជនដែលមាន អាយុក្រោម១៨ នៅពេលដែលប្រព្រឹត្តបទល្មើស គឺគាត់នៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ក៏ប៉ុន្តែការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ គឺតុលាការត្រូវថ្លឹងថ្លែងពាក់ព័ន្ធទៅជាមួយនឹងកាលៈទេសៈនៃបទល្មើសដែលគាត់បាន ប្រព្រឹត្តបុគ្គលិកលក្ខណៈរបស់បុគ្គលនេះ។ ដោយសារតែអនីតិជន វិធានការនៅក្នុង ការដាក់ទណ្ឌកម្ម គឺក្នុងគោលដៅ ធ្វើការតាមដាន ឬក៏អប់រំ ឬក៏វិធានការការពារ ឬមួយវិធានការឧបត្ថម្ភផ្សេងៗដល់គាត់។ អញ្ចឹង គឺថាទាក់ទងជាមួយនឹងការទទួលខុសត្រូវរបស់អនីតិជន ដែលមានអាយុពី ១៤ឆ្នាំ ទៅដល់អាយុក្រោម ១៨ឆ្នាំ គឺនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល គ្រាន់តែស្ថានភាពដែលថាទទួលឲ្យដូចនីតិជនតែម្តងគឺ មិនដូចទេ ព្រោះមាន កម្រិតស្រាលជាង។

### ឃ. អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ

អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំគឺ ច្បាប់បានកំណត់ថាមិនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេមានន័យថានៅពេលដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមិនតម្រូវឱ្យទទួលខុសត្រូវទេ។ ព្រោះថា ការកំណត់កម្រិតអាយុណាមួយថាឱ្យមានការទទួលខុសត្រូវ ដោយផ្អែកលើកត្តាមួយយ៉ាងសំខាន់ គឺកត្តាចិត្តសាស្ត្រ។ ការសិក្សាអំពីចិត្តសាស្ត្រនេះដែរ បានឱ្យដឹងថា មនុស្សដែលមានអាយុក្រោម ១៤ឆ្នាំ គឺមិនទាន់មានស្មារតីត្រិះរិះពិចារណាលើផលដែលនឹងកើតឡើងដោយសារអំពើដែលខ្លួនបានប្រព្រឹត្តនោះទេ។ នៅក្នុងករណីដែលតុលាការរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម១៤ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការសម្រេចចិត្តឱ្យរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឱ្យដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ ទោះបីជាមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឱ្យទៅអ្នកតំណាងដែលច្បាប់បានកំណត់។ ហើយតុលាការ ត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណីប្រសិនបើមានបណ្តឹងរដ្ឋប្បវេណី។

## ២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គល គឺសំដៅលើក្រុមមនុស្សដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិនិងកាតព្វកិច្ច។ ដូច្នេះនីតិបុគ្គលចាំបាច់ត្រូវតែ មានការទទួលស្គាល់ដោយច្បាប់ ដោយមានបញ្ជាក់នូវ អត្តសញ្ញាណច្បាស់លាស់ដូចជាឈ្មោះ សញ្ជាតិ អាស័យដ្ឋាន កាលបរិច្ឆេទនៃការកកើតនិងលក្ខន្តិកៈនៃនីតិបុគ្គលនោះជាដើម។ នីតិបុគ្គលត្រូវបែងចែកជា ២ ដែលមានដូចជា នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលឯកជន។ ឧទាហរណ៍ នីតិបុគ្គលឯកជនមានដូចជា ក្រុមហ៊ុន សហគ្រាស សមាគម សហជីព រីឯ នីតិបុគ្គលសាធារណៈ វិញមានដូចជា ក្រសួង មន្ទីរ អង្គភាព ដែលជាស្ថាប័នរដ្ឋ។ ជាទូទៅនីតិបុគ្គលមានពីរប្រភេទគឺ នីតិបុគ្គលសាជីវកម្ម និងនីតិបុគ្គលមូលនិធិ។ នីតិបុគ្គលសាជីវកម្ម ជាក្រុមដែលមានសមាជិក ហើយត្រូវបានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចដោយ

ឯករាជ្យ។ នីតិបុគ្គលមូលនិធិ ជាចំណែកទ្រព្យសម្បត្តិវិភាគទានដែលត្រូវបាន ប្រគល់នូវឋានៈជាប្រធានសិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នីតិបុគ្គល គឺមិនលើកលែងនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ក្នុងអំពើដដែលនោះទេ។ មិនត្រឹមតែក្រមព្រហ្មទណ្ឌ ដែលបានកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ក៏មានការកំណត់អំពីការទទួលខុសត្រូវនៅក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងៗទៀតដែរ។ នីតិបុគ្គល គឺមិនត្រឹមតែទទួលទោសទណ្ឌកម្មដូចដែលមានចែង ក្នុងក្រមព្រហ្មទណ្ឌនោះទេ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ក៏ចែងពីការដាក់ទោសនីតិបុគ្គលដែរ។ នៅពេលក្រុមហ៊ុនមួយផ្តល់សិទ្ធិឲ្យតំណាងរបស់ខ្លួនឬបុគ្គលដឹកជញ្ជូននូវទំនិញដែលជាផលប្រយោជន៍របស់ខ្លួន ហើយបុគ្គលជាអ្នក បើកបរធ្វេសប្រហែសខ្ជីខ្ជា មិនប្រុងប្រយ័ត្ន មិនគោរពច្បាប់ បណ្តាលឲ្យអ្នកដទៃរបួស ឬ អសមត្ថភាពប្រកបការងារ ឬបណ្តាលឲ្យស្លាប់ ក៏ត្រូវទទួលទោសទណ្ឌកម្មដែរ។

### ២.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល បានចែងថានៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេង នីតិបុគ្គល លើកលែងតែរដ្ឋអាចត្រូវ បានប្រកាសថាត្រូវទទួលខុសត្រូវ ព្រហ្មទណ្ឌពីបទល្មើស ដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់ នីតិបុគ្គលនោះ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវ ការទទួលខុសត្រូវព្រហ្ម ទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ។ នីតិបុគ្គលត្រូវទទួលខុសត្រូវ ព្រហ្មទណ្ឌ កាលណាបើមាន៣ចំណុចគឺ អត្ថិភាពនៃច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត បទល្មើសប្រព្រឹត្តដោយ អង្គការ ឬអ្នកតំណាងនីតិបុគ្គល និង ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គល។[២៤]

#### ក. អត្ថិភាពនៃច្បាប់ឬ លិខិតបទដ្ឋានគតិយុត្ត

នីតិបុគ្គលត្រូវទទួលខុសត្រូវ ព្រហ្មទណ្ឌ កាលបើច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានចែងយ៉ាងច្បាស់ថា នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌចំពោះ បទល្មើសណាមួយជាកំណត់។ បទឃាតកម្ម គឺក្រមព្រហ្មទណ្ឌមិនបានចែងពីការទទួលខុសត្រូវ ព្រហ្មទណ្ឌរបស់នីតិ បុគ្គលទេ មានន័យថា នីតិបុគ្គលមិនអាចត្រូវបានប្រកាសថា ទទួលខុសត្រូវ ព្រហ្មទណ្ឌពីបទឃាតកម្មបាន ឡើយ។[២៥]

#### ខ. បទល្មើសប្រព្រឹត្តដោយអង្គការ ឬ អ្នកតំណាងនីតិបុគ្គល

នីតិបុគ្គល គឺជាបុគ្គលដែលកើតឡើងពីការសន្មតរបស់ច្បាប់។ នីតិបុគ្គលរមែងមានអង្គការ តំណាងក្រោមរូបភាពជាក្រុមប្រឹក្សា ឬអ្នកតំណាងរូបវន្តបុគ្គល ដែលធ្វើសកម្មភាពតំណាងឲ្យនីតិ បុគ្គលជានិច្ច។ អង្គការតំណាង ឬ អ្នកតំណាងនៃនីតិបុគ្គលគឺជា ជន ឬអង្គការដែលច្បាប់ ឬលក្ខន្តិកៈ ផ្តល់នូវមុខងារ

[២៤] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រម លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៤២

[២៥] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ២២៤

ជាអ្នកដឹកនាំគ្រប់គ្រង ហើយមាននីតិសម្បទា គ្រប់គ្រាន់ក្នុងការសម្រេចសេចក្តីដែលអាចធ្វើឲ្យនីតិបុគ្គលទទួលខុសត្រូវ ឬអាចនិយាយម្យ៉ាងគឺ ជាអង្គការ ឬជាអ្នកតំណាងដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រព្រឹត្តអំពើណាមួយក្នុងនាមនីតិបុគ្គល។[២៦]

### គ. ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គល

ការប្រព្រឹត្តបទល្មើស ដើម្បីបានជាប្រយោជន៍ ខាងផ្នែកសេដ្ឋកិច្ច ដល់នីតិបុគ្គលតែប៉ុណ្ណោះ ដែលជាកត្តានាំឱ្យនីតិបុគ្គល ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ប្រយោជន៍ សំដៅលើផលប្រយោជន៍ ខាងសេដ្ឋកិច្ចដែលមានលក្ខណៈច្បាស់លាស់ ឬគ្រាន់តែមានលក្ខណៈជាយថាហេតុក៏បានដែរ។ ក៏ប៉ុន្តែ បទល្មើសដែលប្រព្រឹត្តដោយអ្នកតំណាងរបស់នីតិបុគ្គល ប្រសិនបើ ធ្វើឡើងក្នុងផលប្រយោជន៍ផ្ទាល់ ខ្លួនរបស់អ្នកតំណាង មិនអាចឲ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។[២៧]

## ២.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលសាធារណៈ

សំដៅទៅលើ មន្ទីរ ក្រសួង ស្ថាប័ន អគ្គនាយកដ្ឋាន នានា ជាដើម ។ល។ បើទោះបីជាជនណាម្នាក់ដែលទៅប្រព្រឹត្តបទល្មើស ដើម្បីយកផលប្រយោជន៍ឱ្យទៅដល់ស្ថាប័ន សាធារណៈនេះក៏ដោយ នីតិបុគ្គលសាធារណៈ មិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ គឺមានតែរូបវន្តបុគ្គល ដែលប្រព្រឹត្តបទល្មើសនោះទេដែលត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌ ។

### ក. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះនីតិបុគ្គលសាធារណៈ

ចំពោះការពាក់ពន្ធ័ទៅនឹងបញ្ហាស្តីពី "រដ្ឋ" គឺច្បាប់បានកំណត់យ៉ាងជាក់លាក់ នៅក្នុងមាត្រា ៤២ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលថា នៅក្នុងករណីដែលមានការចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលលើកលែងតែរដ្ឋចេញ។ ដូច្នេះ រដ្ឋជានីតិបុគ្គលមួយដែលច្បាប់មិនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ ពីព្រោះថាច្បាប់ព្រហ្មទណ្ឌនៅក្នុងទោសបន្ថែម គឺអាចរំលាយនីតិបុគ្គលមួយចោលបាន។ ដូចនេះបើសិនជា ឲ្យរំលាយនីតិបុគ្គលដែលជារដ្ឋ ឬប្រទេសមួយចោលបាន ដូចជាប្រទេសកម្ពុជាយើងជាដើមពេលនោះនឹងប៉ះពាល់ ដល់អធិបតេយ្យជាតិ ដែលបានការពារដោយរដ្ឋធម្មនុញ្ញជាក់ជាមិនខានឡើយ។ ចំណែកឯនៅក្នុងមូលទោស វិញនោះ គឺមានទោសមួយប្រភេទហៅថាទោសពិន័យជាប្រាក់ ហើយរាល់ទោសពិន័យជាប្រាក់សុទ្ធ តែត្រូវបង់ចូលថវិការដ្ឋ (មាត្រា ៥២)។ ចុះសួរថា បើឲ្យរដ្ឋទទួលខុសត្រូវ ព្រហ្មទណ្ឌ ឬមួយត្រូវពិន័យជាប្រាក់ចំពោះរដ្ឋ តើនឹង មានរឿងចម្លែកអ្វីកើតឡើង? អញ្ចឹងហើយបានជារដ្ឋមិន ទទួលខុសត្រូវទេ ។

---

[២៦] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ២២៥

[២៧] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ២២៦

## ២.៣. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលឯកជន

សំដៅទៅលើរោងចក្រ សហគ្រាស សមាគមន៍ សហជីព ក្រុមហ៊ុន នានាដែលជារបស់ឯកជន។ បើនីតិបុគ្គលនេះស្វែងរកប្រាក់ចំណេញ គេហៅថា ក្រុមហ៊ុន។ ហើយប្រសិនបើ នីតិបុគ្គលមិនស្វែងរកប្រាក់ចំណេញទេ គេហៅថា សមាគមន៍ សហជីព។

ប្រធានក្រុមហ៊ុន ឬប្រធានសហគ្រាសនោះបានទៅប្រព្រឹត្តបទល្មើសណាមួយដែលជាផលប្រយោជន៍ដល់នីតិបុគ្គលឯកជននោះ ឬក៏ជាផលប្រយោជន៍របស់ខ្លួនផ្ទាល់។ ដូច្នេះ សហគ្រិននោះត្រូវតែទទួលខុសត្រូវ ព្រហ្មទណ្ឌរួមទាំងនីតិបុគ្គលនោះ ក៏ត្រូវទទួលខុសត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ឯនីតិបុគ្គលឯកជនវិញ ដើម្បីអាចទទួលខុសត្រូវព្រហ្មទណ្ឌ គឺទាល់តែចូលទៅក្នុងលក្ខខណ្ឌដែលថានីតិបុគ្គលនេះបានប្រព្រឹត្តបទល្មើសណាមួយដោយធ្វើតាមរយៈតំណាងរបស់គាត់ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល គឺមិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេយោងមាត្រា ១៨ នៃក្រមព្រហ្មទណ្ឌថ្មី។ នៅក្នុងក្រមព្រហ្មទណ្ឌថ្មីនេះ គឺយើងបានចែងចំណុចពាក់ព័ន្ធទៅ នឹងបទល្មើសមួយៗ នោះដោយកំណត់ថា តើបទល្មើសណាខ្លះដែលនីតិបុគ្គលត្រូវទទួលខុសត្រូវ? ផ្ទុយទៅវិញ បើសិនជាបទល្មើសណាមួយមិនមានចែងឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌទេ គឺមិនត្រូវដាក់ទណ្ឌកម្ម ឬទោសព្រហ្មទណ្ឌលើនីតិបុគ្គលនោះទេ នេះគឺជាលក្ខខណ្ឌចាំបាច់ដែលត្រូវតែមានចែងនៅក្នុងច្បាប់យ៉ាងជាក់លាក់តែម្តង។

# ជំពូកទី ២

# ការមិនទទួលខុសត្រូវ ឬការសម្រាលទោស ព្រហ្មទណ្ឌ

# ជំពូកទី ២

# ការមិនទទួលខុសត្រូវឬការសម្រាលទោស

ដើម្បីឲ្យយល់កាន់តែច្បាស់ពីការទទួលខុសត្រូវព្រហ្មទណ្ឌ យើងគប្បីស្វែងយល់ពី ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាការរួចផុតពីការទទួលទោសព្រហ្មទណ្ឌ នៅពេលដែលបុគ្គលណាម្នាក់ប្រព្រឹត្តអំពើល្មើស។ មូលហេតុដែលនាំឲ្យគេចផុតពី ការទទួលខុសត្រូវព្រហ្មទណ្ឌដោយសារមូលហេតុអត្តនោម័ត និង មូលហេតុស្ដីពីអំពើយុត្តិកម្ម។

## ផ្នែកទី ១ ៖ មូលហេតុអត្តនោម័ត

អត្តនោម័ត សំដៅដល់ការយល់ឃើញ ការគិត ឬកិរិយាផ្លូវចិត្តរបស់បុគ្គលណាម្នាក់។ បើយើងក្រឡេកមើលទៅលើរឿងក្ដីព្រហ្មទណ្ឌ ដើម្បីសម្រេចថាបុគ្គលណាម្នាក់នឹងត្រូវផ្ដន្ទាទោស យើងត្រូវសិក្សាពីចិត្តគំនិត ឬផ្លូវចិត្ត និងគោលបំណងនៃការប្រព្រឹត្តអំពើនោះ ដើម្បីសម្រេចថាបុគ្គលនោះ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ឬមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

### ១. មូលហេតុវិបល្លាសស្មារតី

វិបល្លាស មានន័យថា ការផ្លាស់ប្រែ ការដំណើរប្រែប្រួល ឬវិបរិត ការបំប្លែង ការក្រឡះ និងការភ្លាត់ខុស បើយោងតាមវចនានុក្រម ព្រះសង្ឃរាជជួនណាត។ យើងអាចទាញបានថា វិបល្លាសស្មារតីសំដៅដល់ការមានវិបត្តិស្មារតី ឬការប្រែប្រួលស្មារតីពីមនុស្សទូទៅ ដែលទាក់ទងទៅនឹងសរសៃប្រសាទនៃប្រព័ន្ធខួរក្បាល។ វិបល្លាសស្មារតីអាចកើតឡើងដោយសារជំងឺរបស់បុគ្គល ឬគ្រោះថ្នាក់ផ្សេងៗដែលបង្កផលប៉ះពាល់ដល់ប្រព័ន្ធខួរក្បាលរបស់បុគ្គល។ នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យ៉ាងជាក់ច្បាស់នៅក្នុងមាត្រា ៣១ ថា៖

- កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាស ស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។
- កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះ កើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលទោសព្រហ្មទណ្ឌដដែល។ ប៉ុន្តែតុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស។
- កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយការប្រើ ប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ឡើយ។[២៨]

[២៨] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រម លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៣១

### ២. អានុភាពនៃកម្លាំង ឬ ការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំង និងការបង្ខំ នេះត្រូវតែមិនអាចឃើញជាមុនបាន និងមិនអាចជៀសវាងបាន។[២៩] មានន័យថា រាល់បុគ្គលដែលបានត្រូវបានទទួលការប្រើប្រាស់ កម្លាំង ឬ ការបង្ខំពីសំណាក់ជនណាម្នាក់ឲ្យប្រព្រឹត្តអំពើដែលផ្ទុយនឹងច្បាប់បុគ្គលនោះពុំបានទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ប៉ុន្តែ បុគ្គលដែលបាន ប្រើប្រាស់កម្លាំង និងបង្ខំជនណាម្នាក់ឲ្យប្រព្រឹត្តបទល្មើសនោះទេ ទើបជាជនដែលនឹងត្រូវបានផ្តន្ទាទោសតាមច្បាប់។

ប្រភេទនៃកម្លាំង ឬ ការបង្ខំមានពីរប្រភេទគឺ **ការបង្ខំលើរូបកាយ** និង**ការបង្ខំលើផ្លូវចិត្ត៖**

**ការបង្ខំលើរូបកាយ** សំដៅទៅលើវត្តមាននៃកម្លាំងណាមួយលើរូបកាយរបស់ចារី ដែលជាហេតុធ្វើឲ្យចារីត្រូវតែប្រព្រឹត្តអំពើ ដោយខ្លួនពុំអាចឃាត់ឃាំងអំពើនោះបាន។ កម្លាំងបង្ខំលើរូបកាយអាចជា **កម្លាំងបង្ខំមកពីខាងក្រៅ** (កម្លាំងមកពីព្រឹត្តិការណ៍ធម្មជាតិ មកពីសត្វ ឬមកពីតតិយជន) និង **កម្លាំងបង្ខំមកពីស្ថានភាពខាងក្នុងរបស់ចារី** (ការភ្លាំងភ្លាត់មកពីសុខភាពខាងក្នុងរបស់ចារីក្នុងពេលកើតហេតុ ដែលហេតុនោះមិនបានកើតឡើងដោយចេតនា)។

**ការបង្ខំលើផ្លូវចិត្ត** សំដៅកម្លាំងដែលបង្ខំឆន្ទៈរបស់ចារីឲ្យប្រព្រឹត្តបទល្មើស ហើយព្រឹត្តិការណ៍ក្រៅឆន្ទៈនោះចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ពោលជាការគាបសង្កត់ឲ្យចារីប្រព្រឹត្តបទល្មើសមិនអាចជៀសបាន។[៣០]

## ផ្នែកទី ២ ៖ មូលហេតុស្តីពីអំពើយុត្តិកម្ម

អំពើយុត្តិកម្ម ឬអំពើសន្យានុម័ត សំដៅដល់ការប្រព្រឹត្តអំពើដែលត្រូវផ្តន្ទាទោសតាមច្បាប់ ប៉ុន្តែបែរជាត្រូវចាត់ថាត្រឹមត្រូវទៅវិញ នៅពេលដែលការប្រព្រឹត្តអំពើនោះ បង្ហាញពីការបំពេញកាតព្វកិច្ច ឬអនុវត្តសិទ្ធិ បានសេចក្តីថាអំពើនោះ បានកើតឡើងដោយសារតែផលប្រយោជន៍ស្របច្បាប់។ ហើយផលប្រយោជន៍នៃ ការប្រព្រឹត្តអំពើនេះមានសារៈសំខាន់ជាង ការចាត់ទុកអំពើនោះជាបទល្មើស ព្រោះថាអំពើនេះផ្តល់ផល ប្រយោជន៍សង្គម។[៣១]

### ១. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់ បុគ្គល នោះមិនប្រព្រឹត្ត បទល្មើសទេ។ បុគ្គលណាដែលបានប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើស ទេ លើកលែងតែអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។

---

[២៩] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រម លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៣៦

[៣០] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ២៤៣ ដល់ ២៤៥

[៣១] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ២៤៨

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ៖

១. ជនល្មើសនោះ បានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ដោយ**ច្បាប់**ជាធរមាន។ ក្នុងករណីដែលច្បាប់បញ្ញត្ត ឬអនុញ្ញាតឲ្យប្រព្រឹត្តអំពើល្មើសណាមួយហើយច្បាប់មិនបានបញ្ញតឲ្យផ្តន្ទាទោស លើអំពើដែលកើតចេញពីការបំពេញកាតព្វកិច្ចតម្រូវដោយច្បាប់។

ឧទាហរណ៍៖ ការអនុវត្តនីតិវិធីដោយចូលខ្លួនក្នុងសកម្មភាពល្មើសដើម្បីចាប់ជនល្មើសដូចជា ភ្នាក់ងារសម្ងាត់ក្លែងខ្លួនជាអ្នកទិញគ្រឿងញៀន ដើម្បីចាប់អ្នកជួញដូរគ្រឿងញៀន។

២. បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់**អាជ្ញាធរ**ស្របច្បាប់។ អាជ្ញាធរស្របច្បាប់ សំដៅលើអាជ្ញាធរសាធារណៈដែលជាអាជ្ញាធរតុលាការ ឬអាជ្ញាធរយោធា ដែលមានអំណាចតាមផ្លូវច្បាប់ក្នុងការបញ្ជាឲ្យអនុវត្តច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ។[៣២]

## ២. ការការពារស្របច្បាប់ ឬការការពារធម្មានរូប

បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ចំពោះការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ៖

- បទល្មើស ត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ការពារខ្លួន ការពារអ្នកដទៃ ឬការការពារ ទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។
- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នានឹង
- គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។[៣៣]

## ៣. សច្ចធារណ៍នៃការការពារស្របច្បាប់

បទល្មើសដែលត្រូវបានសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ៖

១. បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរញ្ជៀប្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។

២. បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា។ សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ។ សច្ចធារណ៍នេះអាចត្រូវរំលាយដោយភស្តុតាងផ្ទុយ។[៣៤]

[៣២] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រម លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៣២
[៣៣] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រម លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៣៣
[៣៤] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រម លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៣៤

### ៤. ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្ត មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ៖

- បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។
- គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។[៣៥]

[៣៥] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រម លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៣៥

# ជំពូកទី ៣
# ការអនុវត្តទោស
# ព្រហ្មទណ្ឌ

# ជំពូកទី ៣
# ការអនុវត្តទោសព្រហ្មទណ្ឌ

## ផ្នែកទី ១ ៖ សញ្ញាណនៃទោស

ទោស គឺជាទណ្ឌកម្មដែលកំណត់ដោយសង្គម ទៅលើចារីដែលប្រព្រឹត្តបទល្មើសដោយផ្អែកលើច្បាប់។ ទោសត្រូវបានគេបែងចែកដាច់ស្រឡះពី សំណងរដ្ឋប្បវេណី និងដាច់ស្រឡះ ពីទណ្ឌកម្មវិន័យ។ គោលការណ៍នៃការបែងចែកនេះ បានបញ្ជាក់យ៉ាងច្បាស់លាស់ថា ទោសត្រូវបានគេប្រើប្រាស់ក្នុងនាមសង្គម និងដើម្បីការពារផលប្រយោជន៍ សាធារណៈ គឺបម្រើផលប្រយោជន៍ ដល់សង្គមទាំងមូល។ ចំណែកឯ សំណងរដ្ឋប្បវេណី ក៏ដូចជាទណ្ឌកម្មវិន័យ គឺសំដៅការពារផលប្រយោជន៍របស់ក្រុមណាមួយ ទោះបីក្រុមនោះជាបុគ្គលក្តី ឬជាសមូហភាពក្តី។[៣៦]

ដូច្នេះ ទោស គឺជាវិធានបង្ក្រាបយ៉ាងតឹងរ៉ឹងបំផុតរបស់រដ្ឋដែលត្រូវបានបញ្ញត្តហើយជាការស្រេចនៅ ក្នុងច្បាប់ព្រហ្មទណ្ឌ ពោលគឺអាស្រ័យដោយអង្គការតុលាការជាអ្នកសម្រេចផ្តន្ទាទោសជនល្មើស។

### ១. គោលបំណងនៃទោសព្រហ្មទណ្ឌ

ការដាក់ទោសទៅលើជនល្មើសនេះ ក្នុងគោលបំណងពុំមែនត្រឹមតែបង្ក្រាបជនល្មើសតែប៉ុណ្ណោះទេ គឺនៅមានគោលបំណងអប់រំ កែប្រែបុគ្គលទាំងនោះ ឱ្យក្លាយទៅជាមនុស្សមាន ផលប្រយោជន៍សម្រាប់ច្បាប់ ឱ្យបានត្រឹមត្រូវ និងរាំងស្កាត់បទល្មើសថ្មីៗមិនឱ្យកើតមានឡើង។

#### ១.១. គោលបំណងនៃការធ្វើឱ្យរួញរា ឬគោលបំណងនៃការការពារទុកជាមុន

ការដាក់ទោសធ្វើឱ្យសម្រេចទិសដៅពីរយ៉ាង គឺធ្វើឱ្យរួញរាចំពោះបុគ្គលណាមួយ (ការភ័យខ្លាចចំពោះការទទួលទោសជាមូលហេតុធ្វើឱ្យគេបញ្ឈប់ការប្រព្រឹត្តបទល្មើសពាក់កណ្តាលទីបាន) និង ធ្វើឱ្យរួញរាជាទូទៅ (ដូចជាជនប្រព្រឹត្តបទល្មើសដែលត្រូវបានគេដាក់ទោសនោះគឺជាឧទាហរណ៍សម្រាប់ឱ្យអ្នកដទៃទៀតធ្វើការពិចារណាឱ្យបានវែងឆ្ងាយ មុននឹងប្រព្រឹត្តបទល្មើសជាយថាហេតុ)។

#### ១.២. គោលបំណងនៃការធ្វើសំណងជាប្រាក់

ការដាក់ទោសលើការខូចខាតដែលត្រូវបានកម្រិតលើ មូលដ្ឋាននៃ**ពិរុទ្ធភាព**របស់ជនល្មើស និងលើ មូលដ្ឋាននៃការខូចខាត ដែលសង្គមបានទទួលរងគ្រោះ គឺបានសេចក្តីថាជាការដាក់ទោសលើជនល្មើសត្រូវ ផ្អែកលើពិរុទ្ធភាព ពោលគឺចាប់បង្ខំជនល្មើសឱ្យធ្វើសំណងជួសជុលការអន្តរាយដល់សង្គម។ ការធ្វើយ៉ាងនេះ គឺក្នុងគោលបំណងធ្វើឱ្យការឈឺចាប់របស់ជនរងគ្រោះ និងមតិសាធារណៈបានរំងាប់ស្ងប់ស្ងាត់ទៅវិញ។

[៣៦] សាស្ត្រាចារ្យ ហ៊ាងឡេង, នីតិព្រហ្មទណ្ឌទូទៅ, ទំព័រ

### ១.៣. គោលបំណងនៃការអប់រំកែប្រែ

គោលបំណងនៃការដាក់ទោសនេះ មិនមែនសំដៅទៅលើ ការធ្វើទារុណកម្មលើរូបរាងកាយ ជនល្មើសនោះទេ គោលបំណងចំបង គឺសំដៅទៅលើការអប់រំកែប្រែជនល្មើស ឱ្យកែប្រែអត្តចរិតពី មនុស្សកោង កាចឃោឃៅ ឱ្យទៅជាមនុស្សមានផលប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល។

## ២. ចរិតលក្ខណៈនៃទោសព្រហ្មទណ្ឌ

### ២.១. ចរិតលក្ខណៈនីត្យានុកូលនៃទោស

បទល្មើសដែលមានចែងក្នុងបញ្ញត្តិនៃក្រមព្រហ្មទណ្ឌធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ផ្ទុយទៅវិញបើទោសនោះពុំមានច្បាប់ចែងក៏គ្មានការផ្តន្ទាទោសដែរ។[៣៧]

ក្នុងករណីខ្លះអំពើដែលផ្តល់ផលវិបាក និងព្យសនសកម្មដល់សង្គមមិនបានចែង ដូចនេះចៅក្រមអាច លើកយកយុត្តិសាស្ត្រមកដោះស្រាយបញ្ហានោះបាន។ យុត្តិសាស្ត្រអាចត្រូវបានយកមកអនុវត្តនៅពេលអំពើមួយ ផ្តល់ព្យសនៈកម្មដល់សង្គមប៉ុន្តែពុំមានច្បាប់ចែង។ តែក្នុងករណីព្រហ្មទណ្ឌនៃកម្ពុជាមិនត្រូវបានអនុញ្ញាត ឲ្យប្រើ យុត្តិសាស្ត្រយកមកអនុវត្តនៅក្នុងនីតិវិធីតុលាការបានឡើយ។

### ២.២. ចរិតលក្ខណៈនៃការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ។[៣៨]

### ២.៣. ចរិតលក្ខណៈសមភាពនៃទោស

ការចែងពីទោសពុំត្រូវមានមូលដ្ឋានផ្អែកទៅលើលក្ខខណ្ឌសង្គម (រួមមានដូចជា រូបសម្បត្តិ ភេទ ទ្រព្យសម្បត្តិ ។ល។ នៃបុគ្គលដែលត្រូវផ្តន្ទាទោសនោះទេ។ នេះជាការអនុវត្តនូវ គោលការណ៍សមភាព រវាងពលរដ្ឋ គ្រប់រូប។[៣៩]

ឧទាហរណ៍៖ ទោសកំណត់នៃការដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ សម្រាប់ បទឃាតកម្ម ដោយមិនបានធ្វើការបញ្ជាក់ថា ទោសនេះត្រូវអនុវត្តតែទៅលើបុរស ឬស្ត្រី អ្នកមាន ឬអ្នកក្រីក្រឡើយ។[៤០] ដែលមានន័យថាការកំណត់ទោសនេះត្រូវយកមកអនុវត្តទូទៅដោយមិនគិត ឋានៈ ភេទ ទ្រព្យ។

### ២.៤. ចរិតលក្ខណៈឯកត្តជននៃទោស

ចរិតលក្ខណៈឯកត្តជននៃទោសនាំមកនូវគោលការណ៍ឯកត្តកម្មនៃ ការទទួលខុសត្រូវព្រហ្មទណ្ឌ។ តាម គោលការណ៍ខាងលើ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសទណ្ឌផ្សេងៗទៀត ត្រូវតែផ្តន្ទាទោសទៅលើ

---

[៣៧] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៣

[៣៨] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៦

[៣៩] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ (២០១២, ២៩៥)

[៤០] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ១៩៩

ជនណាដែលបានប្រព្រឹត្តបទល្មើសតែប៉ុណ្ណោះ បានន័យថា មានតែជនដែលបានចូលរួមដោយផ្ទាល់ក្នុងការប្រព្រឹត្តបទល្មើសនោះទេដែលត្រូវបានចាត់ទុកថាជា ជនល្មើស ហើយត្រូវតែទទួលទោស។ គោលការណ៍នេះបានហាមឃាត់ការទទួលខុសត្រូវជាក្រុម ដែលគេតែងតែអនុវត្ត កាលពីសម័យមុន មានន័យថា បើជនណាម្នាក់បានប្រព្រឹត្តបទល្មើស សមាជិកក្រុមគ្រួសារទាំងមូលរបស់ជនល្មើសត្រូវតែទទួលទោសរួមគ្នាតែម្តង។ ម្យ៉ាងវិញ ទៀង គោលការណ៍ខាងលើ ក៏បានហាមឃាត់ការទទួលខុសត្រូវព្រហ្មទណ្ឌដោយសារអំពើរបស់អ្នកដទៃផងដែរ បានសេចក្តីថា ត្រូវហាមឃាត់ដាច់ខាត ដល់ការដាក់ទណ្ឌកម្មជនណាម្នាក់ ដោយសារតែជនម្នាក់ផ្សេងទៀតបានប្រព្រឹត្តបទល្មើស។

ឧទាហរណ៍៖ ឈ្មោះ ក បានសម្លាប់ឈ្មោះ ខ ដោយសារតែមានទំនាស់រឿងព្រំដីជាមួយនឹងក្រុម គ្រួសាររបស់គាត់។ ក្នុងករណីនេះ មានតែឈ្មោះ ក ទេដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំណែកឪពុកម្តាយ របស់ ក មិបានដឹងរឿងនេះទេ ហើយក៏មិនបានចូលរួមក្នុងការប្រព្រឹត្តសកម្មភាពល្មើសច្បាប់នេះដែរ។ ហេតុនេះ ឪពុកម្តាយរបស់ឈ្មោះ ក មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាមួយនឹងឈ្មោះ ក ឡើយ គឺមានតែឈ្មោះ ក ម្នាក់ ឯងគត់ដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានទទួលស្គាល់យ៉ាងជាក់ច្បាស់ ដោយមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌដែលបានចែងថា បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើ ផ្ទាល់ខ្លួនប៉ុណ្ណោះ។[៧]

### ៣. មុខងារនៃទោស

ទោសដែលត្រូវផ្តន្ទាទៅលើចារីនៃបទល្មើស ត្រូវបំពេញនូវមុខងារបីយ៉ាងផ្សេងៗគ្នាគឺ៖

**មុខងារបំភិតបំភ័យ**

ការដាក់ទោសលើចារីបណ្តាលឲ្យបុគ្គលផ្សេងៗទៀតដែលមានបំណងបម្រុងប្រព្រឹត្តបទល្មើសត្រូវតែខ្លាចរអាលែងហ៊ានប្រព្រឹត្តបទល្មើសតទៅទៀត ចំណែកឯបុគ្គលដែលមិនទាន់មានបំណងប្រព្រឹត្តបទល្មើស វិញក៏ត្រូវមានការភ័យខ្លាចនឹង ការប្រព្រឹត្តបទល្មើសដែរ។

**មុខងារបង្ក្រាប**

ទោសធ្វើឲ្យចារីត្រូវនៅឃ្លាតឆ្ងាយពីសង្គម លែងអនុញ្ញាតឲ្យចារីអាចមានឱកាសនឹងប្រព្រឹត្តបទ ល្មើសដែលខ្លួនប្រាថ្នាតទៅទៀតហើយ។

**មុខងារបញ្ចូលចារីទៅក្នុងសង្គមវិញ**

មុខងារចុងក្រោយនេះជាមុខងារសំខាន់ជាងគេទាំងអស់ ព្រោះថា ការដាក់ទោសលើចារីពុំមែន សុទ្ធតែមានគោលដៅក្នុងការបណ្តេញចារីឲ្យចាកចេញពីសង្គមជាស្ថាពរនោះទេ ក៏ប៉ុន្តែគឺគ្រាន់តែជាការក្រើន រំលឹកអប់រំដល់

---

[៧] រុន ពណ្ណារីទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ (២៩៤, ២៩៥, ២៩៦)

ចារីឲ្យដឹងត្រូវឡើងវិញ ហើយខិតខំកែប្រែខ្លួនឲ្យក្លាយជាពលរដ្ឋល្អសម្រាប់សង្គមជាតិ និងមិនត្រូវ ប្រព្រឹត្តបទល្មើសតទៅទៀតតែប៉ុណ្ណោះ។ ហេតុដូច្នេះ ដើម្បីឆ្លើយតបទៅនឹងមុខងារខាងលើ ពន្ធនាគារត្រូវតែជា កន្លែង សម្រាប់អប់រំដែលអនុញ្ញាតឲ្យទណ្ឌិតអាចទទួលបាននូវចំណេះដឹងខ្លះៗ ដើម្បីអាចត្រៀមបញ្ចូលខ្លួនទៅ ក្នុងសង្គមជាតិវិញបន្ទាប់ពីទទួលបានរងនូវទោសទណ្ឌកម្មសព្វគ្រប់រួចហើយ។[៦២]

## ៤. ទោស និងសញ្ញាណប្រហាក់ប្រហែល

ទោស គឺជាទណ្ឌកម្មដែលត្រូវបានប្រកាសដោយចៅក្រមព្រហ្មទណ្ឌ ដើម្បីផ្តន្ទាចំពោះបទល្មើសណាមួយ។ ក្នុងន័យនេះទោសគឺខុសប្លែកពីទណ្ឌកម្មដទៃទៀតដែល ពុំមានលក្ខណៈព្រហ្មទណ្ឌ និងខុសប្លែកពីវិធានការសន្តិសុខនានា។

### ៤.១. ទណ្ឌកម្មដែលពុំមានលក្ខណៈព្រហ្មទណ្ឌ

ការរំលោភបំពានលើកាតព្វកិច្ចណាមួយ អាចនាំឲ្យមានទណ្ឌកម្មច្រើនប្រភេទដូចជា ទណ្ឌកម្មរដ្ឋប្បវេណី ទណ្ឌកម្មរដ្ឋបាល និង ទណ្ឌកម្មព្រហ្មទណ្ឌ ជាដើម។

ទណ្ឌកម្មរដ្ឋប្បវេណីពុំមែនជាទោសព្រហ្មទណ្ឌទេ ពីព្រោះថាមានគោលដៅគ្រាន់តែជាការជួសជុល ដល់ការខូចខាតដែលបានបង្កើតឡើងដល់ជនរងគ្រោះ ហើយដោយតម្រូវឲ្យចារីត្រូវតែសងការខូចខាតដែលជន រងគ្រោះបានទទួលរងជាដើម។

ម្យ៉ាងវិញទៀតក្នុងករណីខ្លះច្បាប់បានផ្តល់អំណាចក្នុងការដាក់ទណ្ឌកម្មផ្សេងៗ ទៅឲ្យអាជ្ញាធររដ្ឋ បាលដោយគ្រាន់តែពិនិត្យមើលមួយភ្លែតទៅគឺ ជាទណ្ឌកម្មដែលមានលក្ខណៈប្រហាក់ប្រហែលទៅនឹងទោស ក្នុងរឿងព្រហ្មទណ្ឌដែរ ក៏ប៉ុន្តែតាមការពិតទៅមែនជាទោសព្រហ្មទណ្ឌនោះទេ។

### ៤.២. វិធានការសន្តិសុខ

វិធានការសន្តិសុខ មានលក្ខណៈប្រហាក់ប្រហែលទៅនឹងទោសដែរ ក៏ប៉ុន្តែមានលក្ខណៈខុសប្លែក ពីទោសខ្លះៗ។ ច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀនបានចែងពី វិធានការព្យាបាល។ មាត្រា៦២ថ្មីនៃច្បាប់ កំណត់ថាកាលបើជនញៀនគ្រឿងញៀនត្រូវផ្តន្ទាទោសដោយបទល្មើសណាមួយដែលមានចែងក្នុងមាត្រា ៣១ថ្មី ដល់ ៩ថ្មី នៃច្បាប់នេះ តុលាការអាចចាត់បន្ថែមលើទោសនូវវិធានការ ព្យាបាលដែលមានចែងក្នុងផ្នែកទី ២ នៃជំពូកទី ២៤ ។

វិធានការព្យាបាល អាចត្រូវបានដាក់បង្ខំដោយព្រះរាជអាជ្ញា ឬតុលាការ ឬក៏ដោយស្ម័គ្រចិត្ត ពីសំណាក់ជនដែលញៀនថ្នាំ។ មាត្រា ៩៨ ថ្មី កថាខណ្ឌទី ១ និង ទី ២ បានចាត់ទុកជាបទល្មើសនូវ ការរក្សាទុក ទិញ ឬដាំដុះដោយចេតនាសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬប្រើប្រាស់ផ្ទាល់ខ្លួននូវរុក្ខជាតិ ឬសារធាតុ ដែលចាត់ទុកថាជាថ្នាំញៀន ឬសារធាតុដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ។ ក៏ប៉ុន្តែ ប្រសិនបើ ជនប្រើប្រាស់គ្រឿងញៀនចូលខ្លួន

---

[៦២] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ២៩៣

ដោយខ្លួនឯង ទៅទទួលការព្យាបាលមុនការចោទប្រកាន់ ព្រះរាជអាជ្ញា ពុំអាចធ្វើការចោទប្រកាន់ឡើយ។ ម្យ៉ាងវិញទៀត តាមស្មារតីនៃមាត្រា ៩១ ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យជនដែលប្រើប្រាស់គ្រឿងញៀនចូលខ្លួនក្នុង រយៈពេល ៨ ថ្ងៃ ទៅក្នុងគ្រឹះស្ថានព្យាបាលណាមួយដែលបានចែងក្នុងមាត្រា ៨៩ ថ្មី ដើម្បីទទួលការព្យាបាលសមស្រប តាមសុខភាពរបស់ខ្លួន។ ក្នុងករណី ដែលជននោះបានទទួលការព្យាបាលតាមបង្គាប់រហូតដល់ទីបញ្ចប់ ឬបើជននោះបានបន្តការព្យាបាលដោយទៀងទាត់ តុលាការអាចប្រកាសថាមិនដាក់ទោស។ ដូចគ្នានេះដែរ មាត្រា ៩២ អនុញ្ញាតឲ្យតុលាការត្រឹមតែធ្វើការព្រមានប៉ុណ្ណោះ ប្រសិនបើជនប្រើប្រាស់គ្រឿងញៀន ទទួលការព្យាបាលរហូតដល់ទីបញ្ចប់ តាមការបង្ខំដោយតុលាការ ពោលគឺតុលាការមិនផ្តន្ទាទោស ដាក់ពន្ធនាគារ ឬផាកពិន័យឡើយ។ លើសពីនេះទៅទៀត អ្នកញៀនជាតិពុលដែលប្រព្រឹត្តបទល្មើស មិនធ្ងន់ធ្ងរមនឹងផ្តន្ទាទោសដាក់ពន្ធនាគារ ហើយមិនដែលត្រូវបានផ្តន្ទាទោស ដាក់ពន្ធនាគារដោយព្យួរទោស ឬមិនព្យួរទោសក្នុងរយៈពេល ៣ឆ្នាំកន្លងទៅ តុលាការអាចសម្រេច មិនដាក់ទោស ប៉ុន្តែត្រូវបង្ខំជននោះឲ្យទៅ ទទួលការព្យាបាល។

បទប្បញ្ញត្តិនានា ក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានឆ្លុះបញ្ចាំងឲ្យ ឃើញនូវ វិធានការព្យាបាលដែលច្បាប់ពុំបានចាត់ទុកថាជាទោស។ ប៉ុន្តែ វិធានការទាំងនេះអាចត្រូវប្រកាស ដោយចៅក្រម សម្រាប់ជនដែលបានប្រព្រឹត្តបទល្មើសណាមួយដែលច្បាប់កំណត់។ ដូចនេះ វិធានការព្យាបាល ត្រូវបាន ចាត់ទុកជា វិធានការសន្តិសុខ។[៤៣]

យើងទាញអត្ថន័យបានថា វិធានការសន្តិសុខជាវិធានការច្បាប់ដែលបានបង្កើតឡើង ក្នុងទិសដៅ អប់រំកែប្រែជនល្មើស រហូតដល់ជនល្មើសមានលក្ខណៈ ប្រក្រតី ដោយហេតុថាជនល្មើស មិនស្ថិតក្នុង ស្ថានភាពមិនប្រក្រតី (ញៀនគ្រឿងញៀន)។

## ផ្នែកទី ២ ៖ ប្រភេទនៃទោស

### ១. មូលទោស

មូលទោស គឺជាទោសមូលដ្ឋានដែលយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស។ មូលទោស ត្រូវបានបែងចែកជាពីរប្រភេទគឺ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។[៤៤]

---

[៤៣] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ (២៩៨ ដល់ ៣០១)

[៤៤] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៤៣

ទោសដាក់ពន្ធនាគារ គឺជាទោសគុកដែលដកសិទ្ធិសេរីភាពមានកំណត់កាលដែលត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារ។ កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ។

ទោសពិន័យជាប្រាក់ គឺជាទោសដែលចៅក្រមជំនុំជម្រះប្រកាសឲ្យជនជាប់ចោទបង់ប្រាក់ចូលរដ្ឋតាមការកំណត់ឲ្យបង់។ ការពិន័យត្រូវគិតជាប្រាក់រៀល។ កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពី អប្បបរមា និងអតិបរមា នៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល។

ចំពោះ ការប្រកាសមូលទោស ក្នុងគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និងពិន័យជាប្រាក់ផងតុលាការអាចប្រកាសទោសដូចជា៖

- ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ
- ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ
- ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។[៤៥]

### ១.១. អប្បបរមា និងអតិបរមានៃមូលទោស

កាលបើមានបទល្មើសមួយ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ តាមកាលដែលច្បាប់បានកំណត់អំពីបទល្មើសនោះត្រូវតែមាន អប្បបរមា និង អតិបរមា នៃទោសក្នុងការដាក់ពន្ធនាគារ។

ចំណែកកាលបើមានបទល្មើសណាត្រូវផ្តន្ទាទោសជាទោសពិន័យ ច្បាប់ក៏បានកំណត់អំពី ការពិន័យស្រដៀងទៅនឹងការកម្រិតរបស់ទោសពន្ធនាគារដែរ តែការកម្រិតនៃការដាក់ទោសពិន័យនេះគឺជាការពិន័យជាសាច់ប្រាក់ដូចជា ការពិន័យជាជាទឹកប្រាក់ក្នុង កម្រិតអប្បបរមា និងអតិបរមា។[៤៦]

### ១.២. ការកំណត់ទម្ងន់ទោស និងការសម្រាលទោស

ការកំណត់អប្បបរមា និងអតិបរមានៃទោសក្នុងការដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ អាចនឹងត្រូវបានបន្ថែម ឬត្រូវបានបន្ថយទៅតាមលក្ខខណ្ឌដែលមានចែងនៅក្រមព្រហ្មទណ្ឌនេះ។[៤៧]

### ១.៣. ប្រភេទនៃបទល្មើស

ជាទូទៅបទល្មើសមានច្រើនប្រភេទតែនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានចែងបទល្មើសព្រហ្មទណ្ឌជាបីប្រភេទគឺ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។

---

[៤៥] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៩៦
[៤៦] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៤៤
[៤៧] ក្រមព្រហ្មទណ្ឌ, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៤៥

### ១.៣.១. បទឧក្រិដ្ឋ

បទល្មើសដែលមានអតិបរមានៃទោស ស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរដែលច្បាប់បានកំណត់ ឲ្យជាប់ពន្ធនាគារអស់មួយជីវិត និងជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ (ប្រាំ) ឆ្នាំ ក្រោម ឬស្មើនឹង ៣០ (សាមសិប) ឆ្នាំ។ ក្នុងករណីខ្លះ ទោសដាក់ពន្ធនាគារអាចក៏ត្រូវបានបន្ថែមទោសពិន័យជាប្រាក់ផងដែរ។[៥៨]

**ឧទាហរណ៍៖**

បទរំលោភសេពសន្ថវៈ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ដូច្នេះយើងឃើញថា អតិបរមានៃទោសដាក់ពន្ធនាគារសម្រាប់ បទរំលោសេពសន្ថវៈ ដែលបានកំណត់អំពី អតិបរមានៃទោសដាក់ពន្ធនាគារចំនួន ១០ (ដប់) ឆ្នាំ គឺជាបទឧក្រិដ្ឋ (មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ) ។

បទឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត (មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ) ។

បទទារុណកម្ម និងអំពើឃោរឃៅ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ (មាត្រា ២១០ នៃក្រមព្រហ្មទណ្ឌ) ។

បទដណ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ (មាត្រា ២៥៦ នៃក្រមព្រហ្មទណ្ឌ) ។

បទឧបឃាតសំដៅលើអំពើប្រព្រឹត្តមួយឬច្រើនក្នុងគោលបំណងបង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឱ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ (មាត្រា ៤៥១ នៃក្រមព្រហ្មទណ្ឌ) ។

### ១.៣.២. បទមជ្ឈិម

បទមជ្ឈិម គឺជាបទល្មើសទាំងឡាយណាដែលស្ថិតនៅចន្លោះបទឧក្រិដ្ឋនិងបទលហុហើយកម្រិត គ្រោះថ្នាក់ដល់សង្គមនោះមិនធ្ងន់ធ្ងរពេក ក៏មិនស្រាលពេក ហើយទោសដែលត្រូវទទួលក៏មិនធ្ងន់ធ្ងរពេក ហើយក៏មិនស្រាលពេកដែរ គឺមានលក្ខណៈធួនល្មម។ នៅក្នុងមាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ បទមជ្ឈិមត្រូវបានកំណត់អតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ។ បន្ថែមពីលើនេះទៅទៀតទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។

**ឧទាហរណ៍៖**

បទលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ ដូច្នេះអតិបរមា នៃទោសដាក់ពន្ធនាគារដែលកំណត់ ៣ (បី) ឆ្នាំ គឺក្រោម ៥ (ប្រាំ) ឆ្នាំ ដូច្នេះជាបទមជ្ឈិម (មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ) ។

បទមនុស្សឃាតដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ (មាត្រា ២០៧ នៃក្រមព្រហ្មទណ្ឌ) ។

---

[៥៨] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៤៦

បទគំរាមគំហែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ (មាត្រា ២៣១ នៃក្រមព្រហ្មទណ្ឌ)។

បទរុកកួនផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ (មាត្រា ២៥០ នៃក្រមព្រហ្មទណ្ឌ) ។

បទញុះញង់អនីតិជនឱ្យប្រព្រឹត្តបទបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ (មាត្រា ៣៤៥ នៃក្រមព្រហ្មទណ្ឌ) ។

### ១.៣.៣. បទលហុ

បទលហុ គឺជាបទល្មើសមួយដែលជនល្មើស បានប្រព្រឹត្តអំពើដែលប៉ះពាល់ដល់សង្គមយ៉ាងតិចតួចស្តួចស្តើង ឬប៉ះពាល់ដល់សិទ្ធិសេរីភាពបុគ្គល ហើយទណ្ឌកម្ម ដែលត្រូវផ្តន្ទាទោសទៅលើជនល្មើស ក៏ស្រាល ដែរ។ បទលហុនៅក្នុងមាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ គឺយើងមើលទៅលើគោលកាណ៍ពីរយ៉ាង គឺ៖

- គោលការណ៍ទី ១ ត្រូវមើលទៅលើអតិបរមានៃទោសដាក់ពន្ធនាគាររយៈពេលក្រោម ឬស្មើនឹង ៦ (ប្រាំមួយ) ថ្ងៃ។
- គោលការណ៍ទី ២ មើលទៅលើបទល្មើសដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់តែប៉ុណ្ណោះ។

ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ ដូច្នេះ យើងពិនិត្យឱ្យលម្អិតទៅឃើញថា នៅក្នុងក្រមព្រហ្មទណ្ឌថ្មីនេះមានបទល្មើសដែលផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ បើទោះបីជាចំនួនប្រាក់ដែលត្រូវបានពិន័យនោះប៉ុន្មានក៏ដោយ ក៏នៅតែជាបទលហុដែរ។

**ឧទាហរណ៍៖**

បទស្រវឹងជាក់ស្តែង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០(ប្រាំពាន់)រៀល ទៅ ១០.០០០(មួយម៉ឺន)រៀល គឺពិន័យត្រឹមតែជាប្រាក់ប៉ុណ្ណោះ (មាត្រា ២៩៧ នៃក្រមព្រហ្មទណ្ឌ) ។

បទហិង្សាស្រាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០(ប្រាំពាន់)រៀល ទៅ ១០០.០០០(មួយសែន)រៀល (មាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ) ។

បទបរិហារកេរ្តិ៍ជាសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០(មួយសែន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល (មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ) ។

បទជេរប្រមាថជាសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០(មួយសែន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល (មាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ) ។

បទហៅអ្នកដទៃនៅទីសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ៥០.០០០ (ប្រាំម៉ឺន) រៀល (មាត្រា ២៩៨ នៃក្រមព្រហ្មទណ្ឌ) ។

ចូលចាំថាដើម្បីអាចកំណត់បានថាបទល្មើសមួយជា បទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ គឺត្រូវមើលទៅលើអតិបរមានៃទោសដាក់ពន្ធនាគារ ដែលចែងនៅក្នុងច្បាប់ ឬមានចែងនៅក្នុងមាត្រានីមួយៗ នៃច្បាប់ជាក់ស្តែងដែលយើងឃើញតែប៉ុណ្ណោះ។ ផ្ទុយទៅវិញមិនត្រូវមើល លើអប្បបរមានៃទោសដាក់ពន្ធនាគារដែលមាន ចែងនៅក្នុងច្បាប់ជាក់ស្តែង ស្ថានទម្ងន់ទោស ស្ថានសម្រាលទោស ករណីអនុវត្តចំពោះអនីតិជនសេចក្តី សម្រេចរបស់តុលាការទេ (សាលក្រម ឬសាលដីកា) ។

## ២. ទោសបន្ថែម

អនុទោស ឬទោសបន្ថែម គឺជាទោសដែលតុលាការប្រកាសបន្ថែមទៅលើមូលទោស។ លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម នឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ ចំពោះ បទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ដែលត្រូវចោទប្រកាន់។ ទោសបន្ថែម អាចប្រកាសក៏បាន មិនប្រកាសក៏បាន។ ទោសបន្ថែមត្រូវ ប្រកាស ជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់។[៤៩]

ការប្រកាសទោសបន្ថែមលើមូលទោស កាលណាបើបទល្មើសមយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ នៃក្រមព្រហ្មទណ្ឌ។ ការជំនួសមូលទោសដោយទោសបន្ថែមបានកំណត់ថា តុលាការអាចសម្រេចជំនួសមូលទោសដោយទោសបន្ថែមួយ ឬច្រើនក្នុងករណីៈ

- កាលណាជនជាប់ចោទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់។
- កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ។[៥០]

### ២.១. ការដកសិទ្ធិខ្លះជាពលរដ្ឋ

ក្នុងករណីដែលបានប្រព្រឹត្តបទល្មើស ដែលច្បាប់បានហាមឃាត់ និងត្រូវបានតុលាការប្រកាសទោស ជនប្រព្រឹត្តបទល្មើសនោះ អាចនឹងត្រូវបានដកសិទ្ធិខ្លះជាពលរដ្ឋ ដែលសិទ្ធិទាំងនោះរួមមានៈ

១. សិទ្ធិបោះឆ្នោត។

២. សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត។

៣. សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសារធាណៈ។

៤. សិទ្ធិទទួលបានការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬ អាណត្តិគាហករបស់តុលាការ។

៥. សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់។

៦. សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការ។

---

[៤៩] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៥៤

[៥០] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, មាត្រា ៩៩, ១០០

ទោសនេះអាចជស្ថាពរ ឬ ជាបណ្តោះអាសន្នសសម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។[៥១]

### ២.២. ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ

ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ មិនអនុវត្តទៅលើការបំពេញអាណត្តិ ដែលជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ ឬ ការទទួលខុសត្រូវខាងសហជីពទេ។ ការហាមឃាត់នេះ មិនអាចអនុវត្តចំពោះបទល្មើសបានរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មាន។ ទោសនេះអាច ជាស្ថាពរ ឬ ក៏ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំយ៉ាងច្រើន។ តុលាការត្រូវបញ្ជាក់មុខរបរដែល ត្រូវហាមឃាត់។[៥២]

### ២.៣. ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ និងការព្យួរលិខិតបើកបរ

ក្នុងករណីនេះ ប្រសិនបើបុគ្គលណាម្នាក់ធ្លាប់បានប្រព្រឹត្តបទល្មើស និងបានទទួលការអនុវត្តន៍ទោស ហើយបានសម្រេចទោសជាស្ថាពរដោយតុលាការ សាលដីកាស្ថាពរពីតុលាការ នោះបុគ្គលត្រូវបានកំណត់ និង ត្រូវបានហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ មិនត្រូវលើសពី ៥ (ប្រាំ)ឆ្នាំ ដែលមានន័យថា ការហាមស្ថិតនៅចន្លោះពី ១ឆ្នាំ ដល់ ៥ឆ្នាំ។[៥៣]

ការព្យួរលិខិតបើកបរមិនឲ្យលើសរយៈពេលពី ៥ (ប្រាំ) ទេ។ ទណ្ឌិតត្រូវប្រគល់ លិខិតបើកបរ របស់ខ្លួនទៅក្រឡាបញ្ជីតុលាការ។ លិខិតបើកបររបស់ទណ្ឌិត ត្រូវរក្សាទុក្ខតាមលក្ខខណ្ឌ ដែលបានកំណត់ដោយ ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[៥៤]

### ២.៤. ការហាមឃាត់ចំពោះការស្នាក់នៅ

ការហាមឃាត់ការស្នាក់នៅទីនេះ សំដៅដល់ការហាមឃាត់ដល់ទណ្ឌិត ចំពោះការមានមុខ ឬការស្នាក់នៅទីកន្លែងណាមួយ លើដែនដីដែលបានហាមឃាត់នៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនេះទោស មិនអាចលើសពី ១០ (ដប់) ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម។ តុលាការកំណត់បញ្ជីនៃកន្លែង ដែលហាមឃាត់ និង កំណត់ថេរវេលានៃការហាមឃាត់។ ការហាមឃាត់ការស្នាក់នៅត្រូវមានវិធានការតាម ដានទណ្ឌិតដូចជា៖

១. ចូលបង្ហាញខ្លួនតាមដីកាកោះហៅរបស់អាជ្ញាធរុលាការ ឬ រដ្ឋបាលដែលតុលាការបានចាត់តាំង។

២. ចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬ កងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ។ តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន។

សេចក្តីសម្រេចរបស់តុលាការ ត្រូវជូនដំណឹងដោយព្រះរាជអាជ្ញាដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ។ [៥៥]

---

[៥១] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៥៥

[៥២] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៥៦

[៥៣] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៥៧

[៥៤] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៥៨

[៥៥] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៥៩

### ២.៥. ការហាមឃាត់ចំពោះការចាកចេញពីដែននៃព្រះរាជាណាចក្រកម្ពុជា

ទណ្ឌិត នឹងត្រូវបានហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជណាចក្រកម្ពុជា ក្នុងកំឡុងពេល មិនត្រូវលើសពី ៥(ប្រាំ) ឆ្នាំ បន្ទាប់ពីបានប្រព្រឹត្តបទល្មើស។ ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅ ក្រឡាបញ្ជីនៃតុលាការ។ ហើយលិខិតនេះ ត្រូវបានរក្សាទុក តាមលក្ខខណ្ឌដែលមានកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្រៅពីនេះ ទណ្ឌិតមិនអាចសុំ លិខិតឆ្លងដែនបានទេ ក្នុងរយៈពេលដែលកំពុងទទួល ទោសនោះ។[៥៦]

### ២.៦. ការហាមឃាត់ចំពោះការចូលនិងការស្នាក់នៅលើដែននៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិតដែលជាជនបរទេស

ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល និងការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំយ៉ាងច្រើន។ ការ ហាមឃាត់នេះ នាំឱ្យមានការ បណ្តេញទណ្ឌិតឱ្យចេញដោយពេញច្បាប់នៅពេលបញ្ចប់ទោសដាក់ពន្ធនាគារ។[៥៧]

### ២.៧. ការរឹបអូស និងការចាត់ចែងទ្រព្យសម្បត្តិរឹបអូស

បន្ទាប់ពីមានការប្រព្រឹត្តបទល្មើស និងការកំណត់បាននៅទណ្ឌិតបានហើយ ការរឹបអូសអាចធ្វើឡើង ទៅលើ វត្ថុ ឬសម្ភារៈដូចជា៖

១. ឧបករណ៍ សម្ភារៈ ឬវត្ថុ ដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្ត បទល្មើស ឬដែលទុក សម្រាប់ប្រព្រឹត្ត បទល្មើស។

២. វត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។

៣. ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស

៤. ឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុ ដែលលំអទីកន្លែងដែល បទល្មើសត្រូវបានប្រព្រឹត្ត។

បន្ថែមលើនេះ ការរឹបអូសនេះ នឹងមិនអាចកើតមានឡើង និង ការរឹបអូសមិនអាចប្រកាសបានទេ ប្រសិន បើផ្តល់ ផលប៉ះពាល់ដល់សិទ្ធិរបស់តតិយជន។ តតិយជនត្រង់នេះ អាចសំដៅដល់ជនដែលស្ថិតនៅក្នុង កន្លែងកើត ហេតុ ឬជនដែលអាចទទួលផលប៉ះពាល់បន្ទាប់ពីការការរឹបអូសនោះ។[៥៨]

កាលណាបើការរឹបអូសបានចូលជាស្ថាពរហើយ ទ្រព្យសម្បត្តិរឹបអូសនឹងត្រូវបានក្លាយជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងករណីដែលមានបទបញ្ញត្តិដោយឡែក ដែលមានចែងអំពីការប្រគល់វត្ថុផ្សេងទៀតពីនេះ។ ដូចនេះ រដ្ឋអាចលក់ ឬធ្វើការបំផ្លាញចោលទ្រព្យដែលបានរឹបអូសនោះ ទៅតាមនីតិវិធីស្តីពីការលក់ទ្រព្យសម្បត្តិរដ្ឋ។[៥៩]

---

[៥៦] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៦០

[៥៧] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៦១

[៥៨] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៦២

[៥៩] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៦៣

### ២.៨. ការហាមឃាត់ចំពោះការកាន់កាប់ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់ រំសេវគ្រប់ប្រភេទ

ការហាមឃាត់ ទណ្ឌិតចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំយ៉ាងច្រើន។ ការហាមឃាត់នេះ ត្រូវអនុវត្តទៅលើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[៦០]

### ២.៩. ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ

ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬ ដោយប្រយោលក្នុងលទ្ធកម្មសាធារណៈទាំងឡាយដែលរៀបចំដោយ៖

១. រដ្ឋ

២. រដ្ឋបាលថ្នាក់ក្រោមជាតិ

៣. គ្រឹះស្ថានសាធារណៈ

៤. សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ ដែលត្រួតពិនិត្យដោយរដ្ឋ ឬ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ហើយទោសបណ្តេញចេញនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។[៦១]

### ២.១០. ការបិទគ្រឹះស្ថាន

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុង គ្រឹះស្ថានដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង។ ហើយទោសបិទគ្រឹះស្ថាននេះ អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។[៦២]

### ២.១១. ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬ ដែលត្រូវប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្ន សម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។[៦៣]

### ២.១២. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស

ទោសបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែង ដែលចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ។ ការបិទផ្សាយមិន អាចលើសពី ២ (ពីរ) ខែ ទេ។ ការបិទផ្សាយអាចធ្វើទាំងស្រុង ឬ តាមសម្រង់ ឬ តាមនិទ្ទេសធម្មតា។ សោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត។

---

[៦០] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៦៤

[៦១] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៦៥

[៦២] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៦៦

[៦៣] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៦៧

ក្នុងករណីមានការបំបាត់ចោល ការលាក់បាំង ឬ ការហែកចោលសេចក្ដីប្រកាសនេះ ត្រូវតែធ្វើការបិទផ្សាយនេះ ត្រូវចេញសោហ៊ុយ ដោយអ្នកបំបាត់ចោល លាក់បាំង ឬ អ្នកហែកចោលសេចក្ដីប្រកាសនេះ។[៦៤]

### ២.១៣. ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ

ទោសផ្សាយសេចក្ដីសម្រេចរបស់តុលាការ ត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និង ក្នុងថិរវេលាដែលកំណត់ដោយតុលាការ រីឯសោហ៊ុយក្នុងការចុះផ្សាយ ជាបន្ទុករបស់ទណ្ឌិត។ ក្នុងករណីមិន គោរពតាមការកំណត់ ទណ្ឌិតអាចត្រូវបង្ខំដល់រូបកាយ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយជាសេចក្ដី សម្រេចសារព័ត៌មានមិនអាចបដិសេធការផ្សព្វផ្សាយនេះបានទេ។[៦៥]

### ២.១៤. ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍

ទោសផ្សាយជាសារធារណៈនូវសេចក្ដីសម្រេចតាមគ្រប់មធ្យោបាយ ទូរគមនាគមន៍សោតទស្សន៍ ត្រូវ អនុវត្តបែបបទដែលកំណត់ដោយតុលាការ។ ការផ្សាយនេះមិនអាចលើសពី ៨(ប្រាំបី) ថ្ងៃ នោះទេ។ ការផ្សាយអាចទាំងស្រុង តាមសម្រង់ ឬ តាមនិទ្ទេស។ សោហ៊ុយនៃការផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត។[៦៦]

### ២.១៥. ពេលនៃការអនុវត្តទោសបន្ថែម

ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦, និង ៧ នៃមាត្រា ៥៣(ប្រភេទនៃបន្ថែម)នៃក្រមនេះ ត្រូវអនុវត្តនៅពេលផុតទោសពន្ធនាគារលើកលែងតែមាន សេចក្ដីសម្រេចផ្ទុយរបស់តុលាការ។[៦៧]

## ៣. ទោសជំនួស

ទោសជំនួស សំដៅលើទោសដែលតុលាការយកមកប្រកាសជំនួសឲ្យមូលទោស។ បើយោងតាមក្រមព្រហ្មទណ្ឌទោសជំនួសចែកចេញជាពីរគឺ **ការងារសហគមន៍** និង **ការស្ដីបន្ទោស**។

**ការងារសហគមន៍** គឺជាកាតព្វកិច្ចត្រូវបំពេញក្នុងថេរវេលាចន្លោះពី ៣០ (សាមសិប)ម៉ោង ទៅ ២០០ (ពីររយ) ម៉ោងនូវការងារគ្មានកម្រៃដែលផ្ដល់ប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀង សហគម ឬអង្គការមិនមែនរដ្ឋាភិបាល។[៦៨] នៅក្នុងគ្រប់ករណីទាំងអស់ ការងារសហគមន៍មិនអាចបំពេញជាប្រយោជន៍រូបវន្តបុគ្គលទេ ពោល ការងារសហគមន៍ត្រូវបានប្រកាសដោយតុលាការ និងមានគោលបំណងផ្ដល់ប្រយោជន៍រួមតែប៉ុណ្ណោះ។[៦៩]

---

[៦៤] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៦៨

[៦៥] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៦៩

[៦៦] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៧០

[៦៧] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៧១

[៦៨] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៧២

[៦៩] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៧៣

ការងារសហមន៍ត្រូវតែស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារជាអាទិ៍ ការងារនៅពេល យប់ អនាម័យ សន្តិសុខ ហើយនិង ការងាររបស់ស្ត្រី។ ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ។[៧០] រដ្ឋជាអ្នកចេញសោហ៊ុយជួសជុលការខូចខាតដែលបង្កដោយទណ្ឌិតដល់អ្នកដទៃ នៅក្នុងពេលដែលកំពុងអនុវត្តសកម្មភាពវិជ្ជាជីវៈ ហើយរដ្ឋត្រូវធ្វើ ឧបាទេសកម្ម ឬ ការទទួលខុសត្រូវជំនួសទណ្ឌិតណាម្នាក់តាមផ្លូវច្បាប់ជូនដល់សិទ្ធិជនរងគ្រោះ។[៧១]

ចំពោះទោសជំនួសជា **ការស្តីបន្ទោស** កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ៣(បី)ឆ្នាំតុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌទាំងបីដូចតទៅ៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួចហើយ
- ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ។[៧២]

## ផ្នែកទី ៣ ៖ ការអនុវត្តទោស

### ១. ការអនុវត្តទោសចំពោះនីតិជន

ការអនុវត្តទោសចំពោះនីតិជន គឺការអនុវត្តទោសមានលក្ខណៈទូទៅ ទៅតាមអ្វីដែលច្បាប់មានចែង ដោយមិនមានលក្ខណៈស្មុគស្មាញដូចអនីតិជនឡើយ។ ដោយសារតែនីតិជនគឺជាជនដែលមាន ការគិតពេញ លេញកាយសម្បទាគ្រប់គ្រាន់ ក្នុងការសម្រេចចិត្ត និងមានអាយុចាប់ពី ១៨ឆ្នាំ ដែលជាវ័យដែលអាចផ្តន្ទាទោសតាមច្បាប់កំណត់។ ករណី បើនីតិជនប្រព្រឹត្តបទល្មើសមានន័យថា ការប្រព្រឹត្តនោះ គឺត្រូវបាន កើតចេញពី ការគិតនិងការសម្រេចចិត្តពីនីតិជនផ្ទាល់តែម្តង។ យើងអាចនិយាយបានថា នីតិជនមានសមត្ថភាពពេញលេញក្នុងការទទួលទោសតាមច្បាប់ ដែលមានចែង។

### ២. ការអនុវត្តទោសចំពោះអនីតិជន

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុ ចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។[៧៣] ដូចនេះ អនីតិជនពុំទាន់មាននីតិភាពពេញលេញក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនោះនៅឡើយទេ នៅពេលប្រព្រឹត្តបទល្មើស ដោយសារអនីតិជនជាជនដែលមានបុគ្គលិកលក្ខណៈមិនគ្រប់គ្រាន់ទៅតាមច្បាប់កំណត់។ ប៉ុន្តែនៅពេល អនីតិជនបានប្រព្រឹត្តបទល្មើស នោះអនីតិជនត្រូវបានក្លាយជាកម្មវត្ថុនៃ **វិធានការតាមដាន វិធានការអប់រំ វិធានការការពារ** និង **វិធានការឧបត្ថម្ភ**។ ហើយតុលាការ អាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជន

[៧០] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៧៤
[៧១] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៧៥
[៧២] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៧៦
[៧៣] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៣៨

អាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនត្រូវបានតម្រូវ។[៧៤]

### ២.១. ប្រភេទវិធានការអនុវត្តចំពោះអនីតិជន

ប្រភេទនៃវិធានការដែលនឹងត្រូវអនុវត្តចំពោះអនីតិជន ហើយបានកំណត់ថាជា វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការ ឧបត្ថម្ភមាន ដូចតទៅ៖

១. ការប្រគល់អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។

២. ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។

៣. ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន

៤. ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។

៥. ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។[៧៥]

ក្នុងករណីដាក់ឱ្យស្ថិតក្រោម **ការការពាររបស់តុលាការ** នោះតុលាការ ចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពី កិរិយាមារយាទ របស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញា អំពីព្រឹត្តិការណ៍ ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ។[៧៦]

### ២.២. មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំ

មូលទោសដែលអនុវត្តចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ បានចែងថា កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ត្រូវបានត្រូវបន្ថយនៅលក្ខខណ្ឌដូចតទៅ៖

១. អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។

២. ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនា គារ២០(ម្ភៃ)ឆ្នាំ។

៣. អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវដាក់បន្ថយពាក់កណ្តាល ប្រសិនអប្បបរមានេះលើសពី ១ថ្ងៃ។

---

[៧៤] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៣៩

[៧៥] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៤០

[៧៦] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៤១

៤. អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្ដាល។ ករណីចោទប្រកាន់ពីបទ ឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាព បន្ថយអតិបរមានៃទោសដាក់ដាក់ពន្ធនាគារមកត្រឹម ចិរវេលាមួយស្មើ ឬតិចជា ៥(ប្រាំ)ឆ្នាំនោះ បទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។[៧៧]

## ២.៣. ទោសបន្ថែមចំពោះអនីតិជន

ទោសបន្ថែមដែលអាចអនុវត្តទៅលើអនីតិជននៅពេលប្រព្រឹត្តបទល្មើសរួមមាន៖

១. ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅ ប្រព្រឹត្តបទល្មើស។

២. ការរឹបអូស ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

៣. ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៤. ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលមានបទល្មើសត្រូវបានប្រព្រឹត្ត។

៥. ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទ។[៧៨]

## ២.៤. ទោសជំនួសចំពោះអនីតិជន

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមាន អាយុ យ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំប៉ុន្តែចិរវេលានៃការងារមិនអាចលើសពី ១០០(មួយរយ) ម៉ោង។ ការងារសហគមន៍ ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្ដុះបណ្ដាល និងសម្រួល ដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។[៧៩]

ការអនុវត្តបទប្បញ្ញត្តិស្ដីការមិនរាងចាល មិនត្រូវបានដាក់អនុវត្តទៅលើអនីតិជនឡើយ។[៨០]

មាត្រា ១៦៤ បានចែងថាស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន។

## ២.៥. ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

កាលបើតុលាការបានសម្រេច ឲ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោស លើអនីតិជនពីបទ ឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាត ដោយឡែកដូចតទៅ:

១. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០(ដប់) ឆ្នាំនោះអប្បបរមា ត្រូវបន្ថយ មកនៅត្រឹម ១(មួយ) ឆ្នាំ។

២. ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធគារស្មើ ឬលើសពី ៥(ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំនោះ អប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ។

---

[៧៧] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៦០
[៧៨] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៦១
[៧៩] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៦២
[៨០] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៦៣

៣. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២(ពីរ) ឆ្នាំ និងតិចជាង ៥(ប្រាំ) ឆ្នាំនោះ អប្បបរមា ត្រូវបន្ថយមកត្រឹម ៣(បី) ខែ។

៤. ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦(ប្រាំមួយ) ថ្ងៃ និងតិចជាង ២(ពីរ) ឆ្នាំ នោះអប្បបរមាត្រូវបន្ថយត្រឹម ១(មួយ) ថ្ងៃ។

៥. អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល។[៩១]

### ២.៦. កាតព្វកិច្ចដោយឡែកនៃការព្យួរទោសសាកល្បងរបស់អនីតិជន

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជនៈ

១. ទទួលការបង្ហាត់បង្រៀន ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

២. ស្ថិតនៅទីកន្លែងមួយជាកំណត់។

៣. ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល។

៤. ជួសជុលព្យសនកម្មដែលបណ្ដាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន។

៥. បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយតាមលទ្ធភាពនៃធនធាន របស់ខ្លួន បន្ទាប់ពីការផ្តន្ទាទោស។

៦. មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ។

៧. មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង។

៨. មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។

៩. មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។[៩២]

## ៣. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី

### ៣.១. ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួន បុគ្គលដែលសង្ស័យថា បានចូលរួមក្នុងការប្រព្រឹត្តបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាច ឃាត់ខ្លួនបុគ្គល ដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញៈ

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន
- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យ ធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។

---

[៩១] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៦៤

[៩២] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៦៥

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ ដែលតម្រូវឱ្យ មានការឃាត់ខ្លួននេះ។ ការឃាត់ខ្លួនមានចិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង។ ចិរវេលាត្រូវចាប់គិត ពីម៉ោងដែលសាមីខ្លួនមកដល់ អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែល ឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីឱ្យ ការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។ ការពន្យារពេលនេះត្រូវសុំទៅព្រះរាជអាជ្ញា ដែលត្រូវផ្ទៀងផ្ទាត់មើល មូលកភាព។ ការអនុញ្ញាតឱ្យ ពន្យារពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និង មានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ការពន្យារគឺជាវិធានការពិសេស។ ការពន្យារនេះមិនអាចឱ្យ លើសពី ២៤ (ម្ភៃបួន)ម៉ោងឡើយ ដោយមិនគិតពីចិរវេលាចាំបាច់ក្នុង ការដឹកជញ្ជូន។

ការពន្យារ មិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះ ជាអនីតិជន។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ម៉ោង ឡើយ ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ម៉ោង ឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ម៉ោងឡើយ ។

អនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។[៨៣]

### ៣.២. ការបញ្ជូនខ្លួន

ចំពោះការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន នៅពេលផុតកំណត់នៃរយៈពេលការឃាត់ខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវះ

- បញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬ
- ដោះលែងឲ្យមានសេរីភាពឡើងវិញ។

សេចក្ដីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា។[៨៤]

---

[៨៣] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៩៦

[៨៤] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០៣

ចំណែករយៈពេលនៃការបញ្ជូនខ្លួន កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា នោះ បុគ្គលនេះត្រូវបាននាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា។

ប្រសិនបើការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ពុំអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេសដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយផ្លូវនៃការដឹកជញ្ជូននោះ រយៈពេលបន្ថែមអាចផ្តល់ឲ្យដោយព្រះរាជអាជ្ញាបាន។

នៅក្នុងគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនត្រូវធ្វើឡើងនៅក្នុងរយៈដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។

មូលហេតុនៃការឃើតយ៉ាវត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌។[៩៥]

### ៣.២. ការឃុំខ្លួនបណ្តោះអាសន្ន

**គោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន** ជាគោលការណ៍ដែលជនត្រូវចោទប្រកាន់ពីបទល្មើសណាមួយត្រូវតែមានសេរីភាព។[៩៦] ករណីនៃការឃុំខ្លួនបណ្តោះអាសន្ន អាចអនុវត្តបានចំពោះតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់បានកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ។[៩៧]

**មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន** ជាការឃុំខ្លួនបណ្តោះអាសន្នដែលអាចត្រូវបានធ្វើការបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះ ដែលជាតម្រូវការ ចាំបាច់ ត្រូវបានកំណត់នៅក្នុងមាត្រា ២០៥ ដូចតទៅៈ

១.ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី ។

២.ដើម្បីរារាំងកុំឱ្យ មានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យ មាន ការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត។

៣.ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ។

៤.ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។

៥-ដើម្បីការពារសន្តិសុខឱ្យ ជនត្រូវ ចោទ ។

៦.ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឱ្យ មានការច្របូកច្របល់ ដែលបណ្តាល មកពីបទល្មើស។[៩៨]

---

[៩៥] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ១០៤
[៩៦] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៣
[៩៧] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៤
[៩៨] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៥

### ក. ការឃុំខ្លួនបណ្តោះអាសន្ននីតិជន

**ការកំណត់សម្គាល់របស់ជនត្រូវចោទ និងការប្រាប់ហេតុផលនៃដីកា** ក្នុងករណីនេះ ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនបណ្តោះអាសន្ន ដោយគំនិតផ្តើមរបស់ខ្លួនផ្ទាល់ ឬ តាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវឱ្យ ដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់ របស់ជនត្រូវចោទនេះ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយ ការពារខ្លួន។ ចំណែកឯចៅក្រមស៊ើបសួរ ត្រូវតែសម្រេចឃុំខ្លួនជនត្រូវចោទ ជាបណ្តោះអាសន្ន ដោយផ្អែកតាមដីកាដោយមានសំអាងហេតុដែលចៅក្រមស៊ើបសួរទទួលបានពីការស៊ើបអង្កេតជនត្រូវចោទ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិនៃមាត្រា២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) នៃក្រមនេះ។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានជូនដំណឹងភ្លាម ដល់ ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។ ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នត្រូវបានធ្វើឡើងដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដូច បានចែងនៅក្នុងមាត្រា ២២០ (និយមន័យ ដីកាបង្គាប់ឱ្យ ឃុំខ្លួន) មាត្រា ២២១(និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យ ឃុំខ្លួន) និងមាត្រា ២២២ (ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន) នៃក្រមនេះ ។[៨៩]

**ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន** នឹងត្រូវបានអនុវត្តឡើង កាលណាចៅក្រមស៊ើបសួរ បានទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដែលបានសុំឱ្យ ឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នតែ ចៅក្រមស៊ើបសួរ នោះមិនព្រមធ្វើតាម ការស្នើរសុំ ឃុំខ្លួនជនត្រូវចោទនោះទេ ចៅក្រមស៊ើបសួរ ត្រូវចេញដីកាក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នូវដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ដោយមិនចាំបាច់ មានសំអាងហេតុនោះទេ។ ដីកាមិនឃុំខ្លួនបណ្តោះអាសន្ននេះត្រូវជូនដំណឹងជាបន្ទាន់ ដល់អ្នកប្តឹងសុំ។ ប្រសិនបើចៅក្រមស៊ើបសួរមិន បានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នោះទេ ព្រះរាជអាជ្ញា អាចធ្វើការដាក់ពាក្យប្តឹងទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរវិញ។[៩០]

**ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋ** ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពី **បទឧក្រិដ្ឋ** ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការ ឃុំខ្លួនបណ្តោះអាសន្នម្តង បាន ៦ (ប្រាំមួយ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្ន បានតែ ២ (ពីរ) ដងគត់។[៩១]

---

[៨៩] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៦

[៩០] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៧

[៩១] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៨

**ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទមជ្ឈិម** ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពី **បទមជ្ឈិម** ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ (បួន)ខែបានទេ។ ប៉ុន្តែ នៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរ អាចពន្យារការឃុំខ្លួន បណ្តោះអាសន្ន បានតែម្តងគត់ មិនឱ្យលើសពី ២ (ពីរ) ខែ ដោយមានដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃ អប្បបរមានៃទោស ដែលច្បាប់បានកំណត់អំពីបទមជ្ឈិមនេះឡើយ។[៦២]

**ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ** ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរ អាចពន្យារពេលការឃុំខ្លួនបណ្តោះ អាសន្នម្តង បាន ១ (មួយ) ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យ ពន្យារការឃុំខ្លួន បណ្តោះអាសន្ននេះ បានតែ ២ (ពីរ) ដងគត់។[៦៣]

**ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន** កាលណាចៅក្រមស៊ើបសួរសម្រេចថាពន្យារពេលឃុំ ខ្លួនជាបណ្តោះអាសន្នចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ។ កាលណាជនត្រូវចោទ មាន មេធាវីអមនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនកូនក្តីរបស់ខ្លួន។ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្តោះអាសន្ន តាមដីកាដោយមានសំអាងហេតុ។ នៅក្នុង ដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួន បណ្តោះអាសន្ន) នៃក្រមនេះ ។ ហើយដីកានេះដែរ ត្រូវឱ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ ។[៦៤]

**ការដោះលែងជនត្រូវចោទឱ្យ នៅក្រៅឃុំដោយចៅក្រមស៊ើបសួរ** ចៅក្រមស៊ើបសួរ អាចបង្គាប់ ឱ្យដោះលែងជនត្រូវចោទ ឱ្យនៅក្រៅឃុំវិញ បានគ្រប់ពេលវេលា។ កាលណាចៅក្រមស៊ើបសួរមាន បំណងដោះលែងជនត្រូវចោទឱ្យ នៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរ ត្រូវជូនព័ត៌មាន ដល់ព្រះរាជអាជ្ញា ដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងឱ្យ ព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត។ ចៅក្រមស៊ើបសួរ អាចធ្វើការសម្រេចយ៉ាងយូរ បំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ បើក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យ ដោះលែងជនត្រូវចោទភ្លាមដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរ ត្រូវចង្អុលប្រាប់ មូលហេតុនៃការបន្ទាន់នេះ នៅក្នុងដីកាម្រេចរបស់ខ្លួន។[៦៥]

---

[៦២] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២០៩
[៦៣] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១០
[៦៤] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១១
[៦៥] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១៥

**ការដោះលែងឱ្យនៅក្រៅឃុំតាមបណ្តឹងរបស់ព្រះរាជអាជ្ញា** ព្រះរាជអាជ្ញា អាចសុំឱ្យដោះលែង ជនត្រូវចោទបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវ អាចធ្វើការសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ យ៉ាងយូរ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានធ្វើការសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនោះទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំ ទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរបាន។ ចំពោះដីកាដែលសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ មកអមជាមួយ។[៩៦]

**ការដោះលែងឱ្យ នៅក្រៅឃុំ តាមបណ្តឹងរបស់ជនត្រូវចោទ** ដែលជនត្រូវចោទអាចដាក់ពាក្យសុំឱ្យ ដោះលែងនៅក្រៅឃុំ បានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីត្រួតពិនិត្យ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុង រយៈពេលខ្លីបំផុត ចំណែកឯ ចៅក្រមស៊ើបសួរសម្រេច យ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ក្នុងករណីនេះ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំ សាជាថ្មីម្តងទៀតទៅ ចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរ ក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីមាន សេចក្តីសម្រេចបដិសេធពាក្យសុំលើកមុន។ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ ត្រូវសម្រេចលើពាក្យនេះ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃបន្ទាប់ពី បានទទួលពាក្យសុំរបស់ជនត្រូវចោទ។ ដីកាដែលមិនព្រមដោះលែងឱ្យនៅ ក្រៅឃុំត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិន បានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ជនត្រូវចោទអាចធ្វើ ពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។[៩៧]

**ការជូនដំណឹងអំពីដីកាដោះលែងឱ្យ នៅក្រៅឃុំ** ដីកាសម្រេច ដោះលែងឱ្យនៅក្រៅឃុំ ត្រូវតែជូនដំណឹងភ្លាមដល់ ព្រះរាជអាជ្ញា និងដល់ប្រធាន ពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ បទប្បញ្ញត្តិនៃមាត្រា ២៧៦ (ការដោះលែងជនត្រូវចោទដែលជាប់ឃុំ ឱ្យ មានសេរីភាព) នៃក្រមនេះ ត្រូវយកមកអនុវត្ត។ ចំពោះដីកាដែលមិនព្រមដោះលែងឱ្យនៅក្រៅឃុំត្រូវតែជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ កាលណាចៅក្រមស៊ើបសួរ សម្រេចឱ្យដោះលែងជនត្រូវចោទឱ្យ នៅក្រៅឃុំ ចៅក្រមនេះអាច ដាក់ជននោះ ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២២៣(កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) ដល់មាត្រា២៣០ (ការគេចវេះរបស់ ជនត្រូវចោទពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ ។[៩៨]

[៩៦] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១៦
[៩៧] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១៧
[៩៨] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១៨

### ខ. ការឃុំខ្លួនបណ្តោះអាសន្នអនីតិជន

**ចំពោះសេចក្តីសម្រេចទាក់ទងនឹងអនីតិជនមានអាយុតិចជាង១៤ (ដប់បួន) ឆ្នាំ** អនីតិជនដែលមានអាយុតិចជាង ១៤ (ដប់បួន)ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេច ប្រគល់ អនីតិជននេះឱ្យឪពុកម្តាយអ្នកអាណាព្យាបាល ឬក្នុងករណី គ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តី សម្រេចរបស់តុលាការ។[៩៩]

**ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជន** មានអាយុ ចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំចំពោះអនីតិជនអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំថិ) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ថិរវេលាឃុំខ្លួនបណ្តោះអាសន្ន មានដូចតទៅ៖

១. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ (បួន)ខែបានទេ កាលណា អនីតិជននេះ មានអាយុតិចជាង ១៦(ដប់ប្រាំមួយ) ឆ្នាំ ។

២. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ កាលណា អនីតិជននេះ មានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។[១០០]

**ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជន** ដែលមានអាយុ ចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងករណីនេះ ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវ ចោទប្រកាន់ពីបទមជ្ឈិម ថិរវេលាឃុំខ្លួនបណ្តោះអាសន្ន មានដូចតទៅ៖

១. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ២ (ពីរ)ខែ បានទេ កាលណា អនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ។

២. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ (បួន)ខែ បានទេ កាលណា អនីតិជននេះ មានអាយុចាប់ពី ១៦(ដប់ប្រាំមួយ)ឆ្នាំ ដប់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នតាមចំណុចទី១ និងចំណុចទី២ ខាងលើនេះ មិនត្រូវ លើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ។[១០១]

### ៤. ការអនុវត្តទោសចំពោះនីតិបុគ្គល

បើយោងតាមក្រមព្រហ្មទណ្ឌ ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល ត្រូវបានបែងចែងជាពីរប្រភេទគឺ ទោសពិន័យក្នុងឋានៈជាមូលទោស និងទោសបន្ថែម។

---

[៩៩] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១២

[១០០] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១៣

[១០១] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២១៤

### ៤.១. មូលទោសក្នុងឋានៈជាទោសពិន័យដែលអនុវត្តចំពោះនីតិបុគ្គល

ទោសពិន័យជាទោសដែលតម្រូវឲ្យនីតិបុគ្គលធ្វើការបង់ប្រាក់តាមការកំណត់របស់ច្បាប់ ទឹកប្រាក់ដែល តម្រូវឲ្យបង់នោះត្រូវគិតជាប្រាក់រៀលតាមការកំណត់។[១០២] ចំណែកប្រាក់ពិន័យដែលទទួលបាន ជាផលទោសពិន័យ ត្រូវបង់ចូលថវិការដ្ឋ។[១០៣]

### ៤.២. ទោសបន្ថែមដែលអនុវត្តចំពោះនីតិបុគ្គល

យោងមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌបានកំណត់ថា ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គល មានដូជា៖

១. ការរំលាយចោល។

២. ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។

៣. ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន។

៤. ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ។

៥. ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ។

៦. ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបានដែល កំណត់ដោយធនាគារ។

៧. ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់។

៨. ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស។

៩. ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់ សាធារណជនឬដែលបាន ប្រើប្រាស់ដោយសាធារណជន។

១០. ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែល មានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។

១១. ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

១២. ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

១៣. ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបាន ប្រព្រឹត្ត។

១៤. ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន សរសេរឬការផ្សាយតាមធ្យោបាយទូរគមនាគមន៍សោតទស្សន៍។ បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោស បន្ថែមដទៃទៀតបាន។

#### ក. លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម

[១០២] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៤៣
[១០៣] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ៥២

ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាង ជាក់លាក់ ចំពោះបទល្មើសដែលចោទប្រកាន់។[១០៤]

**ខ. ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល**

សេចក្តីសម្រេចដែលបង្គាប់ឲ្យរំលាយនីតិបុគ្គល នាំឲ្យមាន ការបញ្ជូននីតិបុគ្គលនេះទៅតុលាការ មានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី។[១០៥]

**គ. ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ**

ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ មិនអាចលើសពី ៥ (ប្រាំ) ឆ្នាំទេ។ សេចក្តីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឲ្យមាន ការចាត់តាំងអាណត្តិគាហក ដែលតុលាការបញ្ជាក់បេសកម្មរបស់ពួកគេ។ ជារៀងរាល់ ៦ (ប្រាំមួយ) ខែយ៉ាងតិច អាណត្តិគាហក ត្រូវបានតុលាការធ្វើរបាយការណ៍ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន។

ក្រោយពីបានឃើញរបាយការណ៍ របស់អាណត្តិគាហក តុលាការ ព្រះរាជអាជ្ញា អាចប្តឹងទៅ តុលាការដែលបានប្រកាស ឲ្យធ្វើ ការដាក់ក្រោម ការតាមដានរបស់តុលាការ។ តុលាការអាចប្រកាសនូវ ទោសថ្មីមួយ។

តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់តំណាង អយ្យការ អាណត្តិគាហកតុលាការ និងជាយថាហេតុ មេធាវីរបស់ នីតិបុគ្គលនោះ។[១០៦]

**ឃ. ការហាមឃាត់ចំពោះការធ្វើសកម្មភាព**

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់ចិរវេលា ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។ តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់។[១០៧]

**ង. ការណ្តេញចេញពីលទ្ធកម្មសាធារណៈ**

ទោសបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោផ្ទាល់ឬដោយប្រយោលនៅក្នុងគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំដោយ៖

១. រដ្ឋ។

២. រដ្ឋបាលថ្នាក់ក្រោមជាតិ។

៣. គ្រឹះស្ថានសាធារណៈ។

៤. សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ ដែលត្រួតពិនិត្យ ដោយរដ្ឋ ឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

---

[១០៤] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៦៩

[១០៥] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៧០

[១០៦] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៧១

[១០៧] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៧២

ទោសនេះអាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់ចិរវេលាមួយមិនលើសពី ៥ (ប្រាំ) ឆ្នាំ។[១០៨]

**ច. ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឲ្យធ្វើការសន្សំសំចៃ**

ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឲ្យធ្វើការដាក់ប្រាក់សន្សំអាចជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

ការហាមឃាត់នេះ នាំឲ្យមានការហាមឃាត់ដល់នីតិបុគ្គលចំពោះការអំពាវនាវដើម្បីឲ្យដាក់ឧបករណ៍ អាចជួញដូរបានរបស់ខ្លួនទៅក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុនមូលបត្រ។

ការហាមឃាត់នេះនាំឲ្យមានការហាមឃាត់ចំពោះការផ្សព្វផ្សាយជាសាធារណៈដែរ។[១០៩]

**ឆ. ការបិទគ្រឹះស្ថាន**

ទោសបិទគ្រឹះស្ថាននាំឲ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះ នូវសកម្មភាព ដែលមានបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ។ ទោសនេះអាចជាស្ថាពរ ឬជា បណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។[១១០]

**ជ. ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន**

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានមួយ ដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬជាបណ្ដោះអាសន្នក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។[១១១]

**ឈ. ការរឹបអូសកម្មសិទ្ធិការលក់ ការបំផ្លាញចោលវត្ថុរឹបអូស**

កាលបើការរឹបអូសក្លាយជាស្ថាពរ វត្ថុរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែបញ្ញត្តិដោយឡែកបានចែងអំពីការប្រគល់ផ្សេងទៀត។

រដ្ឋអាចលក់ ឬបំផ្លាញចោលវត្ថុរឹបអូសនៅក្នុងទម្រង់ដែលមានចែងសម្រាប់ការលក់ទ្រព្យសម្បត្តិរបស់ រដ្ឋ។ ច្បាប់អាចចែងអំពីការបំផ្លាញចោលនៅវត្ថុខ្លះផងដែរ។

កាលបើវត្ថុរឹបអូសមិនត្រូវបានចាប់យកទេ ហើយនិងមិនអាចប្រគល់ឲ្យបានទេនោះ ទណ្ឌិតត្រូវចេញសងវត្ថុរឹបអូសនេះ។ តម្លៃនេះត្រូវបានកំណត់ដោយតុលាការ។ វិធានការដើម្បីប្រមូលប្រាក់នេះត្រូវធ្វើឡើងដូចក្នុងរឿងបង្ខំដល់រូបកាយដែរ។[១១២]

**ញ. ការរឹបអូស និងសិទ្ធិតតិយជន**

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចខាងក្រោមៈ

---

[១០៨] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៧៣

[១០៩] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៧៤

[១១០] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៧៦

[១១១] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៧៧

[១១២] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៧៨

១. ឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅ សម្រាប់ប្រព្រឹត្តបទល្មើស។

២. វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

៣. ផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលដែលកើតចេញពីបទល្មើស។

៤. ឧបភោគភណ្ឌ សម្ភារៈ និងចលវត្ថុនៅទីកន្លែងដែលមានបទល្មើសបានកើតឡើង។

ក៏ប៉ុន្តែ ការរឹបអូសមិនអាចត្រូវប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន។[១៦៣]

**ដ. ការបិទផ្សាយសេចក្តីសម្រេច**

ការបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងចង្អុលប្រាប់តុលាការ និងសម្រាប់រយៈមួយដែល កំណត់ឡើងតុលាការ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ។ ការបិទផ្សាយអាចទាំងស្រុងតាមទម្រង់ ឬតាមនិទ្ទេសធម្មតា។ សោហ៊ុយនៃការបិទផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស។

ក្នុងករណីដែលដកបំបាត់ចេញ លាក់បំបាំង ឬហែកចោលសេចក្តីប្រកាសបិទផ្សាយនោះ ត្រូវធ្វើការបិទផ្សាយជាថ្មីម្តងទៀត។ សោហ៊ុយ នៃការចេញផ្សាយនេះត្រូវចេញដោយជនល្មើសដែលជាអ្នកដកបំបាត់ចោល លាក់បំបាំង ឬហែកចោល។[១៦៤]

**ឋ. ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍**

ទោសផ្សាយសេចក្តីសម្រេច តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ត្រូវអនុវត្តតាមបែបបទ ដែលកំណត់ឡើងដោយតុលាការ។ ការផ្សាយនេះមិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ។ ការផ្សាយនេះ អាចផ្សាយ ទាំងស្រុងតាមទម្រង់ ឬនិទ្ទេស។

ទោសផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និង ក្នុងថេរវេលា ដែលកំណត់ដោយតុលាការ។ សោហ៊ុយ ក្នុងការចុះផ្សាយ ជាបន្ទុករបស់នីតិបុគ្គល។ បើតុលាការបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារព័ត៌មានមិនអាចបដិសេធការចុះផ្សាយនេះបានទេ។[១៦៥]

## ផ្នែកទី ៤ ៖ ការរំលត់ទោស

ជាគោលការណ៍ ទោសដែលបានប្រកាសដោយសាលាជម្រះក្តីនានាត្រូវតែរលត់ទៅវិញ ដោយសារការអនុវត្តទោសបានចប់សព្វគ្រប់។ ក៏ប៉ុន្តែ ការសម្រេចផ្តន្ទាទោសដោយតុលាការ នៅតែរក្សាទុកជាស្លាកស្នាម ឬ

[១៦៣] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៧៩

[១៦៤] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៨០

[១៦៥] ក្រមព្រហ្មទណ្ឌ, ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២, ចុះថ្ងៃទី៣០ ខែវិច្ឆិកា ២០០៩, មាត្រា ១៨១

ភស្តុតាង និងមានអានុភាពគតិយុត្តជានិច្ច ដោយមូលហេតុថា ទណ្ឌកម្មទាំងនោះត្រូវបានកត់ត្រាទុកយ៉ាងច្បាស់លាស់នៅក្នុងបញ្ជីថ្កោលទោសជាដរាប។[១១៦]

### ១. មរណៈភាពរបស់ជនជាប់ទោស

ការរលត់ទោសដោយសារមូលហេតុមរណភាព គឺត្រូវបានទាញចេញពីគោលការណ៍ឯកត្តកម្មនៃទោស ដែលបានបញ្ញត្តថា **ទោសត្រូវយកមកអនុវត្តតែចំពោះជនប្រព្រឹត្តកំហុសផ្ទាល់ខ្លួនប៉ុណ្ណោះ។** ដូចនេះទោសដែលត្រូវបានរលត់ គឺជាទោសដាក់ពន្ធនាគារ ចំណែកទោសពិន័យជាប្រាក់ និង ការរឹបអូសផ្សេងៗទៀតនៅតែអាចបន្តអនុវត្តបានដដែល ពីព្រោះថា ថ្វីត្បិតតែពេលដែលជនជាប់ទោសបានទទួលមរណៈភាព ក៏បេតិកភណ្ឌរបស់គាត់ទាំងទ្រព្យសកម្ម និងអកម្ម ត្រូវតែផ្ទេរទៅសន្តតិជន តាមរយៈច្បាប់ស្តីពីសន្តិកម្ម។ ហេតុដូច្នេះសន្តតិជនជាអ្នកជាប់កាតព្វកិច្ចទទួលខុសត្រូវទោសពិន័យ និងត្រូវតែប្រគល់វត្ថុដែលត្រូវរឹបអូសតាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការ។[១១៧]

### ២. អជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោស គឺជាការរំលត់ទោសដែលពុំត្រូវបានដាក់ឲ្យអនុវត្តក្នុងរយៈពេលណាមួយជា កំណត់ ហើយត្រូវគិតចាប់ពីពេល ដែលបានផ្តន្ទាទោសដោយតុលាការបានចូលជាស្ថាពរ។ វិធានស្តីពីអាជ្ញាយុកាលបានបង្កើតឡើង ពីព្រោះថា ការកន្លងផុតទៅនៃពេលវេលាយូរអង្វែង នៃការស្វះស្វែងរកទណ្ឌិត បានជម្រុញឲ្យលុបចោលនូវ អានុភាពនៃបទល្មើស និង ធ្វើឲ្យលែងមានការចងចាំអំពីការផ្តន្ទាទោសតទៅទៀត។

បន្ថែមលើនេះទៀត យើងអាចជឿជាក់ថា ក្នុងរយៈពេលនៃអាជ្ញាយុកាលនៃទោស ទណ្ឌិតប្រាកដជាបានប្រព្រឹតតែអំពើល្អ ដើម្បីកុំឲ្យគេចាប់អារម្មណ៍លើខ្លួន។ ពោលគឺទណ្ឌិតបានកែប្រែខ្លួនរួចទៅហើយ ដូច្នេះពុំមានភាពចាំបាច់ចាប់បង្ខំយកទណ្ឌិតមកអនុវត្តទោសឡើយ។[១១៨]

### ៣. ការលើកលែងទោស

ការលើកលែងទោស គឺជាព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រ ហើយត្រូវបានបញ្ញត្ត នៅក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដែលមានខ្លឹមសារថា ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោសដល់ទណ្ឌិត។ ការលើកលែងទោសត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ [១១៩]

លើសពីនេះទៅទៀត ការលើកលែងទោសត្រូវធ្វើឡើង ដោយយោងតាមបុគ្គលិកលក្ខណៈរបស់ទណ្ឌិត។ ការលើកលែងទោសចំពោះទណ្ឌិតត្រូវកំណត់ ៥ (ប្រាំ) ដង ក្នុងមួយឆ្នាំ។ ព្រះមហាក្សត្រក៏អាចផ្តល់នូវ

[១១៦] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ៤៦២
[១១៧] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ៤៦៣
[១១៨] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញ៖ ២០១២), ទំព័រ ៤៦៤
[១១៩] មាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

ការលើកលែងទោសជាសមូហភាព នៅក្នុងពិធីផ្លូវការណាមួយដូចជា ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ពិធីបុណ្យពិសាខបូជា ពិធីបុណ្យឯករាជ្យជាតិ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។ លើសពីនេះ ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើបានក្នុងពិធីបុណ្យ ឬព្រឹត្តិការណ៍ធំៗរបស់ជាតិ ហើយការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចធ្វើរួម ឬដាច់ដោយឡែក ក្នុងពិធីនីមួយៗបាន។ ការលើកលែងទោសត្រូវសម្រេចឡើង ដោយអនុលោមតាមសំណើណាមួយ ក្រោយពីបានពិភាក្សាករណីនៃទណ្ឌិតរួចរាល់អស់។[១២០]

លក្ខខណ្ឌនៃការលើកលែងទោសមាន លក្ខខណ្ឌទាក់ទងនឹងកិរិយាមារយាទរបស់ទណ្ឌិត និង រយៈពេលនៃការទទួលរងទោស៖

លក្ខខណ្ឌទាក់ទងនឹងទណ្ឌិត ផ្អែកតាមបទបញ្ញត្តិនៃ មាត្រា ៥ នៃក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ១៩៨៨ ទណ្ឌិតត្រូវ បានទទួលការលើកលែងទោសដោយបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ទណ្ឌិតបានភ្ញាក់រលឹកខិតខំលត់ដំកែប្រែខ្លួនបានល្អ និង ប្តេជ្ញាខិតខំរៀនសូត្រអប់រំខ្លួនឲ្យល្អក្លាយ ជាពលរដ្ឋសុចរិត និងមានប្រយោជន៍។
- ទណ្ឌិតបានយកចិត្តទុកដាក់បំពេញការងារពលកម្មយ៉ាងសកម្មទៀងទាត់មានឥទ្ធិពលល្អ និង ជាគំរូល្អដល់ទណ្ឌិតដទៃទៀត។
- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀងទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្ម។
- ទណ្ឌិតបានគោរពប្រតិបត្តិយ៉ាងហ្មត់ចត់ត្រឹមត្រូវតាមរបបបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ។

ប្រធានពន្ធនាគារត្រូវធ្វើការវាយតម្លៃ និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌ ដូចដែលមានខាង លើរបស់ ទណ្ឌិត ហើយប្រធានពន្ធនាគារត្រូវបញ្ចូលឈ្មោះទណ្ឌិតក្នុងបញ្ជី ដែលត្រូវស្នើសុំទៅគណៈកម្មការ រាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងវាយតម្លៃអំពី កម្រិតកែប្រែរបស់ទណ្ឌិត។[១២១]

### ៤. ការលើកលែងទោសជាទូទៅ

ការលើកលែងទោសទូទៅ ជាវិធានការនីតិកម្មដែលមានគោលដៅលុបចោលនូវចរិតលក្ខណៈជាបទ ល្មើសមួយចំនួន។ ច្បាប់ស្តីពីការលើកលែងទោសទូទៅនេះមាន **គោលបំណង** ដើម្បីកុំឲ្យមានចំនួនទណ្ឌិតក្នុង ពន្ធនាគារច្រើនពេក ឬក៏ក្នុងឱកាសមានហេតុការណ៍ដ៏សំខាន់ណាមួយនៅក្នុង ការឡើងគ្រងរាជសម្បត្តិរបស់ព្រះមហាក្សត្រថ្មី។ លើសពីនេះ ច្បាប់ការលើកលែង ទោសទូទៅ អាចមានកម្មវត្ថុពាក់ព័ន្ធទាំងទោសព្រហ្មទណ្ឌ និងទណ្ឌកម្មផ្នែករដ្ឋបាល នេះប្រសិនបើច្បាប់បានចែងដូចនេះ។ ច្បាប់ស្តីពីការលើកលែងទោសទូទៅ កំណត់យ៉ាងច្បាស់លាស់ពី

[១២០] មាត្រា ៣ នៃក្រឹត្យលេខ ២៨ ក្រ, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨
[១២១] មាត្រា ៥ នៃក្រឹត្យលេខ ២៨ ក្រ, ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨

**កាលបរិច្ឆេទ** នៃការប្រព្រឹត្តបទ ល្មើសដែលត្រូវ លើកលែង ឬពីប្រភេទនៃបទល្មើសដែលត្រូវលើកលែងទោស ឬក៏ទោសប្រកាសប្រភេទណាមួយ ដែលនឹងត្រូវ បានលើកលែង។ ច្បាប់ស្តីពីការលើកលែងទោសក៏បានកំណត់ពី **លក្ខខណ្ឌ** នៃការលើកលែងទោសផងដែរ ដើម្បីឲ្យទណ្ឌិតទទួលបាននូវផលប្រយោជន៍ពីការលើកលែងទោស។ ច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ត្រូវ មានអានុភាពលុបបំបាត់ចោលទាំងស្រុងនូវទណ្ឌកម្មដែលពាក់ព័ន្ធទាំងអស់។ ចំពោះអំពើល្មើសដែលទទួល បាននូវការលើកលែងទោស ហើយមិនទាន់ត្រូវបាន វិនិច្ឆ័យដោយតុលាការនៅឡើយ បណ្តឹងអាជ្ញាត្រូវរលត់ ហើយតុលាការមិនអាចសម្រេចផ្តន្ទាទោសលើចារីបាននោះទេ។ ប្រសិនបើមានការផ្តន្ទាទោសស្ថាពរហើយ ក៏ការផ្តន្ទាទោសទាំងអស់ត្រូវចាត់ទុកជាឥតបានការ ដោយមិនអាចយកមកអនុវត្តបានឡើយ ម្យ៉ាងវិញទៀត បើទណ្ឌិតកំពុងរងទោសដាក់ស្ថិតពន្ធនាគារ ត្រូវតែ ទទួលការដោះលែងឲ្យមានសេរីភាពឡើងវិញ។[១២២]

បើយើងក្រឡេកមើលលើ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃមាត្រា ៩០ ថ្មី រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិប្បញ្ញត្តិ ហើយមានភារកិច្ចរបស់ខ្លួនក្នុង ការបង្កើត ឬលុបចោលកែប្រែ ច្បាប់ដែលត្រូវ ដែលការអនុម័តត្រូវប្រព្រឹត្តទៅដោយ រដ្ឋសភាត្រូវបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនខាតនៃ ចំនួនសមាជិករដ្ឋសភាទាំងមូល ។[១២៣]

### ៥. ការផ្តល់ និង ការមាននីតិសម្បទាឡើងវិញ

ការផ្តល់នីតិសម្បទាមានន័យថា ជាសមត្ថភាពដែលច្បាប់បើកឲ្យជនណាម្នាក់ធ្វើ កិច្ចការអ្វីមួយ ដែលមានលក្ខណៈស្របច្បាប់ ហើយសិទ្ធិដែលជននោះទទួលបាន គឺសិទ្ធិគ្រប់គ្រាន់តាមផ្លូវច្បាប់។[១២៤]

ទណ្ឌិតត្រូវធ្វើទម្រង់ពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញ ជូនទៅព្រះរាជអាជ្ញា ដែលមាន សមត្ថកិច្ចខាងដែនដី។ ទណ្ឌិតត្រូវចង្អុលបង្ហាញប្រភេទនៃទណ្ឌកម្មដែលខ្លួនបានរង និងបញ្ជាក់ ពីទីកន្លែងដែលខ្លួនបានលំនៅតាំងពីពេលដែលខ្លួនត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។[១២៥]

ការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញាជូនអគ្គព្រះរាជអាជ្ញា ដែលព្រះរាជអាជ្ញាចាត់ធ្វើការស៊ើបអង្កេតអំពីសីលធម៌នៅគ្រប់ទីកន្លែង ដែលទណ្ឌិតធ្លាប់បាន រស់នៅ តាំងពីពេលខ្លួនត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។ ដូចនេះព្រះរាជអាជ្ញាសុំឱ្យ ទណ្ឌិតប្រគល់មកខ្លួននូវៈ

- លិខិតចម្លងនៃសេចក្តីចសម្រេចផ្តន្ទាទោស
- លិខិតជូនដំណឹងអំពីកាលបរិច្ឆេទនៃការអនុវត្តទោសរួចហើយ

---

[១២២] រុន ពណ្ណារឹទ្ធ, នីតិព្រហ្មទណ្ឌទូទៅ, កែសម្រួលដោយចាំងស៊ីណាត (ភ្នំពេញៈ ២០១២), ទំព័រ (៤៧៧ ដល់ ៤៨០)
[១២៣] មាត្រា ៩០ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
[១២៤] ហ៊ីង ធីឫទ្ធិ, ២០១០, វចនានុក្រមច្បាប់, រាជធានីភ្នំពេញ
[១២៥] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៣៧

- ព្រឹត្តិបត្រលេខ ១ នៃបញ្ជីថ្កោលទោស ។

ព្រះរាជអាជ្ញា បញ្ជូនសំណុំរឿងដោយមានយោបល់ ដែលមានសំអាងហេតុរបស់ខ្លួនភ្ជាប់ជាមួយទៅអង្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។[១២]

នៅពេលដែលទណ្ឌិតត្រូវបានការដោះលែងឲ្យមានសេរីភាពធម្មតា មានន័យថាទណ្ឌិតទទួលបាន ការមាននីតិសម្បទាឡើងវិញបន្ទាប់ពីទទួលបានការអនុវត្តទោស។ មាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពី ៥៣៤ ដល់ ៥៤១។

### ៦. ការលុបចោលទោសបន្ថែមខ្លះ

តុលាការអាចបង្គាប់ឲ្យលុបចោលទោសមួយ ឬច្រើន នៃមាត្រា ៥៣ ដែលជាប្រភេទទោសបន្ថែមប្រសិនបើលក្ខខណ្ឌត្រូវបានបំពេញដូចជា៖

- ភាពច្របូកច្របល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ឈប់
- ព្យសនកម្មត្រូវបានជួសជុល
- សេចក្តីសម្រេចរៀបចំកែប្រែ ឬលុបចោល មានលក្ខណៈអនុគ្រោះឲ្យធ្វើការបញ្ជូនជនល្មើសទៅរស់នៅក្នុងសង្គមវិញ។

ការលុបចោលនូវទោសបន្ថែមនេះ ដោយតុលាការទទួលពាក្យបណ្តឹងពីអយ្យការតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមពាក្យប្តឹងរបស់ទណ្ឌិត ហើយតុលាការបានស្តាប់យោបល់តំណាងអយ្យការ ទណ្ឌិត និង មេធាវីរបស់ជនរងគ្រោះ ឬទណ្ឌិត។ ដូចនេះតុលាការសម្រេចបើកសវនាការសាធារណៈលុបចោលទោសបន្ថែមទៅតាមភស្តុតាងជាក់ស្តែង។

---

[១២] ក្រមនីតិវិធីព្រហ្មទណ្ឌ, នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ៥៣៨

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានដាក់ឲ្យអនុវត្តនៅក្នុងសង្គមខ្មែរ ដែលមានចែងនៅក្នុងរឿងក្តីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ យោងតាមគោលការណ៍ឯកតកម្ម បុគ្គលណាមួយដែល បានប្រព្រឹត្តបទល្មើសបុគ្គលនោះ ជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។ បុគ្គលដែលតម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនៅពេលប្រព្រឹត្តបទល្មើសរួមមាន រូបវន្តបុគ្គល សំដៅដល់ នីតិជន និងអនីតិជន និងចំណែក នីតីបុគ្គល សំដៅដល់នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលឯកជន។ ប៉ុន្តែ ការទទួលខុសត្រូវព្រហ្មទណ្ឌមានលក្ខណៈ និងមានកម្រិតខុសគ្នា។ នីតិជនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌមានលក្ខណៈធម្មតាទៅតាមច្បាប់ដែលមានចែង តែពេលខ្លះការទទួលខុសត្រូវក៏មានលក្ខណៈបន្ធូរបន្ថយតាមស្ថានភាពនៃជនល្មើស។ នីតិជនក៏អាចនឹងត្រូវ បានបន្ធូរបន្ថយទោស ប្រសិនបើជនល្មើសមានភាពវិបល្លាសស្មារតី ឬ ទទួលរងអានុភាពនៃកម្លាំង ឬការបង្ខំពីជនណាម្នាក់ឲ្យប្រព្រឹត្តអំពើល្មើស។ ចំពោះអនីតិជនត្រូវបាន ចែងចេញជាពីរប្រភេទ អនីតិជនក្រោម ១៤ ឆ្នាំ និង អនីតិជនអាយុ ១៤ ឆ្នាំឡើងទៅតែក្រោម ១៨។ អនីតិជន ក្រោម ១៤ ឆ្នាំ មិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌទេ តែអាណាព្យាបាលដែលតម្រូវឲ្យទទួលខុសត្រូវ តែមានលក្ខណៈជាសំណងរដ្ឋប្បវេណី។ ចំណែកអនីតិជនដែល មានអាយុចាប់ពី ១៤ ឆ្នាំក្រោម ១៨ តម្រូវឲ្យ ទទួលខុសត្រូវព្រហ្មទណ្ឌពាក់កណ្តាលនៃអតិប្បរមានៃទោស របស់នីតិជន។ ករណីចំពោះនីតិបុគ្គលជាស្ថាប័នដែលបណ្តុំទៅដោយក្រុមមនុស្សដែលធ្វើរួមគ្នា និងមានគោលបំណងតែមួយ ដូច្នេះនីតិបុគ្គលត្រូវទទួលខុសត្រូវជាទោសពិន័យ និងអាចត្រូវទទួលទោសបន្ថែម តាមប្រភេទបទល្មើសដែលនីតិបុគ្គលបានប្រព្រឹត្ត។ នៅពេលដែលរូបវន្តបុគ្គល និង នីតិបុគ្គលប្រព្រឹត្ត បទល្មើសការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកើតឡើង ចំណែកឯការអនុវត្តទោស ក៏ត្រូវដាក់ចេញតាមប្រភេទនៃទោស ដែលមានចែងដោយក្រមព្រហ្មទណ្ឌ។ ប្រភេទនៃទោសដែលត្រូវចែងក្នុងក្រម ព្រហ្មទណ្ឌរួមមាន មូលទោស ទោសបន្ថែម និងទោសជំនួស។ មូលទោសជាទោសមូលដ្ឋាន ដែលយកមកប្រើប្រាស់សម្រាប់ការប្រកាស ទោសចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានប្រព្រឹត្តបទល្មើស ហើយមូលទោសត្រូវបានចែងជាពីរគឺ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។ ទោសបន្ថែម ឬអនុទោស ជាទោសដែលតុលាការប្រកាស បន្ថែមទៅលើមូលទោសដែលត្រូវបានអនុវត្តលើរូបវន្តបុគ្គល និង នីតិបុគ្គល។ ទោសជំនួស សំដៅលើទោស ដែលជាទោសការងារ សហគមន៍ ឬការស្តីបន្ទោសដែលជំនួសឲ្យមូលទោស។ បន្ថែមលើនេះទៀត ពេលដែលមានការទទួលខុសត្រូវព្រហ្មទណ្ឌ នោះក៏នាំឲ្យមានការមិនទទួលខុសត្រូវព្រហ្មទណ្ឌ និងការសម្រាលទោសផងដែរ ហើយសកម្មភាពនេះក៏ត្រូវបានដាក់ចេញតាមស្ថានភាពជនល្មើស ឬស្ថានភាពនីតិបុគ្គល។ បើយើងក្រឡេកមើល លើការអនុវត្តទោស និងការដាក់ទោសមានភាពខុសគ្នារវាង រូបវន្តបុគ្គល និងនីតិបុគ្គល។ បន្ថែមលើសពីនេះទៅទៀត ការរំលត់ទោសក៏អាចត្រូវបានកើតឡើងទៅតាមបុគ្គលិកលក្ខណៈ របស់រូបវន្តបុគ្គល និងនីតិបុគ្គល ដែលបានប្រព្រឹត្តបទល្មើស ឬអំពើផ្ទុយ

នឹងច្បាប់ព្រហ្មទណ្ឌ។ ការរំលត់ទោស អាចកើតឡើងដោយសារ ការមរណៈភាពរបស់ជនជាប់ទោស អាជ្ញាយុកាលនៃទោស ការលើកលែងទោស ការលើកលែងទោសទូទៅ ការផ្ដល់ និងការមាននីតិសម្បទាឡើងវិញ និងការលុបចោលទោសបន្ថែមខ្លះ។ ការរលត់ទោសរបស់នីតិបុគ្គលកើតឡើងនៅពេលដែលមិនមានច្បាប់ចែង ឬក្នុងករណីអំពើល្មើសរបស់នីតិបុគ្គលនោះ បានផ្ដល់ប្រយោជន៍ច្រើនជាងការប៉ះពាល់នៃសង្គម។ នីតិបុគ្គលសាធារណៈមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ព្រោះនីតិបុគ្គលសាធារណៈស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ។ យើងអាចសន្និដ្ឋានបានថា កាលដែលរូបវន្តបុគ្គល និងនីតិបុគ្គល តម្រូវឲ្យទទួលខុសត្រូវព្រហ្មទណ្ឌដោយច្បាប់ពិតជាមានសារៈធំក្រៃលែងដល់សង្គមជាតិទាំងមូល ដូចជា ការលុប បំបាត់ និងកាត់បន្ថយបទល្មើស ការធ្វើឲ្យសង្គមមានសណ្ដាប់ធ្នាប់ សុវត្ថិភាព ស្ថិរភាព និងសន្តិភាព។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមរយៈការសិក្សា និងការស្រាវជ្រាវអត្ថបទសារណាបញ្ចប់ការសិក្សារបស់ យើងខ្ញុំស្ដីពី ការទទួលខុសត្រូវព្រហ្មទណ្ឌ ក្នុងនាមយើងខ្ញុំទាំងពីរនាក់ ជានិស្សិតដែលបានធ្វើការស្រាវជ្រាវ លើប្រធានបទមួយនេះ សុំចូលរួមផ្ដល់មតិខ្លះៗ ដើម្បីឱ្យស្ថាប័នដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ រួមមាន ស្ថាប័ននីតិបញ្ញត្តិ ដែលជាអ្នកតាក់តែងច្បាប់ ស្ថាប័ននីតិប្រតិបត្តិ ដែលដែលធ្វើការអនុវត្តច្បាប់ ស្ថាប័នតុលាការ ជាស្ថាប័នធ្វើការ ជម្រះក្ដី រកយុត្តិធម៌ ធ្វើការកំណត់ឱ្យជនល្មើល ទទួលខុសត្រូវព្រហ្មទណ្ឌ ឱ្យសមស្របតាមស្ថានភាពជាក់ស្ដែងរបស់ជនល្មើស និង តាមបរិបទសង្គមបច្ចុប្បន្ន។

- ស្ថាប័ននីតិបញ្ញត្តិ ដែលជាអ្នកតាក់តែងច្បាប់ និងធ្វើវិសោធនកម្មច្បាប់ គួរពិនិត្យមើលស្ថានភាពជាក់ ស្ដែងពីអាយុអនីតិជន គឺអនីតិជនក្រោម១៨ឆ្នាំ ដែលច្បាប់មិនតម្រូវឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ គប្បីធ្វើវិសោធនកម្មច្បាប់ ព្រោះថាបច្ចុប្បន្ន ដោយសារសង្គមរីកចម្រើនពិសេសបច្ចេកវិទ្យា មានទូរសព្ទ ស្មាតហ្វូនមានកម្មវិធីបណ្ដាញសង្គមនានា កុមារមានអាយុក្រោម១៨ឆ្នាំ ដែលទទួលរងផលមិនល្អ ពីការប្រើប្រាស់វាអាចប្រព្រឹត្តនូវអំពើល្មើសផ្សេងៗដូចជា ការវាយតប់គ្នា ការរំលោភសេពសន្ថវៈ ឬ អាចឈានដល់ការប្រព្រឹត្តអំពើឃាតកម្ម ដូចដែលបានឃើញក្នុងសង្គមបច្ចុប្បន្ន។
- ស្ថាប័ននីតិបញ្ញត្តិ គួរធ្វើវិសោធនកម្ម ដោយបន្ថែម រយៈពេលនៃការជាប់ពន្ធនាគារ និងការពិន័យ ជាប្រាក់របស់ទណ្ឌិតដែលបានប្រព្រឹត្ត បទល្មើសមានលក្ខណៈធ្ងន់ធ្ងរ។
- ស្ថាប័ននីតិប្រតិបត្ត ជាស្ថាប័នអនុវត្តច្បាប់ ជាពិសេសនគរបាលយុត្តិធម៌ ជាអ្នកដែលមានតួនាទី ពាក់ព័ន្ធលើការទទួលខុសត្រូវព្រហ្មទណ្ឌ ដូចជា ការចាប់ខ្លួនបទល្មើសជាក់ស្ដែង ការឃាត់ខ្លួន ការឃុំខ្លួន ដែលទទួលបានការអនុញ្ញាតពីព្រះរាជអាជ្ញា និងទទួលបានដីកាពីចៅក្រមស៊ើបសួរ គប្បីអនុវត្តការងារ ប្រកបដោយតម្លាភាព ដោយយុត្តិធម៌ និងស្របតាមនីតិវិធី មិនត្រូវឱ្យមាន ការអន្តរាគមន៍ពីជនណាម្នាក់ ដើម្បីឱ្យជនល្មើស រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ការដែលអាចរួចផុត ឬមិនទទួលខុសត្រូវព្រហ្មទណ្ឌ លើកលែងតែក្នុងករណីដែលច្បាប់បានចែង ក្នុងជំពូកទី២នៃក្រមព្រហ្មទណ្ឌ តែប៉ុណ្ណោះ។
- តុលាការ ជាស្ថាប័នដែលមានសមត្ថកិច្ចក្នុងការ ជម្រះក្ដី ដោះស្រាយរឿងក្ដី រកយុត្តិធម៌ ជូនប្រជាពលរដ្ឋ ធ្វើយ៉ាងណាត្រូវធានាឱ្យមាន យុត្តិធម៌ សមស្របតាមនីតិវិធី ដល់ជនរងគ្រោះ និងជនជាប់ចោទ ជៀសវាងការអនុវត្តមិនច្បាស់លាស់ លំអៀង ដែលបណ្ដាលឱ្យមានភាពអយុត្តិធម៌កើតឡើង។
- ព្រះរាជអាជ្ញាជាតំណាងអយ្យការ ដែលជាអ្នកមានសិទ្ធិធ្វើការចោទប្រកាន់ រាល់បទល្មើស ដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សង្គម ត្រូវធ្វើការចោទប្រកាន់ប្រកបដោយ ភាពត្រឹមត្រូវ ដោយមិនយោគយល់ដល់មនោសញ្ចេតនា ដែលអាចនាំឱ្យជនត្រូវចោទ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ លើសពីអំពើដែលខ្លួនបានប្រព្រឹត្ត។

- សូមឱ្យប្រព័ន្ធផ្សព្វផ្សាយ ទាំងទូរទស្សន៍ក្តី ទាំងវិទ្យុក្តី ទាំងតាមបណ្តាញសង្គមក្តី ធ្វើការ សហការ ជាមួយ ក្រសួងស្ថាប័នមានសមត្ថកិច្ច ដើម្បីបង្កើតកម្មវិធី ផ្សព្វផ្សាយច្បាប់ ដល់ប្រជាជនគ្រប់គ្នា ឱ្យបានយល់ដឹងទូលំទូលាយពីច្បាប់។
- សូមឱ្យមន្ត្រីរាជការ គ្រប់ជាន់ថ្នាក់ សូមកុំប្រើឥទ្ធិពល ប្រើអំណាច លុយកាក់ ទៅប្រព្រឹត្តអំពើ ផ្ទុយទៅនឹងច្បាប់ ហើយធ្វើយ៉ាងណាដើម្បីឱ្យខ្លួនផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលធ្វើ ឱ្យមានអំពើអយុត្តិធម៌កើតឡើង។
- សូមប្រជាជនគ្រប់គ្នា (រូបវន្តបុគ្គល) និង បណ្តាក្រុមហ៊ុន សហគ្រាស សមាគមន៍ អង្គការ(នីតិបុគ្គល) គួរសិក្សាស្វែងយល់ពីច្បាប់ តាមរយៈការអានសៀវភៅ ការស្តាប់ការពន្យល់ ពីអ្នកច្បាប់ ការសួរនាំអ្នកច្បាប់ ដើម្បីឱ្យការប្រព្រឹត្តសកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃ និងសកម្មភាពនានា ប្រកបតាមកន្លងច្បាប់ ដែលនាំឱ្យ ឲ្យផុតពីការទទួលខុសត្រូវទោស និងទោសពិន័យនានា ដែលមានចែងក្នុងរឿងក្តីព្រហ្មទណ្ឌ និងរដ្ឋប្បវេណី។

# ឯកសារយោង

## ឯកសារយោង

- វចនានុក្រម **សម្តេចសង្ឃរាជ្យ ជួនណាត**
- វដ្ឋធម្មនុញ្ញ ១៩៩៣
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- នីតិព្រហ្មទណ្ឌទូទៅ **រុន ពណ្ណារ័ទ្ធ**
- នីតិព្រហ្មទណ្ឌទូទៅរបស់ **សាស្ត្រាចារ្យ ហ៊ាង ឡេង**
- នីតិព្រហ្មទណ្ឌទូទៅរបស់ **សាស្ត្រាចារ្យ សេង នាង**
- នីតិព្រហ្មទណ្ឌទូទៅខ្មែរ **កៅ សីហា**
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- វចនានុក្រមច្បាប់ ស្នាដៃនិពន្ធទី ៦ របស់លោក ហ៊ីង ធីឫទ្ធិ

# ឧបសម្ព័ន្ធ

# ក្រមព្រហ្មទណ្ឌ

# ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

## គន្ថីទី ៦
## អវសានប្បញ្ញត្តិ
## ជំពូកទោល
## អវសានប្បញ្ញត្តិ

**មាត្រា ៦៧១.-** និរាករណ៍ និងអានុភាពនៃបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន

ច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុនដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវបាត់បង់អានុភាពចាប់ពីថ្ងៃដែលក្រមនេះ ត្រូវបានអនុវត្ត :

១-រាល់បទប្បញ្ញត្តិព្រហ្មទណ្ឌមុនឆ្នាំ ១៩៩២ ។

២-បទប្បញ្ញត្តិព្រហ្មទណ្ឌនៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

៣-ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ៧ ខែ មករា ឆ្នាំ ២០០២។

បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលមានអានុភាពនៅពេលក្រមនេះ ត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថា គ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ។

ប៉ុន្តែ បទប្បញ្ញត្តិព្រហ្មទណ្ឌពីមុនដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើ ត្រូវបន្តមានអានុភាពអនុវត្តក្រោយការអនុវត្តនៃក្រមនេះ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តមុនពេលក្រមនេះត្រូវបានអនុវត្ត លើកលែងតែបទប្បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៦៦៨ (ការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក) នៃក្រមនេះ ។

**មាត្រា ៦៧២.-** ការអនុវត្តក្រមនេះ

លើកលែងតែបទប្បញ្ញត្តិទូទៅនៃគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះដែលត្រូវ

យកទៅអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រមនេះ បទប្បញ្ញត្តិដទៃទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

**នស.០៩១១.១១២៨**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ:១០២៩ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ. ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**យុន ឋិនកេន**

# ច្បាប់
# ស្ដីពី
# វិសោធនកម្មក្រមព្រហ្មទណ្ឌ
# នៃព្រះរាជាណាចក្រកម្ពុជា

**ព្រះរាជក្រម**

***នស/រកម/០២១៨/០០៣***

**យើង**

**ព្រះករុណាព្រះបាទសម្តេចបរមនាថ នរោត្តម សីហមុនី**
**សមានភូមិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់
# ស្តីពី
# វិសោធនកម្មក្រមព្រហ្មទណ្ឌ

**មាត្រាមួយ.-**

ក្រមព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រូវបានធ្វើវិសោធនកម្មដោយបន្ថែម មាត្រា៤៣៧ (ស្ទួន) ដូចខាងក្រោម៖

**មាត្រា៤៣៧.- (ស្ទួន) បទប្រមាថចំពោះអង្គព្រះមហាក្សត្រ**

ការប្រមាថ គឺជាវាចារ កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃបុគ្គល។

ការប្រមាថចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទប្រមាថចំពោះអង្គព្រះមហាក្សត្រ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមនេះ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១ (ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមនេះ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពណាមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញ់ចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញ់ចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ។

**មាត្រាពីរ.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់។

ថ្ងៃ អង្គារ ១៣កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

*ពរល.១៨០២.២៣២*

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្ស វឌ្ឍានា**

# ព្រះរាជក្រម

នស/រកម/០៨០៧/០២៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាម ទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ក្រមនីតិវិធីព្រហ្មទណ្ឌ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

# គន្ថីទី ១១
# អវសានប្បញ្ញត្តិ
# ជំពូកតោល
# អវសានប្បញ្ញត្តិ

**មាត្រា ៦១១.** – និរាករណ៍នៃអត្ថបទច្បាប់ស្ដីពីនីតិវិធីពីមុន

បទប្បញ្ញត្តិដូចតទៅនេះត្រូវទុកជានិរាករណ៍ :

- រាល់បទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌ មុនឆ្នាំ ១៩៩២
- បទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌ នៃបទប្បញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩២
- ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើដោយក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ ១៩៩៣
- ព្រះរាជក្រមលេខ ០៨៩៩/០៩ ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន
- ច្បាប់ស្ដីពីវិសោធនកម្មមាត្រា ៣៦ មាត្រា ៣៨ មាត្រា ៩០ និងមាត្រា ៩១ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០២/០០៥ ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០២

បទប្បញ្ញត្តិស្ដីពីនីតិវិធីនៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣ ពុំអាចអនុវត្តចំពោះរឿងព្រហ្មទណ្ឌបានឡើយ ។

**មាត្រា ៦១២.** – ការអនុវត្តភ្លាមនូវក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនេះត្រូវអនុវត្តភ្លាម ចំពោះគ្រប់កិច្ចនីតិវិធីក្រោយក្រមនេះចូលជាធរមាន ។

ការអនុវត្តភ្លាមនូវបទប្បញ្ញត្តិនៃក្រមនេះ ពុំមានអានុភាពលើសុពលភាពនៃកិច្ចនីតិវិធីទាំងឡាយដែលត្រូវបានបំពេញរួចរាល់ហើយ ដោយអនុលោមតាមច្បាប់ចាស់ឡើយ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នស.០៧០៨.៣៧១** **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ:៣៤៩ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ. ថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**យុន ចិនកេន**

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ជំពូកទី ១៦
# អវសានប្បញ្ញត្តិ

## មាត្រា ៨៩.- ការអនុវត្តច្បាប់នេះ

ក្រោយពីចូលជាធរមាននៅទូទាំងប្រទេស ច្បាប់នេះត្រូវផ្សព្វផ្សាយរយៈពេល ៦ (ប្រាំមួយ) ខែ ទើបអនុវត្ត ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១៦

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាបន្ទាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

នស/រកម/០៧១៦/០១០

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ដលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ហត្ថលេខា**

**វង សូត**

លេខ: ៧២៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ច្បាប់

# ស្តីពី

# ការត្រួតពិនិត្យគ្រឿងញៀន




២/៧៩

# ព្រះរាជក្រម

នស/រកម/០១១២/០០១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ច្បាប់ចម្លង

**ព្រះរាជក្រឹត្យ**

**ស្តីពី**

នស/រកត/០១២១/០៣០

**ការបន្ធូរបន្ថយទោស និងការលើកលែងទោស**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ត្រាស់បង្គាប់**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៨.-**

ក្រឹត្យលេខ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩.-**

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ អង្គារ ១៤រោច ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២១

នស/រកត.០១២១.០៣៤

ន សីហមុនី

**នរោត្តម សីហមុនី**

**បានប្រមាប់ព្រះរាជលញ្ឆករហើយ**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

## បុព្វកថា

## យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភធំទូលាយថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយទ្រុឌទ្រោមឱនថយមហាសោកស្តាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈ មោះមុត ប្តូរផ្តាច់ រួបរួមគ្នាពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា "កោះសន្តិភាព" ឡើងវិញផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើង រីកចំរើនលូតលាស់ សម្បូររុងរឿង ជានិច្ច និរន្តរ៍ ។

### ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

## គណៈកម្មាធិការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ
## បានអនុម័តដោយសភាធម្មនុញ្ញនាសម័យប្រជុំពេញអង្គលើកទី ១
## ថ្ងៃទី ៣០ ខែ មិថុនា ១៩៩៣

១.ឯកឧត្តមសម្តេចប្រធានសភាធម្មនុញ្ញឬឯកឧត្តមអនុប្រធានសភាធម្មនុញ្ញ "ករណីសម្តេចប្រធានអវត្តមាន" ជាប្រធាន

| | |
|---|---|
| ២- ឯកឧត្តម ចែម ស្ងួន | ជាអនុប្រធាន |
| ៣- ឯកឧត្តមបណ្ឌិត តាវ សេងហួរ | ជាអ្នករាយការណ៍ |
| ៤- ឯកឧត្តម កាន់ ម៉ន | ជាសមាជិក |
| ៥- ឯកឧត្តម តាត ឈន់ | ជាសមាជិក |
| ៦- ឯកឧត្តម ឈួរ លាងហួត | ជាសមាជិក |
| ៧- ឯកឧត្តម ថៅ ប៉េងលាត | ជាសមាជិក |
| ៨- ឯកឧត្តម សម រង្សី | ជាសមាជិក |
| ៩-អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរត្ន | ជាសមាជិក |
| ១០- ឯកឧត្តម សឺន ស៊ូប៊ែរ្តិ៍ | ជាសមាជិក |
| ១១- ឯកឧត្តម សោម ចាន់បុត្រ | ជាសមាជិក |
| ១២- ឯកឧត្តម អ៊ុន នឹង | ជាសមាជិក |
| ១៣- ឯកឧត្តម ឡូយ ស៊ីមឈាង | ជាសមាជិក |
| ១៤- ឯកឧត្តម ជាម យៀប | ជាសមាជិកបំរុង |
| ១៥- ឯកឧត្តម ប៉ុល ហំម | ជាសមាជិកបំរុង |
| ១៦- ឯកឧត្តម ពូរ សុធីរៈ | ជាសមាជិកបំរុង |
| ១៧- ឯកឧត្តម សរ សំអាត | ជាសមាជិកបំរុង |
| ១៨- ឯកឧត្តម អ៊ឹង គៀត | ជាសមាជិកបំរុង |
| ១៩- ឯកឧត្តម អ៊ុក វ៉ាប៊ុន | ជាសមាជិកបំរុង |
| ២០- ឯកឧត្តម អ៊ុង ផន | ជាសមាជិកបំរុង |
| ២១- ឯកឧត្តម ឯក សំអុល | ជាសមាជិកបំរុង |
| ២២- ឯកឧត្តម សាយ បូរី | ជាអ្នកជំនាញការ |
| ២៣- ឯកឧត្តម ចាន់ សុខ | ជាអ្នកជំនាញការ |
| ២៤- ឯកឧត្តម ឈន អៀម | ជាអ្នកជំនាញការ |
| ២៥- ឯកឧត្តម ហេង វង្សប៊ុនឆាត | ជាអ្នកជំនាញការ |
| ២៦- ឯកឧត្តម ខៀវ វ៉ាដា | ជាអ្នកជំនាញការ |

# ច្បាប់
# ស្តីពី
# មាត្រា ២៨ នៃរដ្ឋធម្មនុញ្ញ

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤
នាសម័យប្រជុំវិសាមញ្ញសម័យពិសេស
ភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤

ប្រធានរដ្ឋសភាស្តីទី
ហត្ថលេខា
**ឡូយ ស៊ីមឈាង**

នស/រកម/០៣៩៩/០១

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមមាត្រា ១១ ជំពូកទី ២ ស្តីពី **ព្រះមហាក្សត្រ** នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ**កម្ពុជា** ដែលត្រូវបានសភាធម្មនុញ្ញ អនុម័តនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣

**បញ្ញាប់**

**មាត្រា១** : ប្រកាសឱ្យប្រើជាផ្លូវការ នូវច្បាប់ស្តីពីការកែប្រែមាត្រា ២៨នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាដែលរដ្ឋសភា បានអនុម័ត នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

**មាត្រា២** : ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

ធ្វើនៅព្រះរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៤
ក្នុងព្រះបរមនាថ និងតាមព្រះរាជចំណារ
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងត្រា
**ជា ស៊ីម**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ច្បាប់ធម្មនុញ្ញ

# ស្តីពី

# វិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨

# ៣០ ៣៤ ៥១ ៩០ ៩១ ៩៣

# និងមាត្រានាំងឡាយ នៃជំពូកទី ៨

# ដល់

# ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ

ច្បាប់ធម្មនុញ្ញនេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ០៤ ខែ មិនា ឆ្នាំ ១៩៩៩ ក្នុងសម័យប្រជុំវិសាមញ្ញ នីតិកាលទី ២ ។

**ភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៩**

**ប្រធានរដ្ឋសភា**

**ហត្ថលេខា និងត្រា**

**នរោត្តម រណឫទ្ធិ**

នស/រកម/០៣៩៩/០១

**ព្រះរាជក្រម**

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-ទ្រង់យល់សម័យប្រជុំវិសាមញ្ញពេញអង្គ នៃរដ្ឋសភានៅថ្ងៃទី ២-៣-៤ ខែ មីនា ឆ្នាំ ១៩៩៩

-យោងតាមសំណើរបស់ ប្រធានរដ្ឋសភា ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៩៩

ត្រាស់បង្គាប់

**មាត្រា១** : ប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩ ។

**មាត្រា២** : ព្រះរាជក្រមនេះចូលជាធរមានច្បាប់ ចាប់ពីពេល ឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩

ព្រះរាជលញ្ឆករ ,

**នរោត្តម សីហនុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

# ច្បាប់រដ្ឋធម្មនុញ្ញ
# ស្តីពី
# វិសោធនកម្មមាត្រា ១៩ និង មាត្រា ២៩ នៃរដ្ឋធម្មនុញ្ញ

**មាត្រាតែមួយ** : មាត្រា១៩ និងមាត្រា ២៩ នៃរដ្ឋធម្មនុញ្ញត្រូវបានកែប្រែដូចតទៅ :

**មាត្រា ១៩ ថ្មី.-**

ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីតាមបែបបទដែលមានចែងក្នុង មាត្រា ១១៩ ថ្មី ។

**មាត្រា ២៩ ថ្មី.-**

ព្រះមហាក្សត្រទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រទ្រង់សំរេចប្រទានឋានន្តរសក្តិ ឋានៈ យោធា និងស៊ីវិលតាមច្បាប់កំណត់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យ
ប្រជុំរដ្ឋសភា លើកទី ៦ នីតិកាលទី ២ ។
ភ្នំពេញ.ថ្ងៃទី ខែ កក្កដា ឆ្នាំ ២០០១

**នរោត្តមរណឫទ្ធិ**

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៤
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ នៃព្រឹទ្ធសភា នាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤
- យោងតាមសំណើ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ របស់ព្រឹទ្ធសភា សមាជិករដ្ឋសភា នីតិកាលទី ៣

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

នស/រកម/០៣០៦/០០៦

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់តំណាងរាស្ត្រចំនួនលើសពីមួយភាគបួននៃចំនួនតំណាងរាស្ត្រទាំងមូល
- បានទ្រង់យល់លិខិតលេខ ៨២ លស ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់សម្តេចនាយករដ្ឋមន្ត្រី
- បានទ្រង់យល់លិខិតលេខ ០០១/០១/២០០៦ កបធ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជសារព្រះមហាក្សត្រចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦
- បានទ្រង់យល់លិខិតលេខ ២៥៤ រស ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៦ របស់រដ្ឋសភា
- បានទ្រង់យល់លិខិតលេខ ០១៣/០៣០៦/ពស/នវ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០៦ របស់ព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៨២ មាត្រា ៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា១០៦ថ្មី មាត្រា១១១ថ្មី (មួយ) មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័ន-ជាតិ ដែលរដ្ឋសភាអនុម័តនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភា លើកទី ៤ នីតិកាលទី ៣ និងដែល-

ព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

## ច្បាប់រដ្ឋធម្មនុញ្ញ
## ស្តីពី
## វិសោធនកម្ម
## មាត្រា៨២ មាត្រា៨៨ថ្មី មាត្រា៩០ថ្មី មាត្រា៩៨ មាត្រា ១០៦ថ្មី មាត្រា ១១១ថ្មី (មួយ) មាត្រា១១៤ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

### មាត្រាតែមួយ.-

មាត្រា ៨២ មាត្រា ៨៨ ថ្មី មាត្រា ៩០ ថ្មី មាត្រា ៩៨ ថ្មី មាត្រា ១០៦ ថ្មី មាត្រា ១១១ ថ្មី (មួយ) មាត្រា ១១៤ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៦ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ត្រូវបានកែប្រែដូចតទៅ :

### មាត្រា ៨២.- ថ្មី

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធាន រដ្ឋសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៥ នៃរដ្ឋធម្មនុញ្ញ ។

### មាត្រា ៨៨.- ថ្មី(ពីរ)

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬ ពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភា នឹងយកជាការបានលុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែល

តម្រូវឱ្យយកមតិភាគច្រើន ពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្ដាល នៃចំនួនសមាជិករដ្ឋសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩០.- ថ្មី(ពីរ)**

រដ្ឋសភាជាអង្គការ ដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្ដីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្ដីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាលតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៩៨.- ថ្មី**

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែងដោយអនុម័តញ្ញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាល ត្រូវបានលើកឡើងជូនរដ្ឋសភាដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

**មាត្រា ១០៦.- ថ្មី (មួយ)**

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរក្រោយពេលបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្ដើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នា នូវប្រធាន អនុប្រធានព្រឹទ្ធសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភាដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី ៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ១១១.- ថ្មី (ពីរ)**

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

ក- កូរ៉ុមលើសពី ពីរភាគបី នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ខ- កូរ៉ុមលើសពីពាក់កណ្ដាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលសម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

**មាត្រា ១១៤.~ ថ្មី (មួយ)**

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ។ បទបញ្ជាផ្ទៃក្នុងនេះត្រូវអនុម័តយល់ព្រម ដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**មាត្រា ៦.~ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម**

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីការបោះឆ្នោតជុំទីមួយមិនបានសម្រេច នីតិវិធីដដែលនេះនឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៦០៣.១២៤

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ដលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខ : ១១៣ ច.ល

**ដើម្បីចម្លងចែក**

**រាជធានីភ្នំពេញ ថ្ងៃទី ខែ មីនា ឆ្នាំ ២០០៦**

**ហត្ថលេខា**

**ឈាងី តាន់**